ខោនធី Los Angeles
សៀវភៅណែនាំសមាជិកអំពីសេវាសុខភាពអាកប្បកិរិយា

សេវាឯកទេសសុខភាពផ្លូវចិត្ត
និងប្រព័ន្ធសម្រាបសម្រួលព្យាបាលការប្រើប្រាស់សារធាតុញៀនដែលផ្តល់ដោយ Medi-Cal

នាយកដ្ឋានសុខភាពផ្លូវចិត្ត
510 South Vermont Avenue
Los Angeles, CA 90020

នាយកដ្ឋានសុខភាពសាធារណៈ: (SAPC)
1000 South Fremont Avenue, A-9 East, Box #34
Alhambra, CA 91803

ទូរសព្ទលេខ៖ (800) 854-7771
អាចទំនាក់ទំនងបាន 24 **ម៉ោងក្នុងមួយថ្ងៃ និង** 7 **ថ្ងៃក្នុងមួយសប្តាហ៍**

កាលបរិច្ឆេទមានប្រសិទ្ធភាព៖ ថ្ងៃទី 1 ខែមករា ឆ្នាំ 2026[1]

សេចក្តីជូនដំណឹងអំពីសេវាកម្មជំនួយភាសា និងសេវាកម្ម និងឧបករណ៍ជំនួយដែលមានផ្តល់ជូន

English

ATTENTION: If you need help in your language call 1-800-854-7771 (TTY: 711). Aids and services for people with disabilities, like documents in braille and large print, are also available. Call 1-800-854-7771 (TTY: 711). These services are free of charge.

العربية (Arabic)

يُرجى الانتباه: إذا احتجت إلى المساعدة بلغتك، فاتصل بـ 1-800-854-7771 (TTY: 711). تتوفر أيضًا المساعدات والخدمات للأشخاص ذوي الإعاقة، مثل المستندات المكتوبة بطريقة بريل والخط الكبير. اتصل بـ 1-800-854-7771 (TTY: 711). هذه الخدمات مجانية.

Հայերեն (Armenian)

ՈՒՇԱԴՐՈՒԹՅՈՒՆ: Եթե Ձեզ օգնություն է հարկավոր Ձեր լեզվով, զանգահարեք 1-800-854-7771 (TTY: 711): Կան նաև օժանդակ միջոցներ ու ծառայություններ հաշմանդամություն ունեցող անձանց համար, օրինակ՝ Բրայլի գրատիպով ու խոշորատառ տպագրված նյութեր: Զանգահարեք 1-800-854-7771 (TTY: 711): Այդ ծառայություններն անվճար են:

ខ្មែរ (Khmer)

សូមចំណាំ៖ បើអ្នកត្រូវការជំនួយជាភាសារបស់អ្នក សូមទូរសព្ទទៅលេខ 1-800-854-7771 (TTY: 711)។ ជំនួយ និងសេវាកម្មសម្រាប់ជនពិការដូចជាឯកសារសរសេរជាអក្សរផុស សម្រាប់ជនពិការភ្នែក ឬឯកសារសរសេរជាអក្សរពុម្ពធំ ក៏អាចរកបានផងដែរ។ ទូរសព្ទមកលេខ 1-800-854-7771 (TTY: 711)។ សេវាកម្មទាំងនេះមិនគិតថ្លៃឡើយ។

繁體中文 (Chinese)

请注意：如果您需要以您的母语提供帮助，请致电 1-800-854-7771 (TTY: 711)。另外还提供针对残疾人士的帮助和服务，例如盲文和需要较大字体阅读，也是方便取用的。请致电 1-800-854-7771 (TTY: 711)。这些服务都是免费的。

فارسی (Farsi)

توجه: اگر می‌خواهید به زبان خود کمک دریافت کنید، با 1-800-854-7771 (TTY: 711) تماس بگیرید. کمک‌ها و خدمات مخصوص افراد دارای معلولیت، مانند نسخه‌های خط بریل و چاپ با حروف بزرگ، نیز موجود است. با 1-800-854-7771 (TTY: 711) تماس بگیرید. این خدمات رایگان ارائه می‌شوند.

[1] សៀវភៅណែនាំនេះត្រូវតែផ្តល់ជូននៅពេលដែលសមាជិកចូលប្រើប្រាស់សេវាកម្មជាលើកដំបូង។

हिंदी (Hindi)
ध्यान दें: अगर आपको अपनी भाषा में सहायता की आवश्यकता है तो 1-800-854-7771 (TTY: 711) पर कॉल करें। अशक्तता वाले लोगों के लिए सहायता और सेवाएं, जैसे ब्रेल और बड़े प्रिंट में भी दस्तावेज़ उपलब्ध हैं। 1-800-854-7771 (TTY: 711) पर कॉल करें। ये सेवाएं नि: शुल्क हैं।

Hmoob (Hmong)
CEEB TOOM: Yog koj xav tau kev pab txhais koj hom lus hu rau 1-800-854-7771 (TTY: 711). Muaj cov kev pab txhawb thiab kev pab cuam rau cov neeg xiam oob qhab, xws li puav leej muaj ua cov ntawv su thiab luam tawm ua tus ntawv loj. Hu rau 1-800-854-7771 (TTY: 711). Cov kev pab cuam no yog pab dawb xwb.

日本語 (Japanese)
注意日本語での対応が必要な場合は 1-800-854-7771 (TTY: 711)へお電話ください。点字の資料や文字の拡大表示など、障がいをお持ちの方のためのサービスも用意しています。 1-800-854-7771 (TTY: 711)へお電話ください。これらのサービスは無料で提供しています。

한국어 (Korean)
유의사항: 귀하의 언어로 도움을 받고 싶으시면 1-800-854-7771 (TTY: 711) 번으로 문의하십시오. 점자나 큰 활자로 된 문서와 같이 장애가 있는 분들을 위한 도움과 서비스도 이용 가능합니다. 1-800-854-7771 (TTY: 711) 번으로 문의하십시오. 이러한 서비스는 무료로 제공됩니다.

ພາສາລາວ (Laotian)
ປະກາດ: ຖ້າທ່ານຕ້ອງການຄວາມຊ່ວຍເຫຼືອໃນພາສາຂອງທ່ານໃຫ້ໂທຫາເບີ 1-800-854-7771 (TTY: 711). ຍັງມີຄວາມຊ່ວຍເຫຼືອແລະການບໍລິການສໍາລັບຄົນພິການ
ເຊັ່ນເອກະສານທີ່ເປັນອັກສອນນູນແລະມີໂຕພິມໃຫຍ່ ໃຫ້ໂທຫາເບີ
1-800-854-7771 (TTY: 711). ການບໍລິການເຫຼົ່ານີ້ບໍ່ຕ້ອງເສຍຄ່າໃຊ້ຈ່າຍໃດໆ.

Mien
LONGC HNYOUV JANGX LONGX OC: Beiv taux meih qiemx longc mienh tengx faan benx meih nyei waac nor douc waac daaih lorx taux 1-800-854-7771 (TTY: 711). Liouh lorx jauv-louc tengx aengx caux nzie gong bun taux ninh mbuo wuaaic fangx mienh, beiv taux longc benx nzangc-pokc bun hluo mbiutc aengx caux aamz mborqv benx domh sou se mbenc nzoih bun longc. Douc waac daaih lorx 1-800-854-7771 (TTY: 711). Naaiv deix nzie weih gong-bou jauv-louc se benx wang-henh tengx mv zuqc cuotv nyaanh oc.

ਪੰਜਾਬੀ (Punjabi)
ਧਿਆਨ ਦਿਓ: ਜੇ ਤੁਹਾਨੂੰ ਆਪਣੀ ਭਾਸ਼ਾ ਵਿੱਚ ਮਦਦ ਦੀ ਲੋੜ ਹੈ ਤਾਂ ਕਾਲ ਕਰੋ 1-800-854-7771 (TTY: 711). ਅਪਾਹਜ ਲੋਕਾਂ ਲਈ ਸਹਾਇਤਾ ਅਤੇ ਸੇਵਾਵਾਂ, ਜਿਵੇਂ ਕਿ ਬ੍ਰੇਲ ਅਤੇ ਮੋਟੀ ਛਪਾਈ ਵਿੱਚ ਦਸਤਾਵੇਜ਼, ਵੀ ਉਪਲਬਧ ਹਨ| ਕਾਲ ਕਰੋ 1-800-854-7771 (TTY: 711). ਇਹ ਸੇਵਾਵਾਂ ਮੁਫਤ ਹਨ|

Русский (Russian)
ВНИМАНИЕ! Если вам нужна помощь на вашем родном языке, звоните по номеру 1-800-854-7771 (линия TTY: 711). Также предоставляются средства и услуги для людей с ограниченными возможностями, например документы крупным шрифтом или шрифтом Брайля. Звоните по номеру 1-800-854-7771 (линия TTY: 711). Такие услуги предоставляются бесплатно.

Español (Spanish)
ATENCIÓN: si necesita ayuda en su idioma, llame al 1-800-854-7771 (TTY: 711). También ofrecemos asistencia y servicios para personas con discapacidades, como documentos en braille y con letras grandes. Llame al 1-800-854-7771 (TTY: 711). Estos servicios son gratuitos.

Tagalog (Filipino)
ATENSIYON: Kung kailangan mo ng tulong sa iyong wika, tumawag sa 1-800-854-7771 (TTY: 711). Mayroon ding mga tulong at serbisyo para sa mga taong may kapansanan,tulad ng mga dokumento sa braille at malaking print. Tumawag sa 1-800-854-7771 (TTY: 711). Libre ang mga serbisyong ito.

ภาษาไทย (Thai)
โปรดทราบ: หากคุณต้องการความช่วยเหลือเป็นภาษาของคุณ กรุณาโทรศัพท์ไปที่หมายเลข 1-800-854-7771 (TTY: 711) น
อกจากนี้ ยังพร้อมให้ความช่วยเหลือและบริการต่าง ๆ สำหรับบุคคลที่มีความพิการ เช่น เอกสารต่าง ๆ ที่เป็นอักษรเบรลล์และเอกสารที่พิมพ์ด้วยตัวอักษรขนาดใหญ่ กรุณาโทรศัพท์ไปที่หมายเลข 1-800-854-7771 (TTY: 711) ไม่มีค่าใช้จ่ายสำหรับบริการเหล่านี้

Українська (Ukrainian)
УВАГА! Якщо вам потрібна допомога вашою рідною мовою, телефонуйте на номер 1-800-854-7771 (TTY: 711). Люди з обмеженими можливостями також можуть скористатися допоміжними засобами та послугами, наприклад, отримати документи, надруковані шрифтом Брайля та великим шрифтом. Телефонуйте на номер 1-800-854-7771 (TTY: 711). Ці послуги безкоштовні.

Tiếng Việt (Vietnamese)
CHÚ Ý: Nếu quý vị cần trợ giúp bằng ngôn ngữ của mình, vui lòng gọi số 1-800-854-7771 (TTY: 711). Chúng tôi cũng hỗ trợ và cung cấp các dịch vụ dành cho người khuyết tật, như tài liệu bằng chữ nổi Braille và chữ khổ lớn (chữ hoa). Vui lòng gọi số 1-800-854-7771 (TTY: 711). Các dịch vụ này đều miễn phí.

តារាងមាតិកា

ភាសា និងទម្រង់ផ្សេងទៀត 6
ព័ត៌មានទំនាក់ទំនងខោនធី 8
គោលបំណងនៃសៀវភៅណែនាំនេះ 10
ព័ត៌មានអំពីសេវាសុខភាពអាកប្បកិរិយា 12
ការទទួលបានសេវាសុខភាពអាកប្បកិរិយា 15
ការជ្រើសរើសអ្នកផ្តល់សេវា 25
សិទ្ធិរបស់អ្នកក្នុងការចូលមើលកំណត់ត្រាសុខភាពអាកប្បកិរិយា
និងព័ត៌មានបញ្ជីអ្នកផ្តល់សេវាដោយប្រើប្រាស់ឧបករណ៍ឆ្លាតវៃ 29
ទំហំនៃសេវាកម្ម 30
សេវាកម្មដែលមានតាមរយៈទូរសព្ទ ឬតាមកម្មវិធីសុខភាពពីចម្ងាយ 61
ដំណើរការដោះស្រាយបញ្ហា ដើម្បីដាក់ពាក្យបណ្តឹង ប្តឹងឧទ្ធរណ៍
ឬស្នើសុំសវនាការយុត្តិធម៌របស់រដ្ឋ 62
ឯកសារណែនាំជួរការជាមុន 76
សិទ្ធិ និងទំនួលខុសត្រូវ 77
សេចក្តីជូនដំណឹងអំពីការមិនរើសអើង 91
ការជូនដំណឹងអំពីការអនុវត្តឯកជនភាព 94
ពាក្យដែលត្រូវដឹង 95
ព័ត៌មានបន្ថែមអំពីខោនធីរបស់អ្នក 108

ភាសាផ្សេងទៀត

ប្រសិនបើអ្នកត្រូវការជំនួយជាភាសារបស់អ្នក សូមទូរសព្ទទៅលេខ 1-800-854-7771 (TTY: 711)។ ជំនួយ និងសេវាកម្មសម្រាប់ជនពិការ ដូចជាឯកសារជាអក្សរប្រេល និងអក្សរធំ ក៏មានផងដែរ។ សូមទូរសព្ទទៅលេខ 1-800-854-7771 (TTY: 711)។ សេវាកម្មទាំងនេះគឺមិនគិតថ្លៃទេ។

ទម្រង់ផ្សេងទៀត

អ្នកអាចទទួលបានព័ត៌មាននេះជាទម្រង់ផ្សេងទៀត ដូចជាអក្សរប្រេល
អក្សរធំទំហំ 20 ចុច ជាសំឡេង
និងជាទម្រង់អេឡិចត្រូនិកដែលអាចចូលប្រើបានដោយមិនគិតថ្លៃ។
សូមទូរសព្ទទៅកាន់លេខទូរសព្ទខោនធីដែលមានរាយនៅលើគម្របសៀវភៅណែនាំនេះ (TTY: 711)។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ។

សេវាអ្នកបកប្រែផ្ទាល់មាត់

ខោនធីផ្តល់សេវាបកប្រែផ្ទាល់មាត់ពីអ្នកបកប្រែដែលមានសមត្ថភាព 24 ម៉ោងក្នុងមួយថ្ងៃ ដោយមិនគិតថ្លៃ។ អ្នកមិនចាំបាច់ប្រើប្រាស់សមាជិកគ្រួសារ ឬមិត្តភក្តិជាអ្នកបកប្រែទេ។
យើងមិនលើកទឹកចិត្តការប្រើប្រាស់អនីតិជនជាអ្នកបកប្រែទេ លុះត្រាតែវាជាគ្រាអាសន្ន។ ខោនធីក៏អាចផ្តល់ឧបករណ៍ជំនួយ

និងសេវាដល់សមាជិកគ្រួសារ មិត្តភក្តិ
ឬអ្នកផ្សេងទៀតដែលសមស្របក្នុងការទំនាក់ទំនងជាមួយអ្នក។
សេវាកម្មអ្នកបកប្រែ ផ្នែកភាសា និងផ្នែកវប្បធម៌អាចរកបានដោយមិនគិតថ្លៃ។
ជំនួយមាន 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍។ សម្រាប់ជំនួយភាសា
ឬដើម្បីទទួលបានសៀវភៅណែនាំនេះជាភាសាផ្សេង
សូមទូរសព្ទទៅលេខទូរសព្ទខោនធីដែលមានរាយនៅលើគម្របសៀវភៅណែនាំនេះ
(TTY: 711)។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ។

ព័ត៌មានទំនាក់ទំនងខោនធី

យើងខ្ញុំនៅទីនេះដើម្បីជួយ។
ព័ត៌មានទំនាក់ទំនងរបស់ខោនធីខាងក្រោមនឹងជួយអ្នកឱ្យទទួលបានសេវាកម្មដែលអ្នកត្រូវការ។

ខ្សែទូរសព្ទជំនួយសម្រាប់សេវាសុខភាពផ្លូវចិត្ត និងវិបត្តប្រើប្រាស់សារធាតុញៀនរបស់ខោនធី Los Angeles
ទូរសព្ទ៖ (800) 854-7771 ផ្តល់សេវាកម្ម 24/7

នាយកដ្ឋានសុខភាពផ្លូវចិត្តខោនធី Los Angeles
គេហទំព័រ៖ https://dmh.lacounty.gov
បញ្ជីអ្នកផ្តល់សេវា៖ https://dmh.lacounty.gov/pd
ផ្ទាំងផ្ទៃមុខកម្មវិធីសម្រាប់ចូលប្រើប្រាស់របស់អ្នកជំងឺ (API)៖
https://dmh.lacounty.gov/our-services/access-your-medical-records/patientaccess/
ទូរសារសម្រាប់ដាក់ពាក្យបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍៖ (213) 330-0285

នាយកដ្ឋានសុខភាពសាធារណៈ ការបង្ការ និងការគ្រប់គ្រងការប្រើប្រាស់សារធាតុលើសកម្រិតនៃខោនធី Los Angeles
គេហទំព័រ៖ http://publichealth.lacounty.gov/sapc
បញ្ជីអ្នកផ្តល់សេវា៖ https://SUDHelpLA.org
ផ្ទាំងផ្ទៃមុខកម្មវិធីសម្រាប់ចូលប្រើប្រាស់របស់អ្នកជំងឺ (API)៖
https://pax.sapc.ph.lacounty.gov/
ទូរសារសម្រាប់ដាក់ពាក្យបណ្តឹងតវ៉ា និងបណ្តឹងឧទ្ធរណ៍៖ (626) 458-6692

តើខ្ញុំគួរទាក់ទងអ្នកណា ប្រសិនបើខ្ញុំមានគំនិតចង់សម្លាប់ខ្លួន?
ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់កំពុងជួបវិបត្តិ សូមទូរសព្ទទៅលេខ 988
សម្រាប់ជំនួយសង្គ្រោះបន្ទាន់លើវិបត្ត និងការសម្លាប់ខ្លួន តាមរយៈលេខ **988**

ឬខ្សែទូរសព្ទជាតិសម្រាប់បង្ការការសម្លាប់ខ្លួនតាមលេខ **1-800-273-TALK (8255)**។
ការជជែកអាចរកបាននៅ https://988lifeline.org/.
ដើម្បីចូលប្រើប្រាស់កម្មវិធីក្នុងតំបន់របស់អ្នក សូមទូរសព្ទទៅកាន់ខ្សែទូរសព្ទចូលប្រើប្រាស់ 24/7 ដែលបានរាយខាងលើ។

គោលបំណងនៃសៀវភៅណែនាំនេះ

ហេតុអ្វីបានជាការអានសៀវភៅណែនាំនេះគឺជាការសំខាន់?

ខោនធីរបស់អ្នកមានផែនការសុខភាពផ្លូវចិត្តដែលផ្តល់ជូននូវសេវាសុខភាពផ្លូវចិត្តដែលគេស្គាល់ថាជា "សេវាសុខភាពផ្លូវចិត្តពិសេស"។ លើសពីនេះ ខោនធីរបស់អ្នកមានប្រព័ន្ធព្យាបាលរិបត្តប្រើប្រាស់ថ្នាំរៀបចំដោយ Medi-Cal
ដែលផ្តល់ជូននូវសេវាកម្មសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ដែលគេស្គាល់ថាជា "សេវាសម្រាប់រិបត្តិប្រើប្រាស់សារធាតុញៀន"។ សេវាកម្មទាំងនេះរួមគ្នាត្រូវបានគេស្គាល់ថាជា "សេវាសុខភាពអាកប្បកិរិយា"
ហើយវាជាការសំខាន់ដែលអ្នកមានព័ត៌មានអំពីសេវាកម្មទាំងនេះ
ដើម្បីឱ្យអ្នកអាចទទួលបានការថែទាំដែលអ្នកត្រូវការ។
សៀវភៅណែនាំនេះពន្យល់អំពីអត្ថប្រយោជន៍របស់អ្នក និងរបៀបទទួលបានការថែទាំ។
វាក៏នឹងឆ្លើយសំណួរជាច្រើនរបស់អ្នកផងដែរ។

អ្នកនឹងយល់ដឹងអំពី៖

- របៀបទទួលបានសេវាសុខភាពអាកប្បកិរិយាតាមរយៈខោនធីរបស់អ្នក។
- អត្ថប្រយោជន៍អ្វីខ្លះដែលអ្នកអាចទទួលបាន។
- អ្វីដែលត្រូវធ្វើប្រសិនបើអ្នកមានសំណួរ ឬបញ្ហា។
- សិទ្ធិ និងកាតព្វកិច្ចរបស់អ្នកក្នុងនាមជាសមាជិកនៃខោនធីរបស់អ្នក។
- ថាតើនឹងមានព័ត៌មានបន្ថែមអំពីខោនធីរបស់អ្នក
  ដែលអាចត្រូវបានចង្អុលបង្ហាញនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះ។

ប្រសិនបើអ្នកមិនទាន់បានអានសៀវភៅណែនាំនេះឥឡូវនេះទេ អ្នកគួរតែរក្សាវាទុក
ដើម្បីអ្នកអាចអានវានៅពេលក្រោយ។
សៀវភៅនេះត្រូវបានបម្រុងទុកសម្រាប់ប្រើរួមជាមួយសៀវភៅដែលអ្នកទទួលបាននៅពេលចុះឈ្មោះសម្រាប់អត្ថប្រយោជន៍ Medi-Cal របស់អ្នក។ ប្រសិនបើអ្នកមានសំណួរអំពីអត្ថប្រយោជន៍

Medi-Cal របស់អ្នក

សូមទូរសព្ទទៅខោនធីដោយប្រើលេខទូរសព្ទនៅផ្នែកខាងមុខនៃសៀវភៅនេះ។

តើខ្ញុំអាចទៅកន្លែងណាដើម្បីទទួលបានព័ត៌មានបន្ថែមអំពី Medi-Cal?

សូមចូលទៅកាន់គេហទំព័ររបស់នាយកដ្ឋានសេវាថែទាំសុខភាពតាមរយៈ

https://www.dhcs.ca.gov/services/medi-cal/eligibility/Pages/Beneficiaries.aspx

សម្រាប់ព័ត៌មានបន្ថែមអំពី Medi-Cal ។

ព័ត៌មានអំពីសេវាសុខភាពអាកប្បកិរិយា

តើធ្វើដូចម្តេចដើម្បីដឹងថាអ្នក ឬនរណាម្នាក់ដែលអ្នកស្គាល់ត្រូវការជំនួយ?

មនុស្សជាច្រើនឆ្លងកាត់គ្រាលំបាកក្នុងជីវិត ហើយអាចជួបប្រទះនឹងស្ថានភាពសុខភាពផ្លូវចិត្ត ឬវិបត្តិនៃការប្រើប្រាស់សារធាតុញៀន។ រឿងសំខាន់បំផុតដែលត្រូវចងចាំគឺថា
ជំនួយគឺមានផ្តល់ជូន។ ប្រសិនបើអ្នក
ឬសមាជិកគ្រួសាររបស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medi-Cal
ហើយត្រូវការសេវាសុខភាពអាកប្បកិរិយា អ្នកគួរតែទូរសព្ទទៅខ្សែទូរសព្ទចូលប្រើ 24/7
ដែលមានរាយនៅលើគម្របសៀវភៅណែនាំនេះ។
ផែនការថែទាំដែលបានគ្រប់គ្រងរបស់អ្នកក៏អាចជួយអ្នកទាក់ទងខោនធីរបស់អ្នកផងដែរ
ប្រសិនបើពួកគេជឿថាអ្នក
ឬសមាជិកគ្រួសារត្រូវការសេវាសុខភាពអាកប្បកិរិយាដែលផែនការថែទាំដែលបានគ្រប់គ្រងមិនគ្របដណ្តប់។
ខោនធីរបស់អ្នកនឹងជួយអ្នកស្វែងរកអ្នកផ្តល់សេវាសម្រាប់សេវាកម្មដែលអ្នកអាចនឹងត្រូវការ។

បញ្ជីខាងក្រោមអាចជួយអ្នកសម្រេចចិត្តថាតើអ្នក ឬសមាជិកគ្រួសារត្រូវការជំនួយឬអត់។
ប្រសិនបើមានសញ្ញាច្រើនជាងមួយ ឬកើតឡើងក្នុងរយៈពេលយូរ
វាអាចជាសញ្ញានៃបញ្ហាធ្ងន់ធ្ងរជាងនេះដែលត្រូវការចាំបាច់នូវជំនួយពីអ្នកជំនាញ។
ខាងក្រោមនេះគឺជាសញ្ញាទូទៅមួយចំនួនដែលអ្នកប្រហែលជាត្រូវការជំនួយជាមួយនឹងស្ថានភាពសុខភាពផ្លូវចិត្ត ឬស្ថានភាពវិបត្តិប្រើប្រាស់សារធាតុញៀន៖

ផ្នែកគំនិត និងអារម្មណ៍

- ការផ្លាស់ប្តូរអារម្មណ៍ខ្លាំង ប្រហែលជាគ្មានហេតុផល ដូចជា៖
    - កង្វល់ ថប់បារម្ភ ឬភ័យខ្លាចច្រើនពេក
    - សោកសៅ ឬធ្លាក់ទឹកចិត្តពេក
    - ល្អពេក អស្ចារ្យពេក
    - មានអារម្មណ៍ឆេវឆាវ ឬខឹងយូរពេក

- ការគិតអំពីការសម្លាប់ខ្លួន
- គោតតែលើការទទួលបាន និងការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន
- បញ្ហាផ្តោតអារម្មណ៍ ការចងចាំ ឬការគិតឡជីខល និងការនិយាយដែលពិបាកពន្យល់
- បញ្ហាជាមួយនឹងការស្តាប់ ការមើលឃើញ ឬការដឹងអំពីរបស់ដែលពិបាកពន្យល់ ឬដែលមនុស្សភាគច្រើននិយាយថាមិនមាន

ផ្នែករាងកាយ

- បញ្ហារាងកាយជាច្រើន ប្រហែលជាគ្មានមូលហេតុច្បាស់លាស់ ដូចជា៖
    - ឈឺក្បាល
    - ឈឺពោះ
    - គេងច្រើនពេក ឬតិចពេក
    - ញ៉ាំច្រើនពេក ឬតិចពេក
    - មិនអាចនិយាយបានច្បាស់លាស់
- សភាពរូបរាងធ្លាក់ចុះ ឬមានការព្រួយបារម្ភខ្លាំងអំពីរូបរាង ដូចជា៖
    - ការស្រកទម្ងន់ ឬឡើងទម្ងន់ភ្លាមៗ
    - ភ្នែកក្រហម និងប្រស្រីភ្នែកធំខុសពីធម្មតា
    - មានក្លិនចម្លែកៗចេញពីដង្ហើម រាងកាយ ឬសម្លៀកបំពាក់

ផ្នែកអាកប្បកិរិយា

- មានផលវិបាកពីអាកប្បកិរិយារបស់អ្នកដោយសារតែការផ្លាស់ប្តូរសុខភាពផ្លូវចិត្តរបស់អ្នក ឬការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ដូចជា៖
    - មានបញ្ហានៅកន្លែងធ្វើការ ឬសាលារៀន
    - បញ្ហាក្នុងទំនាក់ទំនងជាមួយអ្នកដទៃ ក្រុមគ្រួសារ ឬមិត្តភក្តិ
    - ភ្លេចអំពីការប្តេជ្ញាចិត្តរបស់អ្នក
    - មិនអាចអនុវត្តសកម្មភាពប្រចាំថ្ងៃធម្មតាបានទេ
- ការដៀសវាងមិត្តភក្តិ ក្រុមគ្រួសារ ឬសកម្មភាពសង្គម
- មានអាកប្បកិរិយាសម្ងាត់ ឬត្រូវការលុយដោយសម្ងាត់
- ការចូលរួមជាមួយប្រព័ន្ធច្បាប់ដោយសារតែការផ្លាស់ប្តូរសុខភាពផ្លូវចិត្តរបស់អ្នក ឬការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន

សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ

តើខ្ញុំដឹងដោយរបៀបណាថាពេលណាកុមារ ឬមនុស្សដែលមានអាយុក្រោម 21 ឆ្នាំត្រូវការជំនួយ?

អ្នកអាចទាក់ទងទៅខោនធី
ឬផែនការថែទាំដែលបានគ្រប់គ្រងរបស់អ្នកសម្រាប់ការត្រួតពិនិត្យ
និងការវាយតម្លៃសម្រាប់កូន ឬក្មេងជំទង់របស់អ្នក
ប្រសិនបើអ្នកគិតថាពួកគេកំពុងបង្ហាញសញ្ញានៃស្ថានភាពសុខភាពអាកប្បកិរិយា។
ប្រសិនបើកូន ឬក្មេងជំទង់របស់អ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ Medi-Cal
ហើយការត្រួតពិនិត្យ ឬការវាយតម្លៃបង្ហាញថាសេវាសុខភាពអាកប្បកិរិយាគឺចាំបាច់
នោះខោនធីនឹងរៀបចំឱ្យកូន ឬក្មេងជំទង់របស់អ្នកទទួលបានសេវាសុខភាពអាកប្បកិរិយា។
ផែនការថែទាំដែលបានគ្រប់គ្រងរបស់អ្នកក៏អាចជួយអ្នកទាក់ទងខោនធីរបស់អ្នកផងដែរ
ប្រសិនបើពួកគេជឿថាកូន
ឬក្មេងជំទង់របស់អ្នកត្រូវការសេវាសុខភាពអាកប្បកិរិយាដែលផែនការថែទាំដែលបានគ្រប់គ្រង
មិនគ្របដណ្តប់។
មានការផ្តល់ជូនសេវាកម្មដែលមានសម្រាប់ឪពុកម្តាយដែលមានអារម្មណ៍តានតឹងដោយសារតែ
បន្តកជាឪពុកម្តាយ។
អនីតិជនអាយុចាប់ពី 12 ឆ្នាំឡើងទៅ
អាចនឹងមិនត្រូវការការយល់ព្រមពីឪពុកម្តាយដើម្បីទទួលបានការព្យាបាលសុខភាពផ្លូវចិត្តដែ
លមិនស្នាក់នៅមន្ទីរពេទ្យ ឬការប្រឹក្សាយោបល់ទេ
ប្រសិនបើអ្នកជំនាញដែលចូលរួមជឿជាក់ថាអនីតិជនមានភាពចាស់ទុំគ្រប់គ្រាន់ដើម្បីចូលរួម
ក្នុងសេវាសុខភាពអាកប្បកិរិយា។ អនីតិជនអាយុ 12 ឆ្នាំឡើងទៅ
អាចនឹងមិនត្រូវការការយល់ព្រមពីឪពុកម្តាយដើម្បីទទួលបានការថែទាំផ្នែកវេជ្ជសាស្ត្រ
និងការប្រឹក្សាយោបល់ដើម្បីព្យាបាលបញ្ហាទាក់ទងនឹងរបិត្តិនៃការប្រើប្រាស់សារធាតុញៀន។
ការចូលរួមពីឪពុកម្តាយ ឬអាណាព្យាបាលគឺត្រូវបានតម្រូវចាំបាច់

លុះត្រាតែអ្នកជំនាញដែលចូលរួមកំណត់ថាការចូលរួមរបស់ពួកគេនឹងមិនសមរម្យបន្ទាប់ពីពិគ្រោះជាមួយអនីតិជន។

បញ្ជីខាងក្រោមអាចជួយអ្នកសម្រេចចិត្តថាតើកូន ឬក្មេងជំទង់របស់អ្នកត្រូវការជំនួយឬអត់។ ប្រសិនបើមានសញ្ញាច្រើនជាងមួយ ឬនៅតែបន្តកើតមានរយៈពេលយូរ វាអាចមានន័យថាកូន ឬក្មេងជំទង់របស់អ្នកមានបញ្ហាធ្ងន់ធ្ងរជាងនេះដែលត្រូវការជំនួយពីអ្នកជំនាញ។
ខាងក្រោមនេះជាសញ្ញាមួយចំនួនដែលត្រូវរកមើល៖

- មានបញ្ហាច្រើនផ្តោតអារម្មណ៍ ឬនៅស្ងៀម ធ្វើឲ្យពួកគេគ្រោះថ្នាក់រាងកាយ ឬបង្កបញ្ហាដល់ការសិក្សា
- ការព្រួយបារម្ភខ្លាំង ឬការភ័យខ្លាចដែលរារាំងសកម្មភាពប្រចាំថ្ងៃ
- ការភ័យខ្លាចជាខ្លាំងភ្លាមៗដោយគ្មានហេតុផល ជួនកាលមានចង្វាក់បេះដូងលោតញាប់ ឬដកដង្ហើមលឿន
- មានអារម្មណ៍សោកសៅខ្លាំង ឬនៅឆ្ងាយពីអ្នកដទៃរយៈពេលពីរសប្តាហ៍ ឬច្រើនជាងនេះ ដែលធ្វើឱ្យមានបញ្ហាជាមួយនឹងសកម្មភាពប្រចាំថ្ងៃ
- ការប្រែប្រួលអារម្មណ៍ខ្លាំងដែលបណ្តាលឱ្យមានបញ្ហាក្នុងទំនាក់ទំនង
- ការផ្លាស់ប្តូរអាកប្បកិរិយាយ៉ាងខ្លាំង
- មិនញ៉ាំអាហារ ក្អួត ឬប្រើថ្នាំដើម្បីសម្រកទម្ងន់
- ការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀនម្តងហើយម្តងទៀត
- អាកប្បកិរិយាធ្ងន់ធ្ងរមិនអាចគ្រប់គ្រងបាន ដែលអាចធ្វើឱ្យខ្លួនឯង ឬអ្នកដទៃឈឺចាប់
- មានផែនការម៉ត់ចត់ ឬព្យាយាមធ្វើបាប ឬសម្លាប់ខ្លួនឯង
- ឈ្លោះគ្នាដដែលៗ ការប្រើប្រាស់អាវុធ ឬផែនការម៉ត់ចត់ដើម្បីធ្វើឱ្យអ្នកដទៃឈឺចាប់

ការទទួលបានសេវាសុខភាពអាកប្បកិរិយា

តើខ្ញុំទទួលបានសេវាសុខភាពអាកប្បកិរិយាដោយរបៀបណា?

ប្រសិនបើអ្នកគិតថាអ្នកត្រូវការសេវាសុខភាពអាកប្បកិរិយាដូចជាសេវាសុខភាពផ្លូវចិត្ត និង/ឬសេវាសម្រាប់រឹបត្តិប្រើប្រាស់សារធាតុញៀន
អ្នកអាចទូរសព្ទទៅខោនធីរបស់អ្នកដោយប្រើលេខទូរសព្ទដែលមានរាយនៅលើគម្របសៀវភៅ

ណែនាំនេះ។ នៅពេលដែលអ្នកទាក់ទងខោនធីរួច អ្នកនឹងទទួលបានការត្រួតពិនិត្យ
ហើយនឹងត្រូវបានកក់ពេលសម្រាប់ការណាត់ជួបសម្រាប់ការវាយតម្លៃ។

អ្នកក៏អាចស្នើសុំសេវាសុខភាពអាកប្បកិរិយាពីផែនការថែទាំដែលគ្រប់គ្រងរបស់អ្នកបានដែរ
ប្រសិនបើអ្នកជាសមាជិក។
ប្រសិនបើផែនការថែទាំដែលគ្រប់គ្រងកំណត់ថាអ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យនៃការទទួលបាន
សេវាសុខភាពអាកប្បកិរិយា
ផែនការថែទាំដែលគ្រប់គ្រងនឹងជួយអ្នកឱ្យទទួលបានការវាយតម្លៃដើម្បីទទួលបានសេវាសុខភា
ពអាកប្បកិរិយាតាមរយៈខោនធីរបស់អ្នក។ ចុងបំផុត
មិនមានមធ្យោបាយដែលខុសសម្រាប់ការទទួលបានសេវាសុខភាពអាកប្បកិរិយានោះឡើយ។
អ្នកថែមទាំងអាចទទួលបានសេវាសុខភាពអាកប្បកិរិយាតាមរយៈផែនការថែទាំដែលគ្រប់គ្រង
របស់អ្នក បន្ថែមពីលើសេវាសុខភាពអាកប្បកិរិយាតាមរយៈខោនធីរបស់អ្នកទៀតផង។
អ្នកអាចចូលប្រើសេវាទាំងនេះតាមរយៈអ្នកផ្តល់សេវាសុខភាពអាកប្បកិរិយារបស់អ្នក
ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកកំណត់ថាសេវាកម្មទាំងនោះសមស្របតាមគ្លីនិកសម្រាប់អ្នក
និងដរាបណាសេវាកម្មទាំងនោះត្រូវបានសម្របសម្រួល និងមិនស្ទួនគ្នា។

បន្ថែមពីនេះ សូមចងចាំចំណុចខាងក្រោម៖

- អ្នកអាចនឹងត្រូវបានបញ្ជូនទៅកាន់ខោនធីរបស់អ្នកសម្រាប់សេវាសុខភាពអាកប្បកិរិ
  យាដោយបុគ្គល ឬស្ថាប័នផ្សេងទៀត រួមទាំងគ្រូពេទ្យទូទៅ/វេជ្ជបណ្ឌិតរបស់អ្នក
  សាលារៀន សមាជិកគ្រួសារ អាណាព្យាបាល ផែនការថែទាំដែលបានគ្រប់គ្រងរបស់អ្នក
  ឬភ្នាក់ងារខោនធីផ្សេងទៀត។ ជាធម្មតា វេជ្ជបណ្ឌិតរបស់អ្នក
  ឬផែនការថែទាំដែលគ្រប់គ្រងនឹងត្រូវការការយល់ព្រមពីអ្នក
  ឬការអនុញ្ញាតពីឪពុកម្តាយ ឬអ្នកថែទាំកុមារ
  ដើម្បីធ្វើការបញ្ជូនដោយផ្ទាល់ទៅកាន់ខោនធី លុះត្រាតែមានអាសន្ន។
- ខោនធីរបស់អ្នកអាចនឹងមិនបដិសេធសំណើសុំធ្វើការវាយតម្លៃដំបូងដើម្បីកំណត់ថាតើ
  អ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលបានសេវាសុខភាពអាកប្បកិរិយា។
- សេវាសុខភាពអាកប្បកិរិយាអាចត្រូវបានផ្តល់ជូនដោយខោនធី

ឬអ្នកផ្តល់សេវាផ្សេងទៀតដែលខោនធីមានកិច្ចសន្យាជាមួយ (ដូចជាគ្លីនិក
មជ្ឈមណ្ឌលព្យាបាល អង្គការដែលមានមូលដ្ឋាននៅសហគមន៍
ឬអ្នកផ្តល់សេវាជាលក្ខណៈបុគ្គល)។

តើខ្ញុំអាចទទួលបានសេវាសុខភាពអាកប្បកិរិយានៅឯណា?

អ្នកអាចទទួលបានសេវាសុខភាពអាកប្បកិរិយានៅក្នុងខោនធីដែលអ្នករស់នៅ
និងនៅខាងក្រៅខោនធីរបស់អ្នកប្រសិនបើចាំបាច់។
ខោនធីនីមួយៗមានសេវាសុខភាពផ្លូវចិត្តសម្រាប់កុមារ យុវវ័យ មនុស្សពេញវ័យ
និងមនុស្សចាស់។ ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ
អ្នកមានសិទ្ធិទទួលបានការធានារ៉ាប់រង និងអត្ថប្រយោជន៍បន្ថែមក្រោមការត្រួតពិនិត្យដំបូង
និងតាមកាលកំណត់ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល។ សូមមើលផ្នែក
"ការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល"
នៃសៀវភៅណែនាំនេះសម្រាប់ព័ត៌មានបន្ថែម។

ខោនធីរបស់អ្នកនឹងជួយអ្នកស្វែងរកអ្នកផ្តល់សេវាដែលអាចផ្តល់ការថែទាំដែលអ្នកត្រូវការ។
ខោនធីត្រូវតែបញ្ជូនអ្នកទៅកាន់អ្នកផ្តល់សេវាដែលនៅជិតផ្ទះរបស់អ្នកបំផុត
ឬក្នុងចន្លោះពេល ឬស្តង់ដារចម្ងាយ ដែលនឹងបំពេញតម្រូវការរបស់អ្នក។

តើខ្ញុំអាចទទួលបានសេវាសុខភាពអាកប្បកិរិយានៅពេលណា?

ខោនធីរបស់អ្នកត្រូវតែបំពេញតាមស្តង់ដារពេលវេលាណាត់ជួបនៅពេលកំណត់ពេលសេវាកម្ម
សម្រាប់អ្នក។ សម្រាប់សេវាសុខភាពផ្លូវចិត្ត ខោនធីត្រូវតែផ្តល់ជូនអ្នកនូវការណាត់ជួប៖

- ក្នុងរយៈពេល 10 ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃស្នើសុំមិនបន្ទាន់របស់អ្នក
  ដើម្បីចាប់ផ្តើមសេវាកម្មជាមួយផែនការសុខភាពផ្លូវចិត្ត
- ក្នុងរយៈពេល 48 ម៉ោង
  ប្រសិនបើអ្នកស្នើសុំសេវាកម្មសម្រាប់ស្ថានភាពបន្ទាន់ដែលមិនតម្រូវឱ្យមានការអនុ
  ញ្ញាតជាមុន
- ក្នុងរយៈពេល 96 ម៉ោងនៃស្ថានភាពបន្ទាន់ដែលតម្រូវឱ្យមានការអនុញ្ញាតជាមុន
- ក្នុងរយៈពេល 15 ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃស្នើសុំមិនបន្ទាន់របស់អ្នក

សម្រាប់ការណាត់ជួបជាមួយគ្រូពេទ្យឯកទេសជំងឺផ្លូវចិត្ត និង

- ក្នុងរយៈពេល 10 ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃណាត់ជួបមុន
  សម្រាប់ការណាត់ជួបតាមដានមិនបន្ទាន់សម្រាប់ស្ថានភាពដែលកំពុងបន្ត។

សម្រាប់សេវាកម្មវិបត្តិប្រើប្រាស់សារធាតុញៀន ខោនធីត្រូវតែផ្តល់ជូនអ្នកនូវការណាត់ជួប៖

- ក្នុងរយៈពេល 10 ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃស្នើសុំមិនបន្ទាន់របស់អ្នក
  ដើម្បីចាប់ផ្តើមសេវាកម្មជាមួយអ្នកផ្តល់សេវាព្យាបាលវិបត្តិប្រើប្រាស់សារធាតុញៀន
  សម្រាប់សេវាអ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យ និងសេវាអ្នកជំងឺក្រៅដែលស៊ីជម្រៅ
- ក្នុងរយៈពេល 48 ម៉ោង
  ប្រសិនបើអ្នកស្នើសុំសេវាកម្មសម្រាប់ស្ថានភាពបន្ទាន់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត
  ជាមុន
- ក្នុងរយៈពេល 96 ម៉ោង ប្រសិនបើស្ថានភាពបន្ទាន់តម្រូវឱ្យមានការអនុញ្ញាតជាមុន
- ក្នុងរយៈពេល 3 ថ្ងៃធ្វើការ គិតចាប់ពីថ្ងៃស្នើសុំសេវាកម្មកម្មវិធីព្យាបាលការញៀន
- ការណាត់ជួបតាមដានមិនបន្ទាន់ក្នុងរយៈពេល 10 ថ្ងៃ
  ប្រសិនបើអ្នកកំពុងទទួលការព្យាបាលសម្រាប់វិបត្តិប្រើប្រាស់សារធាតុញៀនដែលកំពុង
  បន្ត លើកលែងតែករណីមួយចំនួនដែលកំណត់ដោយអ្នកផ្តល់សេវាព្យាបាលរបស់អ្នក។

ទោះជាយ៉ាងណា ពេលវេលាទាំងនេះអាចយូរជាងនេះ
ប្រសិនបើអ្នកផ្តល់សេវារបស់អ្នកបានកំណត់ថា
ពេលវេលារង់ចាំយូរជាងនេះគឺសមស្របតាមផ្នែកវេជ្ជសាស្ត្រ
ហើយមិនបង្កគ្រោះថ្នាក់ដល់សុខភាពរបស់អ្នក។ ប្រសិនបើអ្នកត្រូវបានគេប្រាប់ថា
អ្នកត្រូវបានដាក់ក្នុងបញ្ជីរង់ចាំ
ហើយមានអារម្មណ៍ថារយៈពេលនេះបង្កគ្រោះថ្នាក់ដល់សុខភាពរបស់អ្នក
សូមទាក់ទងខោនធីរបស់អ្នកតាមលេខទូរសព្ទដែលមានរាយនៅលើគម្របសៀវភៅណែនាំនេះ។
អ្នកមានសិទ្ធិដាក់ពាក្យបណ្តឹង ប្រសិនបើអ្នកមិនទទួលបានការថែទាំទាន់ពេលវេលា។
សម្រាប់ព័ត៌មានបន្ថែមអំពីការដាក់ពាក្យបណ្តឹង សូមមើលផ្នែក "ដំណើរការប្តឹងផ្តល់"
នៃសៀវភៅណែនាំនេះ។

តើសេវាសង្គ្រោះបន្ទាន់មានអ្វីខ្លះ?

សេវាសង្គ្រោះបន្ទាន់

គឺជាសេវាកម្មសម្រាប់សមាជិកដែលកំពុងជួបប្រទះនឹងស្ថានភាពវេជ្ជសាស្ត្រដែលមិននឹកស្មានដ
ល់ រួមទាំងស្ថានភាពវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់ផ្នែកផ្លូវចិត្ត។

ស្ថានភាពវេជ្ជសាស្ត្រសង្គ្រោះបន្ទាន់មានរោគសញ្ញាធ្ងន់ធ្ងរខ្លាំង

(អាចរួមបញ្ចូលទាំងការឈឺចាប់ធ្ងន់ធ្ងរ)

ដែលមនុស្សជាមធ្យមអាចរំពឹងទុកបានយ៉ាងសមហេតុផលថារឿងដូចខាងក្រោមនេះអាចកើត
ឡើងនៅពេលណាមួយ៖

- សុខភាពរបស់បុគ្គលនោះ (ឬសុខភាពរបស់កូនដែលមិនទាន់កើត)
  អាចមានបញ្ហាធ្ងន់ធ្ងរ
- បង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ដំណើរការរបស់រាងកាយអ្នក
- បង្កការខូចខាតធ្ងន់ធ្ងរដល់សរីរាង្គ ឬផ្នែកណាមួយនៃរាងកាយ

ស្ថានភាពសង្គ្រោះបន្ទាន់ផ្លូវចិត្តកើតឡើងនៅពេលដែលមនុស្សជាមធ្យមគិតថានរណាម្នាក់៖

- មានគ្រោះថ្នាក់បច្ចុប្បន្នដល់ខ្លួនឯង ឬអ្នកដទៃ ដោយសារតែស្ថានភាពសុខភាពផ្លូវចិត្ត
  ឬសង្ឃឹមថាមានស្ថានភាពសុខភាពផ្លូវចិត្ត។
- មិនអាចផ្គត់ផ្គង់តម្រូវការរបស់ពួកគេភ្លាមៗ ដូចជា៖ អាហារ សម្លៀកបំពាក់ ជម្រក
  សុវត្ថិភាពផ្ទាល់ខ្លួន ឬទទួលបានការថែទាំសុខភាពចាំបាច់
  ដោយសារតែស្ថានភាពសុខភាពផ្លូវចិត្ត ឬសង្ឃឹមថាមានស្ថានភាពសុខភាពផ្លូវចិត្ត
  និង/ឬរបត្តិប្រើប្រាស់សារធាតុញៀនធ្ងន់ធ្ងរ។

សេវាសង្គ្រោះបន្ទាន់ត្រូវបានគ្របដណ្តប់ 24 ម៉ោងក្នុងមួយថ្ងៃ

ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍សម្រាប់សមាជិក Medi-Cal ។

ការអនុញ្ញាតជាមុនមិនត្រូវបានទាមទារសម្រាប់សេវាសង្គ្រោះបន្ទាន់ទេ។ កម្មវិធី Medi-Cal
នឹងគ្របដណ្តប់លើស្ថានភាពសង្គ្រោះបន្ទាន់

មិនថាស្ថានភាពនេះបណ្តាលមកពីសុខភាពរាងកាយ ឬស្ថានភាពសុខភាពផ្លូវចិត្ត (គំនិត
អារម្មណ៍ អាកប្បកិរិយាដែលជាប្រភពនៃភាពតានតឹង

និង/ឬភាពមិនប្រក្រតីទាក់ទងនឹងខ្លួនឯង ឬអ្នកដទៃ)។ ប្រសិនបើអ្នកបានចុះឈ្មោះក្នុង

Medi-Cal អ្នកនឹងមិនទទួលបានវិក្កយបត្រដើម្បីបង់ថ្លៃសម្រាប់ការទៅបន្ទប់សង្គ្រោះបន្ទាន់ទេ
ទោះបីជាវាប្រែជាមិនមែនជាអាសន្នក៏ដោយ។ ប្រសិនបើអ្នកគិតថាអ្នកកំពុងមានអាសន្ន
សូមទូរសព្ទទៅ **911** ឬទៅមន្ទីរពេទ្យ ឬកន្លែងផ្សេងទៀតសម្រាប់ជំនួយ។

តើអ្នកណាជាអ្នកសម្រេចចិត្តថាខ្ញុំនឹងទទួលបានសេវាកម្មអ្វីខ្លះ?

អ្នក អ្នកផ្តល់សេវារបស់អ្នក និងខោនធី
សុទ្ធតែចូលរួមក្នុងការសម្រេចចិត្តថាតើសេវាកម្មអ្វីខ្លះដែលអ្នកត្រូវទទួល។
អ្នកជំនាញសុខភាពផ្លូវចិត្តនឹងនិយាយជាមួយអ្នក
ហើយនឹងជួយកំណត់ថាតើសេវាកម្មប្រភេទណាដែលត្រូវការ។

អ្នកមិនចាំបាច់ដឹងថាតើអ្នកមានរោគវិនិច្ឆ័យសុខភាពអាកប្បកិរិយា
ឬស្ថានភាពសុខភាពអាកប្បកិរិយាជាក់លាក់ណាមួយដើម្បីស្នើសុំជំនួយនោះទេ។
អ្នកនឹងអាចទទួលបានសេវាកម្មមួយចំនួន
ខណៈពេលដែលអ្នកផ្តល់សេវារបស់អ្នកបំពេញការវាយតម្លៃ។

ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ
អ្នកក៏អាចអាចទទួលបានសេវាសុខភាពអាកប្បកិរិយាផងដែរ
ប្រសិនបើអ្នកមានបញ្ហាសុខភាពផ្លូវចិត្តដោយសារតែរបួសផ្លូវចិត្ត
ការចូលរួមក្នុងប្រព័ន្ធសុខុមាលភាពកុមារ ការចូលរួមក្នុងយុត្តិធម៌អនីតិជន
ឬភាពគ្មានផ្ទះសម្បែង។ លើសពីនេះ ប្រសិនបើអ្នកមានអាយុក្រោម 21 ឆ្នាំ
ខោនធីត្រូវតែផ្តល់សេវាកម្មចាំបាច់ផ្នែកវេជ្ជសាស្ត្រដើម្បីជួយដល់ស្ថានភាពសុខភាពអាកប្ប
កិរិយារបស់អ្នក។ សេវាកម្មដែលរក្សា គាំទ្រ កែលម្អ
ឬធ្វើឱ្យស្ថានភាពសុខភាពផ្លូវចិត្តកាន់តែអាចទ្រាំទ្របាន
ត្រូវបានចាត់ទុកថាចាំបាច់ផ្នែកវេជ្ជសាស្ត្រ។

សេវាកម្មមួយចំនួនអាចតម្រូវឱ្យមានការអនុញ្ញាតជាមុនពីខោនធី។
សេវាកម្មដែលតម្រូវឱ្យមានការអនុញ្ញាតជាមុនរួមមាន សេវាកម្មនៅផ្ទះដែលស៊ីជម្រៅ
ការព្យាបាលដែលស៊ីជម្រៅនៅពេលថ្ងៃ ការស្តារនីតិសម្បទានៅពេលថ្ងៃ
សេវាព្យាបាលអាកប្បកិរិយា ការថែទាំចិញ្ចឹមព្យាបាល
និងសេវាស្នាក់នៅសម្រាប់អ្នកជំងឺដែលមានរបិត្តិប្រើប្រាស់សារធាតុញៀន។
សូមទូរសព្ទទៅខោនធីរបស់អ្នកដោយប្រើលេខទូរសព្ទនៅលើគម្របសៀវភៅណែនាំនេះ
ដើម្បីស្នើសុំព័ត៌មានបន្ថែម។

ដំណើរការអនុញ្ញាតរបស់ខោនធីត្រូវតែអនុវត្តតាមពេលវេលាជាក់លាក់។

- សម្រាប់ការអនុញ្ញាតសម្រាប់របិត្តិប្រើប្រាស់សារធាតុញៀនតាមស្តង់ដារ

ខោនធីត្រូវតែសម្រេចចិត្តលើសំណើរបស់អ្នកផ្តល់សេវារបស់អ្នកក្នុងរយៈពេលប្រាំ (5) ថ្ងៃធ្វើការ។

- ប្រសិនបើអ្នក ឬអ្នកផ្តល់សេវារបស់អ្នកស្នើសុំ ឬប្រសិនបើខោនធីគិតថាវាស្ថិតនៅក្នុងផលប្រយោជន៍របស់អ្នកក្នុងការទទួលបានព័ត៌មានបន្ថែមពីអ្នកផ្តល់ សេវារបស់អ្នក ពេលវេលាកំណត់អាចត្រូវបានពន្យារពេលរហូតដល់ 14 ថ្ងៃធ្វើការទៀត។ ឧទាហរណ៍នៃពេលដែលការពន្យារពេលអាចជាផលប្រយោជន៍របស់អ្នកគឺនៅពេលដែលខោនធីគិតថាខ្លួនអាចយល់ព្រមសំណើសុំការអនុញ្ញាតរបស់អ្នកផ្តល់សេវារបស់អ្នក ប្រសិនបើខោនធីមានព័ត៌មានបន្ថែមពីអ្នកផ្តល់សេវារបស់អ្នក ហើយនឹងត្រូវបដិសេធសំណើដោយគ្មានព័ត៌មាន។ ប្រសិនបើខោនធីពន្យារពេលពេលវេលាកំណត់ ខោនធីនឹងផ្ញើការជូនដំណឹងជាលាយលក្ខណ៍អក្សរពីការពន្យារពេល។

- សម្រាប់ការអនុញ្ញាតលើសុខភាពផ្លូវចិត្តជាមុនស្តង់ដារ ខោនធីត្រូវតែសម្រេចចិត្តដោយផ្អែកលើសំណើរបស់អ្នកផ្តល់សេវារបស់អ្នកឱ្យបានឆាប់រហ័សតាមដែលស្ថានភាពរបស់អ្នកតម្រូវ ប៉ុន្តែមិនលើសពីប្រាំ (5) ថ្ងៃធ្វើការគិតចាប់ពីពេលដែលខោនធីទទួលបានសំណើ។
  - ឧទាហរណ៍ ប្រសិនបើការអនុវត្តតាមពេលវេលាស្តង់ដារអាចធ្វើឱ្យប៉ះពាល់ដល់អាយុជីវិត សុខភាព ឬសមត្ថភាពក្នុងការសម្រេចបាន រក្សា ឬទទួលបានមុខងារអតិបរមារបស់អ្នក ខោនធីរបស់អ្នកត្រូវតែប្រញាប់ប្រញាល់ធ្វើការសម្រេចចិត្តលើការអនុញ្ញាត និងផ្តល់ការជូនដំណឹងដោយផ្អែកលើពេលវេលាដែលទាក់ទងនឹងស្ថានភាពសុខភាពរបស់អ្នក ដែលមិនលើសពី 72 ម៉ោងបន្ទាប់ពីទទួលបានសំណើសេវាកម្ម។ ខោនធីរបស់អ្នកអាចពន្យារពេលរហូតដល់ 14 ថ្ងៃធ្វើការបន្ថែមបន្ទាប់ពីខោនធីទទួលបានសំណើ ប្រសិនបើអ្នក

ឬអ្នកផ្តល់សេវារបស់អ្នកស្នើសុំការពន្យារពេល
ឬខោនធីផ្តល់ហេតុផលសម្រាប់មូលហេតុដែលការពន្យារពេលនេះគឺស្ថិតនៅក្នុងផ
លប្រយោជន៍ល្អបំផុតរបស់អ្នក។

ក្នុងករណីទាំងពីរ ប្រសិនបើខោនធីពន្យារពេលសម្រាប់សំណើសុំការអនុញ្ញាតរបស់អ្នកផ្តល់សេវា
ខោនធីនឹងផ្ញើការជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការពន្យារពេល។
ប្រសិនបើខោនធីមិនធ្វើការសម្រេចចិត្តក្នុងរយៈពេលដែលបានរាយបញ្ជី ឬបដិសេធ
ពន្យារពេល កាត់បន្ថយ ឬបញ្ចប់សេវាកម្មដែលបានស្នើសុំ
ខោនធីត្រូវតែផ្ញើការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផលដល់អ្នក
ដោយប្រាប់អ្នកថាសេវាកម្មទាំងនោះត្រូវបានបដិសេធ ពន្យារពេល កាត់បន្ថយ ឬបញ្ចប់
ជូនដំណឹងដល់អ្នកថាអ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍
និងផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីរបៀបដាក់ពាក្យបណ្តឹងឧទ្ធរណ៍។

អ្នកអាចស្នើសុំព័ត៌មានបន្ថែមពីខោនធីអំពីដំណើរការអនុញ្ញាតរបស់ខោនធីបាន។

ប្រសិនបើអ្នកមិនយល់ស្របនឹងការសម្រេចចិត្តរបស់ខោនធីលើដំណើរការអនុញ្ញាតទេ
អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍។ សម្រាប់ព័ត៌មានបន្ថែម សូមមើលផ្នែក
"ការដោះស្រាយបញ្ហា" នៃសៀវភៅណែនាំនេះ។

តើភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រជាអ្វី?

សេវាកម្មដែលអ្នកទទួលបានត្រូវតែចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងសមស្របផ្នែកគ្លីនិក
ដើម្បីដោះស្រាយស្ថានភាពរបស់អ្នក។ សម្រាប់សមាជិកដែលមានអាយុ 21 ឆ្នាំឡើងទៅ
សេវាកម្មគឺចាំបាច់ផ្នែកវេជ្ជសាស្ត្រ នៅពេលដែលវាសមហេតុផល និងចាំបាច់
ដើម្បីការពារជីវិតរបស់អ្នក ការពារជំងឺធ្ងន់ធ្ងរ ឬពិការភាព
ឬធ្វើអោយប្រសើរឡើងនូវការឈឺចាប់ធ្ងន់ធ្ងរ។

សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ
សេវាកម្មមួយត្រូវបានចាត់ទុកថាចាំបាច់ផ្នែកវេជ្ជសាស្ត្រ ប្រសិនបើវាកែតម្រូវ រក្សា គាំទ្រ
ធ្វើអោយប្រសើរឡើង ឬធ្វើឱ្យស្ថានភាពសុខភាពអាកប្បកិរិយាកាន់តែអាចទ្រាំទ្របាន។
សេវាកម្មដែលរក្សា គាំទ្រ ធ្វើអោយប្រសើរឡើង

ឬធ្វើឱ្យស្ថានភាពសុខភាពអាកប្បកិរិយាកាន់តែអាចទ្រាំទ្របាន
ត្រូវបានចាត់ទុកថាចាំបាច់ផ្នែកវេជ្ជសាស្ត្រ
និងត្រូវបានគ្របដណ្តប់ជាសេវាកម្មការត្រួតពិនិត្យដំបូង និងតាមកាលកំណត់
ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល។

តើខ្ញុំអាចទទួលបានសេវាសុខភាពផ្លូវចិត្តផ្សេងទៀតដែលមិនត្រូវបានគ្របដណ្តប់ដោយខោនធីដោយរបៀបណា?

ប្រសិនបើអ្នកបានចុះឈ្មោះក្នុងផែនការថែទាំដែលគ្រប់គ្រង
អ្នកអាចចូលប្រើប្រាស់សេវាសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យដូចខាង
ក្រោមតាមរយៈផែនការថែទាំដែលបានគ្រប់គ្រងរបស់អ្នក៖

- ការវាយតម្លៃ និងការព្យាបាលសុខភាពផ្លូវចិត្ត រួមទាំងការព្យាបាលជាលក្ខណៈបុគ្គល ក្រុម និងគ្រួសារ។
- ការធ្វើតេស្តផ្លូវចិត្ត និងសរសៃប្រសាទ នៅពេលដែលត្រូវបានចង្អុលបង្ហាញតាមគ្លីនិក ដើម្បីវាយតម្លៃស្ថានភាពសុខភាពផ្លូវចិត្ត។
- សេវាអ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យសម្រាប់ការតាមដានការប្រើថ្នាំពេទ្យតាមវេជ្ជបញ្ជា។
- ការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រ។

ដើម្បីទទួលបានសេវាកម្មណាមួយខាងលើ
សូមទូរសព្ទទៅផែនការថែទាំដែលគ្រប់គ្រងរបស់អ្នកដោយផ្ទាល់។
ប្រសិនបើអ្នកមិនស្ថិតនៅក្នុងផែនការថែទាំដែលគ្រប់គ្រងទេ
អ្នកប្រហែលជាអាចទទួលបានសេវាកម្មទាំងនេះពីអ្នកផ្តល់សេវា
និងគ្លីនិកនីមួយៗដែលទទួលយក Medi-Cal ។
ខោនធីប្រហែលជាអាចជួយអ្នកស្វែងរកអ្នកផ្តល់សេវា ឬគ្លីនិក។

កន្លែងលក់ថ្នាំពេទ្យណាមួយដែលទទួលយក Medi-Cal
អាចបំពេញវេជ្ជបញ្ជាដើម្បីព្យាបាលស្ថានភាពសុខភាពផ្លូវចិត្តបាន។
សូមចំណាំថាថ្នាំតាមវេជ្ជបញ្ជាភាគច្រើនដែលចែកចាយដោយកន្លែងលក់ថ្នាំពេទ្យ

ដែលមានឈ្មោះថា Medi-Cal Rx ត្រូវបានគ្របដណ្តប់ក្រោមកម្មវិធី Medi-Cal តម្លៃសម្រាប់សេវា
មិនមែនផែនការថែទាំដែលគ្រប់គ្រងរបស់អ្នកទេ។

តើមានសេវាកម្មវិបត្តិប្រើប្រាស់សារធាតុអ្វីទៀតដែលមានពីផែនការថែទាំដែលគ្រប់គ្រង ឬ កម្មវិធី "តម្លៃសម្រាប់សេវា" របស់ Medi-Cal?

ផែនការថែទាំដែលបានគ្រប់គ្រងត្រូវតែផ្តល់សេវាកម្មដែលគ្របដណ្តប់លើវិបត្តិប្រើប្រាស់សារធាតុញៀននៅក្នុងកន្លែងថែទាំបឋម និងការត្រួតពិនិត្យថ្នាំជក់ គ្រឿងស្រវឹង
និងគ្រឿងញៀនខុសច្បាប់។
ផែនការទាំងនោះក៏ត្រូវតែគ្របដណ្តប់លើសេវាកម្មដែលគ្របដណ្តប់លើវិបត្តិប្រើប្រាស់សារធាតុញៀនសម្រាប់សមាជិកមានផ្ទៃពោះ និងការត្រួតពិនិត្យការប្រើប្រាស់គ្រឿងស្រវឹង
និងគ្រឿងញៀន ការវាយតម្លៃ អន្តរាគមន៍រយៈពេលខ្លី
និងការបញ្ជូនទៅកន្លែងព្យាបាលសមស្របសម្រាប់សមាជិកដែលមានអាយុចាប់ពី 11 ឆ្នាំឡើង។
ផែនការថែទាំដែលបានគ្រប់គ្រងត្រូវតែផ្តល់
ឬរៀបចំសេវាកម្មសម្រាប់ការប្រើថ្នាំពេទ្យសម្រាប់ព្យាបាលការញៀន
(ត្រូវបានគេស្គាល់ផងដែរថាជាការព្យាបាលដោយមានជំនួយពីការប្រើថ្នាំពេទ្យ)
ដែលផ្តល់ជូននៅក្នុងកន្លែងថែទាំបឋម មន្ទីរពេទ្យសម្រាប់អ្នកជំងឺសម្រាកព្យាបាល
ផ្នែកសង្គ្រោះបន្ទាន់ និងកន្លែងថែទាំវេជ្ជសាស្ត្រដែលមានកិច្ចសន្យាផ្សេងទៀត។
ផែនការថែទាំដែលបានគ្រប់គ្រងក៏ត្រូវតែផ្តល់សេវាកម្មសង្គ្រោះបន្ទាន់ចាំបាច់ដើម្បីធ្វើឱ្យសមាជិកមានស្ថេរភាពផងដែរ
រួមទាំងការបន្សាបជាតិពុលដោយស្ម័គ្រចិត្តសម្រាប់អ្នកជំងឺសម្រាកព្យាបាល។

តើខ្ញុំអាចទទួលសេវាកម្ម Medi-Cal ផ្សេងទៀត (ការថែទាំបឋម/ Medi-Cal) យ៉ាងដូចម្តេច?

ប្រសិនបើអ្នកស្ថិតនៅក្នុងផែនការថែទាំដែលគ្រប់គ្រងបាន
ខោនធីទទួលខុសត្រូវក្នុងការស្វែងរកអ្នកផ្តល់សេវាសម្រាប់អ្នក។
ប្រសិនបើអ្នកមិនបានចុះឈ្មោះក្នុងផែនការថែទាំដែលគ្រប់គ្រង ហើយមាន Medi-Cal "ធម្មតា"
ដែលត្រូវបានគេហៅថា Medi-Cal តម្លៃសម្រាប់សេវា
នោះអ្នកអាចទៅរកអ្នកផ្តល់សេវាណាមួយដែលទទួលយក Medi-Cal ។

អ្នកត្រូវតែប្រាប់អ្នកផ្តល់សេវារបស់អ្នកថាអ្នកមាន Medi-Cal
មុនពេលអ្នកចាប់ផ្តើមទទួលបានសេវាកម្ម។ បើមិនដូច្នោះទេ
អ្នកអាចនឹងត្រូវបានគិតប្រាក់សម្រាប់សេវាកម្មទាំងនោះ។
អ្នកអាចប្រើប្រាស់អ្នកផ្តល់សេវានៅខាងក្រៅផែនការថែទាំដែលគ្រប់គ្រងរបស់អ្នកសម្រាប់សេវាកម្មផែនការគ្រួសារ។

ហេតុអ្វីបានជាខ្ញុំអាចត្រូវការសេវាព្យាបាលផ្លូវចិត្តសម្រាកនៅមន្ទីរពេទ្យ?

អ្នកអាចនឹងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យ ប្រសិនបើអ្នកមានបញ្ហាសុខភាពផ្លូវចិត្ត
ឬសញ្ញានៃបញ្ហាសុខភាពផ្លូវចិត្តដែលមិនអាចព្យាបាលបានដោយសុវត្ថិភាពនៅកម្រិតថែទាំទាបជាង ហើយដោយសារតែស្ថានភាពសុខភាពផ្លូវចិត្ត ឬរោគសញ្ញានៃបញ្ហាសុខភាពផ្លូវចិត្ត អ្នក៖

- តំណាងឱ្យគ្រោះថ្នាក់ដល់ខ្លួនអ្នក អ្នកដទៃ ឬទ្រព្យសម្បត្តិ។
- មិនអាចថែទាំខ្លួនឯងជាមួយនឹងអាហារ សម្លៀកបំពាក់ ជម្រក
  សុវត្ថិភាពផ្ទាល់ខ្លួន ឬការថែទាំសុខភាពចាំបាច់។
- ប្រឈមនឹងហានិភ័យធ្ងន់ធ្ងរដល់សុខភាពរាងកាយរបស់អ្នក។
- មានការធ្លាក់ចុះគួរឱ្យកត់សម្គាល់នៃសមត្ថភាពក្នុងការបំពេញមុខងារថ្មីៗនេះ
  ដែលជាលទ្ធផលនៃស្ថានភាពសុខភាពផ្លូវចិត្ត។
- ត្រូវការការវាយតម្លៃផ្លូវចិត្ត ការព្យាបាលដោយថ្នាំ
  ឬការព្យាបាលផ្សេងទៀតដែលអាចផ្តល់ជូនបានតែនៅក្នុងមន្ទីរពេទ្យប៉ុណ្ណោះ។

ការជ្រើសរើសអ្នកផ្តល់សេវា

តើខ្ញុំត្រូវរកអ្នកផ្តល់សេវាសម្រាប់សេវាសុខភាពអាកប្បកិរិយាដែលខ្ញុំត្រូវការដោយរបៀបណា?

ខោនធីរបស់អ្នកត្រូវបានតម្រូវឱ្យបង្ហោះបញ្ជីអ្នកផ្តល់សេវាបច្ចុប្បន្នតាមអ៊ីនធឺណិត។
អ្នកអាចស្វែងរកតំណបញ្ជីអ្នកផ្តល់សេវានៅក្នុងផ្នែកទំនាក់ទំនងខោនធីនៃសៀវភៅណែនាំនេះ។
បញ្ជីនេះមានព័ត៌មានអំពីទីតាំងរបស់អ្នកផ្តល់សេវា សេវាកម្មដែលពួកគេផ្តល់ជូន

និងព័ត៌មានផ្សេងទៀតដើម្បីជួយអ្នកឱ្យទទួលបានការថែទាំ
រួមទាំងព័ត៌មានអំពីសេវាកម្មវប្បធម៌ និងភាសាដែលមានពីអ្នកផ្តល់សេវា។

ប្រសិនបើអ្នកមានសំណួរអំពីអ្នកផ្តល់សេវាបច្ចុប្បន្ន
ឬចង់បានបញ្ជីអ្នកផ្តល់សេវាដែលបានធ្វើបច្ចុប្បន្នភាព
សូមចូលទៅកាន់គេហទំព័ររបស់ខោនធីរបស់អ្នក
ឬប្រើប្រាស់លេខទូរសព្ទដែលមាននៅលើគម្របសៀវភៅណែនាំនេះ។
អ្នកអាចទទួលបានបញ្ជីអ្នកផ្តល់សេវាជាលាយលក្ខណ៍អក្សរ ឬតាមប្រៃសណីយ៍
ប្រសិនបើអ្នកស្នើសុំ។

សូមចំណាំ៖
ខោនធីអាចដាក់កម្រិតមួយចំនួនលើជម្រើសរបស់អ្នកនៃអ្នកផ្តល់សេវាសុខភាពផ្លូវចិត្ត។
នៅពេលអ្នកចាប់ផ្តើមទទួលបានសេវាសុខភាពផ្លូវចិត្តដំបូង
អ្នកអាចស្នើសុំឱ្យខោនធីរបស់អ្នកផ្តល់ឱ្យអ្នកនូវជម្រើសដំបូងយ៉ាងហោចណាស់អ្នកផ្តល់សេវាពីរ។
ខោនធីរបស់អ្នកក៏ត្រូវតែអនុញ្ញាតឱ្យអ្នកផ្លាស់ប្តូរអ្នកផ្តល់សេវាផងដែរ។
ប្រសិនបើអ្នកស្នើសុំផ្លាស់ប្តូរអ្នកផ្តល់សេវា
ខោនធីត្រូវតែអនុញ្ញាតឱ្យអ្នកជ្រើសរើសរវាងអ្នកផ្តល់សេវាយ៉ាងហោចណាស់ពីរនាក់នៅពេលដែលអាចធ្វើទៅបាន។
ខោនធីរបស់អ្នកទទួលខុសត្រូវក្នុងការធានាថាអ្នកមានសិទ្ធិទទួលបានការថែទាំទាន់ពេលវេលា
និងថាមានអ្នកផ្តល់សេវាគ្រប់គ្រាន់នៅជិតអ្នក
ដើម្បីធានាថាអ្នកអាចទទួលបានសេវាសុខភាពផ្លូវចិត្តដែលគ្របដណ្តប់ ប្រសិនបើអ្នកត្រូវការ។

ពេលខ្លះអ្នកផ្តល់សេវាដែលមានកិច្ចសន្យារបស់ខោនធីជ្រើសរើសលែងផ្តល់សេវាសុខភាពអាកប្បកិរិយាទៀតហើយ ពីព្រោះពួកគេអាចនឹងលែងចុះកិច្ចសន្យាជាមួយខោនធី ឬលែងទទួលយក Medi-Cal ។ នៅពេលដែលរឿងនេះកើតឡើង
ខោនធីត្រូវតែខិតខំប្រឹងប្រែងដោយពិតប្រាកដក្នុងការផ្តល់ការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់មនុស្សម្នាក់ៗដែលកំពុងទទួលសេវាកម្មពីអ្នកផ្តល់សេវា។

អ្នកត្រូវបានតម្រូវឱ្យទទួលបានការជូនដំណឹង 30
ថ្ងៃធ្វើការមុនកាលបរិច្ឆេទមានប្រសិទ្ធភាពនៃការបញ្ចប់ ឬ 15
ថ្ងៃធ្វើការបន្ទាប់ពីខោនធីដឹងថាអ្នកផ្តល់សេវានឹងឈប់ធ្វើការ។
នៅពេលដែលរឿងនេះកើតឡើង
ខោនធីរបស់អ្នកត្រូវតែអនុញ្ញាតឱ្យអ្នកបន្តទទួលសេវាកម្មពីអ្នកផ្តល់សេវាដែលបានចាកចេញពី
ខោនធី ប្រសិនបើអ្នក និងអ្នកផ្តល់សេវាយល់ព្រម។ នេះត្រូវបានគេហៅថា "ការបន្តការថែទាំ"
ហើយត្រូវបានពន្យល់ខាងក្រោម។
សូមចំណាំ៖ បុគ្គលជនជាតិអាមេរិកាំងឥណ្ឌា និងជនជាតិដើមអាឡាស្កា
ដែលមានសិទ្ធិទទួលបាន Medi-Cal
និងរស់នៅក្នុងខោនធីដែលបានជ្រើសរើសចូលរួមក្នុងប្រព័ន្ធព្យាបាល
រិបត្តប្រើប្រាស់ថ្នាំរៀបចំដោយ Medi-Cal ក៏អាចទទួលបានសេវាកម្មប្រព័ន្ធព្យាបាល
រិបត្តប្រើប្រាស់ថ្នាំរៀបចំដោយ Medi-Cal តាមរយៈអ្នកផ្តល់សេវាថែទាំសុខភាពឥណ្ឌាផងដែរ។

តើខ្ញុំអាចបន្តទទួលបានសេវាសុខភាពផ្លូវចិត្តពិសេសពីអ្នកផ្តល់សេវាបច្ចុប្បន្នរបស់ខ្ញុំបានទេ?
ប្រសិនបើអ្នកកំពុងទទួលបានសេវាសុខភាពផ្លូវចិត្តពីផែនការថែទាំដែលបានគ្រប់គ្រងរួចហើ
យ អ្នកអាចបន្តទទួលបានការថែទាំពីអ្នកផ្តល់សេវានោះ
ទោះបីជាអ្នកទទួលបានសេវាសុខភាពផ្លូវចិត្តពីអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តរបស់អ្នកក៏ដោយ
ដរាបណាសេវាកម្មត្រូវបានសម្របសម្រួលរវាងអ្នកផ្តល់សេវា
ហើយសេវាកម្មទាំងនោះមិនដូចគ្នាទេ។

លើសពីនេះ ប្រសិនបើអ្នកកំពុងទទួលបានសេវាកម្មពីផែនការសុខភាពផ្លូវចិត្តផ្សេងទៀត
ផែនការថែទាំដែលបានគ្រប់គ្រង ឬអ្នកផ្តល់សេវា Medi-Cal ម្នាក់ៗរួចហើយ អ្នកអាចស្នើសុំ
"ការបន្តការថែទាំ" ដើម្បីឱ្យអ្នកអាចស្នាក់នៅជាមួយអ្នកផ្តល់សេវាបច្ចុប្បន្នរបស់អ្នករហូតដល់
12 ខែ។ អ្នកប្រហែលជាចង់ស្នើសុំការបន្តការថែទាំ
ប្រសិនបើអ្នកត្រូវការស្នាក់នៅជាមួយអ្នកផ្តល់សេវាបច្ចុប្បន្នរបស់អ្នកដើម្បីបន្តការព្យាបាលដែល
កំពុងបន្តរបស់អ្នក
ឬដោយសារតែវានឹងបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់ស្ថានភាពសុខភាពផ្លូវចិត្តរបស់អ្នកក្នុងការផ្លាស់

ប្តូរទៅអ្នកផ្តល់សេវាថ្មី។ សំណើសុំការថែទាំបន្តរបស់អ្នកអាចត្រូវបានអនុញ្ញាត
ប្រសិនបើចំណុចខាងក្រោមនេះជាការពិត៖

- អ្នកមានទំនាក់ទំនងជាប់លាប់ជាមួយអ្នកផ្តល់សេវាដែលអ្នកកំពុងស្នើសុំ
  ហើយបានជួបអ្នកផ្តល់សេវានោះក្នុងរយៈពេល 12 ខែចុងក្រោយនេះ។
- អ្នកត្រូវស្នាក់នៅជាមួយអ្នកផ្តល់សេវាបច្ចុប្បន្នរបស់អ្នក
  ដើម្បីបន្តការព្យាបាលជាបន្តបន្ទាប់ដើម្បីការពារការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់
  សមាជិក ឬកាត់បន្ថយហានិភ័យនៃការសម្រាកព្យាបាលនៅមន្ទីរពេទ្យ
  ឬការត្រូវសម្រាកព្យាបាលនៅមួយកន្លែង។
- អ្នកផ្តល់សេវាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងបំពេញតាមតម្រូវការរបស់ Medi-Cal
- អ្នកផ្តល់សេវាយល់ព្រមតាមតម្រូវការរបស់ផែនការសុខភាពផ្លូវចិត្តសម្រាប់ការចុះកិច្ចស
  ន្យាជាមួយផែនការសុខភាពផ្លូវចិត្ត និងការបង់ប្រាក់សម្រាប់សេវាកម្ម។ និង
- អ្នកផ្តល់សេវាចែករំលែកឯកសារពាក់ព័ន្ធជាមួយខោនធីទាក់ទងនឹងតម្រូវការរបស់អ្នក
  សម្រាប់សេវាកម្ម។

**តើខ្ញុំអាចបន្តទទួលបានសេវាកម្មសម្រាប់វិបត្តិប្រើប្រាស់សារធាតុញៀនពីអ្នកផ្តល់សេវាបច្ចុប្បន្ន
របស់ខ្ញុំបានទេ?**

អ្នកអាចស្នើសុំរក្សាអ្នកផ្តល់សេវាក្រៅបណ្តាញរបស់អ្នកសម្រាប់រយៈពេលមួយប្រសិនបើ៖

- អ្នកមានទំនាក់ទំនងជាបន្តបន្ទាប់ជាមួយអ្នកផ្តល់សេវាដែលអ្នកកំពុងស្នើសុំ
  ហើយបានជួបអ្នកផ្តល់សេវានោះមុនកាលបរិច្ឆេទនៃការផ្លាស់ប្តូររបស់អ្នកទៅកាន់ខោន
  ធីនៃប្រព័ន្ធព្យាបាលវិបត្តប្រើប្រាស់ថ្នាំរៀបចំដោយ Medi-Cal ។
- អ្នកត្រូវនៅជាមួយអ្នកផ្តល់សេវាបច្ចុប្បន្នរបស់អ្នក ដើម្បីបន្តការព្យាបាលជាបន្តបន្ទាប់
  ដើម្បីការពារការខូចខាតធ្ងន់ធ្ងរដល់សុខភាពសមាជិក
  ឬកាត់បន្ថយហានិភ័យនៃការសម្រាកព្យាបាលនៅមន្ទីរពេទ្យ
  ឬការត្រូវសម្រាកព្យាបាលនៅមួយកន្លែង។

សិទ្ធិរបស់អ្នកក្នុងការចូលមើលកំណត់ត្រាសុខភាពអាកប្បកិរិយា និងព័ត៌មានបញ្ជីអ្នកផ្តល់សេវាដោយប្រើប្រាស់ឧបករណ៍ឆ្លាតវៃ

អ្នកអាចចូលមើលកំណត់ត្រាសុខភាពអាកប្បកិរិយារបស់អ្នក
និង/ឬស្វែងរកអ្នកផ្តល់សេវាដោយប្រើកម្មវិធីដែលបានទាញយកនៅលើកុំព្យូទ័រ ថេប្លេតឆ្លាតវៃ ឬឧបករណ៍ចល័ត។
ខោនធើរបស់អ្នកអាចមានព័ត៌មានដែលមាននៅលើគេហទំព័ររបស់ពួកគេសម្រាប់អ្នកពិចារណាមុនពេលជ្រើសរើសកម្មវិធីដើម្បីទទួលបានព័ត៌មានរបស់អ្នកតាមវិធីនេះ។
សម្រាប់ព័ត៌មានបន្ថែមអំពីភាពអាចរកបាននៃការចូលមើលរបស់អ្នក
សូមទាក់ទងខោនធើរបស់អ្នកដោយយោងទៅលើផ្នែក "ព័ត៌មានទំនាក់ទំនងខោនធើ"
នៅក្នុងសៀវភៅណែនាំនេះ។

ទំហំនៃសេវាកម្ម

ប្រសិនបើអ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យសម្រាប់ការទទួលបានសេវាសុខភាពអាកប្បកិរិយា
សេវាកម្មដូចខាងក្រោមអាចរកបានសម្រាប់អ្នកដោយផ្អែកលើតម្រូវការរបស់អ្នក។
អ្នកផ្តល់សេវារបស់អ្នកនឹងធ្វើការជាមួយអ្នកដើម្បីសម្រេចថាតើសេវាកម្មណាដែលដំណើរការល្អ
បំផុតសម្រាប់អ្នក។

សេវាកម្មសុខភាពផ្លូវចិត្តពិសេស

សេវាកម្មសុខភាពផ្លូវចិត្ត

- សេវាសុខភាពផ្លូវចិត្ត គឺជាសេវាព្យាបាលដែលផ្អែកលើបុគ្គល ក្រុម ឬគ្រួសារ
  ដែលជួយមនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្ត
  ឱ្យអភិវឌ្ឍជំនាញដោះស្រាយសម្រាប់ការរស់នៅប្រចាំថ្ងៃ។
  សេវាទាំងនេះក៏រួមបញ្ចូលការងារដែលអ្នកផ្តល់សេវាធ្វើ
  ដើម្បីជួយធ្វើឱ្យសេវាកាន់តែប្រសើរឡើងសម្រាប់អ្នកដែលទទួលការថែទាំ។
  ចំណុចទាំងនេះរួមមាន ការវាយតម្លៃ ដើម្បីមើលថាតើអ្នកត្រូវការសេវានេះដែរឬទេ
  និងថាតើសេវានេះដំណើរការឬអត់។ ការធ្វើផែនការព្យាបាល
  ដើម្បីសម្រេចគោលដៅនៃការព្យាបាលសុខភាពផ្លូវចិត្តរបស់អ្នក
  និងសេវាជាក់លាក់ដែលនឹងត្រូវបានផ្តល់ជូន។ និង “ជំនួយស្របគ្នា” ដែលមានន័យថា
  ធ្វើការជាមួយសមាជិកគ្រួសារ និងមនុស្សសំខាន់ៗក្នុងជីវិតរបស់អ្នក
  (ប្រសិនបើអ្នកផ្តល់ការអនុញ្ញាត) ដើម្បីជួយអ្នកឱ្យកែលម្អ
  ឬរក្សាសមត្ថភាពរស់នៅប្រចាំថ្ងៃរបស់អ្នក។
- សេវាសុខភាពផ្លូវចិត្តអាចត្រូវបានផ្តល់ជូននៅក្នុងគ្លីនិក ឬការិយាល័យរបស់អ្នកផ្តល់
  សេវានៅផ្ទះរបស់អ្នក ឬនៅក្នុងសហគមន៍ផ្សេងទៀត តាមទូរសព្ទ
  ឬតាមរយៈការទំនាក់ទំនងតាមទូរសព្ទ (ដែលរួមបញ្ចូលទាំងអន្តរកម្មសំឡេង
  និងវីដេអូ)។ ខោនធី និងអ្នក
  ផ្តល់សេវានឹងធ្វើការជាមួយអ្នកដើម្បីកំណត់ភាពញឹកញាប់នៃសេវាកម្ម/ការណាត់ជួបរប

ស់អ្នក។

សេវាកម្មគាំទ្រការប្រើថ្នាំពេទ្យ

- សេវាកម្មទាំងនេះរួមមាន ការចេញវេជ្ជបញ្ជា ការផ្តល់ថ្នាំ ការចែកចាយ
  និងការត្រួតពិនិត្យថ្នាំពេទ្យផ្លូវចិត្ត។
  អ្នកផ្តល់សេវារបស់អ្នកក៏អាចផ្តល់ការអប់រំអំពីការប្រើថ្នាំពេទ្យផងដែរ។
  សេវាកម្មទាំងនេះអាចត្រូវបានផ្តល់ជូននៅក្នុងគ្លីនិក ការិយាល័យវេជ្ជបណ្ឌិត
  ផ្ទះរបស់អ្នក សហគមន៍ តាមទូរសព្ទ ឬតាមរយៈសុខភាពពីចម្ងាយ
  (ដែលរួមបញ្ចូលទាំងអន្តរកម្មសំឡេង និងវីដេអូ)។

ការគ្រប់គ្រងករណីគោលដៅ

- សេវាកម្មនេះជួយសមាជិកទទួលបានសេវាវេជ្ជសាស្ត្រ អប់រំ សង្គម សេវាមុនវិជ្ជាជីវៈ
  សេវាវិជ្ជាជីវៈ សេវាស្ថានីតិសម្បទា ឬសេវាសហគមន៍ផ្សេងទៀត
  នៅពេលដែលសេវាកម្មទាំងនេះអាចពិបាកសម្រាប់អ្នកដែលមានស្ថានភាពសុខភាពផ្លូវ
  ចិត្តក្នុងការរស់នៅដោយខ្លួនឯង។ ការគ្រប់គ្រងករណីគោលដៅរួមមាន
  ប៉ុន្តែមិនកំណត់ចំពោះ៖
  - ការអភិវឌ្ឍផែនការ
  - ការទំនាក់ទំនង ការសម្របសម្រួល និងការបញ្ជូនបន្ត
  - ការត្រួតពិនិត្យការផ្តល់សេវា ដើម្បីធានាបាននូវការចូលប្រើប្រាស់សេវាកម្ម
    និងប្រព័ន្ធផ្តល់សេវារបស់បុគ្គលនោះ និង
  - ការត្រួតពិនិត្យដំណើរការរបស់បុគ្គលនោះ។

សេវាផ្សាភ្ជាប់សម្រួលវិបត្តិ

- សេវាកម្មនេះអាចរកបានដើម្បីដោះស្រាយស្ថានភាពបន្ទាន់ដែលត្រូវការការយកចិត្តទុក
  ដាក់ជាបន្ទាន់។
  គោលដៅនៃការផ្សាភ្ជាប់សម្រួលវិបត្តិគឺដើម្បីជួយមនុស្សនៅក្នុងសហគមន៍ដើម្បីកុំឱ្យពួ
  កគេត្រូវទៅមន្ទីរពេទ្យ។ ការផ្សាភ្ជាប់សម្រួលវិបត្តិអាចមានរយៈពេលរហូតដល់ប្រាំបីម៉ោង
  ហើយអាចត្រូវបានផ្តល់ជូននៅក្នុងគ្លីនិក ឬការិយាល័យអ្នកផ្តល់សេវា

ឬនៅក្នុងផ្ទះរបស់អ្នក ឬនៅក្នុងសហគមន៍ផ្សេងទៀត។
សេវាកម្មទាំងនេះក៏អាចធ្វើឡើងតាមទូរសព្ទ ឬតាមកម្មវិធីសុខភាពពីចម្ងាយផងដែរ។

សេវាកម្មទប់ស្កាត់វិបត្តិ

- សេវាកម្មនេះអាចរកបានដើម្បីដោះស្រាយស្ថានភាពបន្ទាន់ដែលត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់។ ការធ្វើឱ្យស្ថិរភាពវិបត្តិមានរយៈពេលតិចជាង 24 ម៉ោង
ហើយត្រូវតែផ្តល់ជូននៅមណ្ឌលថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណបើក 24 ម៉ោង
នៅកម្មវិធីអ្នកជំងឺក្រៅដែលមានមូលដ្ឋាននៅមន្ទីរពេទ្យ
ឬនៅទីតាំងអ្នកផ្តល់សេវាដែលមានវិញ្ញាបនបត្រផ្តល់សេវាកម្មទាំងនេះ។

សេវាព្យាបាលមនុស្សពេញវ័យនៅមណ្ឌលថែទាំ

- សេវាកម្មទាំងនេះផ្តល់ការព្យាបាលសុខភាពផ្លូវចិត្តដល់អ្នកដែលមានស្ថានភាពសុខភាពផ្លូវចិត្តដែលរស់នៅក្នុងមណ្ឌលស្នាក់នៅដែលមានអាជ្ញាប័ណ្ណ។
ពួកគេជួយកសាងជំនាញសម្រាប់មនុស្ស
និងផ្តល់សេវាកម្មព្យាបាលសម្រាប់មនុស្សដែលមានស្ថានភាពសុខភាពផ្លូវចិត្ត។
សេវាកម្មទាំងនេះមាន 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ Medi-Cal
មិនរាប់រងថ្លៃបន្ទប់ និងថ្លៃអាហារសម្រាប់ការស្នាក់នៅក្នុងមណ្ឌលទាំងនេះទេ។

សេវាព្យាបាលវិបត្តិនៅមណ្ឌលថែទាំ

- សេវាកម្មទាំងនេះផ្តល់ការព្យាបាលសុខភាពផ្លូវចិត្ត
និងការកសាងជំនាញសម្រាប់អ្នកដែលមានវិបត្តិផ្លូវចិត្ត ឬអារម្មណ៍ធ្ងន់ធ្ងរ។
នេះមិនមែនសម្រាប់អ្នកដែលត្រូវការការថែទាំផ្លូវចិត្តនៅក្នុងមន្ទីរពេទ្យទេ។
សេវាកម្មមាននៅតាមមណ្ឌលដែលមានអាជ្ញាប័ណ្ណរយៈពេល 24 ម៉ោងក្នុងមួយថ្ងៃ
ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ Medi-Cal មិនរាប់រងថ្លៃបន្ទប់
និងថ្លៃអាហារសម្រាប់មណ្ឌលទាំងនេះទេ។

សេវាកម្មព្យាបាលពេលថ្ងៃស៊ីជម្រៅ

- នេះគឺជាកម្មវិធីព្យាបាលសុខភាពផ្លូវចិត្តដែលមានរចនាសម្ព័ន្ធ

ដែលផ្តល់ជូនក្រុមមនុស្ស ដែលបើមិនដូច្នោះទេ
អាចត្រូវការសម្រាកព្យាបាលនៅមន្ទីរពេទ្យ ឬមណ្ឌលថែទាំ 24 ម៉ោងផ្សេងទៀត។
កម្មវិធីនេះមានរយៈពេលបីម៉ោងក្នុងមួយថ្ងៃ។ វារួមបញ្ចូលទាំងការព្យាបាល
ការព្យាបាលចិត្តសាស្ត្រ និងសកម្មភាពកសាងជំនាញ។

ការស្តារនីតិសម្បទាពេលថ្ងៃ

- កម្មវិធីនេះមានគោលបំណងជួយមនុស្សដែលមានបញ្ហាសុខភាពផ្លូវចិត្តឱ្យរៀន
  និងអភិវឌ្ឍជំនាញដោះស្រាយ និងជំនាញជីវិត
  ដើម្បីគ្រប់គ្រងរោគសញ្ញារបស់ពួកគេបានកាន់តែប្រសើរ។
  កម្មវិធីនេះមានរយៈពេលយ៉ាងហោចណាស់បីម៉ោងក្នុងមួយថ្ងៃ។
  វារួមបញ្ចូលទាំងសកម្មភាពព្យាបាល និងកសាងជំនាញ។

សេវាកម្មសម្រាកព្យាបាលនៅមន្ទីរពេទ្យឯកទេសផ្លូវចិត្ត

- ទាំងនេះគឺជាសេវាកម្មដែលផ្តល់ជូននៅក្នុងមន្ទីរពេទ្យឯកទេសផ្លូវចិត្តដែលមានអាជ្ញាប័
  ណ្ណ។
  អ្នកជំនាញសុខភាពផ្លូវចិត្តដែលមានអាជ្ញាប័ណ្ណសម្រេចថាតើមនុស្សម្នាក់ត្រូវការការព្យា
  បាលយ៉ាងយកចិត្តទុកដាក់ 24
  ម៉ោងសម្រាប់ស្ថានភាពសុខភាពផ្លូវចិត្តរបស់ពួកគេឬអត់។
  ប្រសិនបើអ្នកជំនាញសម្រេចថាសមាជិកត្រូវការការព្យាបាល 24 ម៉ោង
  សមាជិកនោះត្រូវតែស្នាក់នៅក្នុងមន្ទីរពេទ្យ 24 ម៉ោងក្នុងមួយថ្ងៃ។

សេវាកម្មមណ្ឌលសុខភាពឯកទេសផ្លូវចិត្ត

- សេវាកម្មទាំងនេះត្រូវបានផ្តល់ជូននៅមណ្ឌលសុខភាពឯកទេសផ្លូវចិត្តដែលមានអាជ្ញា
  ប័ណ្ណ ដែលមានជំនាញក្នុងការព្យាបាលស្តារនីតិសម្បទា 24
  ម៉ោងនៃស្ថានភាពសុខភាពផ្លូវចិត្តធ្ងន់ធ្ងរ។
  មណ្ឌលសុខភាពផ្លូវចិត្តត្រូវតែមានកិច្ចព្រមព្រៀងជាមួយមន្ទីរពេទ្យ ឬ
  គ្លីនិកនៅក្បែរនោះ ដើម្បីបំពេញតម្រូវការថែទាំសុខភាពរាងកាយរបស់មនុស្សនៅក្នុង

មណ្ឌល។ មណ្ឌលសុខភាពឯកទេសផ្លូវចិត្តអាចទទួល
និងព្យាបាលតែអ្នកជំងឺដែលមិនមានជំងឺ
ឬរបួសរាងកាយដែលត្រូវការការព្យាបាលលើសពីអ្វីដែលជាធម្មតាអាចព្យាបាលបាននៅ
លើមូលដ្ឋានអ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យ។

សេវាព្យាបាលអាកប្បកិរិយា

សេវាព្យាបាលអាកប្បកិរិយា
គឺជាផ្សារភ្ជាប់ការព្យាបាលរយៈពេលខ្លីដ៏ស៊ីជម្រៅសម្រាប់សមាជិករហូតដល់អាយុ 21 ឆ្នាំ។
សេវាកម្មទាំងនេះត្រូវបានរចនាឡើងជាពិសេសសម្រាប់សមាជិកម្នាក់ៗ។
សមាជិកដែលទទួលបានសេវាកម្មទាំងនេះមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ
កំពុងជួបប្រទះនឹងការផ្លាស់ប្តូរស្ត្រេស ឬវិបត្តិជីវិត
ហើយត្រូវការសេវាគាំទ្របន្ថែមរយៈពេលខ្លីជាក់លាក់។

សេវាកម្មទាំងនេះគឺជាប្រភេទនៃសេវាកម្មសុខភាពផ្លូវចិត្តឯកទេសដែលមាននៅទូទាំងខោនធី
ប្រសិនបើអ្នកមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ។ ដើម្បីទទួលបានសេវាកម្មព្យាបាលអាកប្បកិរិយា
អ្នកត្រូវតែទទួលបានសេវាកម្មសុខភាពផ្លូវចិត្ត មានអាយុក្រោម 21 ឆ្នាំ និងមាន Medi-Cal
ពេញលេញ។

- ប្រសិនបើអ្នករស់នៅផ្ទះ
  បុគ្គលិកនៃសេវាកម្មព្យាបាលអាកប្បកិរិយាអាចធ្វើការផ្គាល់មួយទល់មួយនឹងអ្នក
  ដើម្បីកាត់បន្ថយបញ្ហាអាកប្បកិរិយាធ្ងន់ធ្ងរ
  ដើម្បីព្យាយាមការពារអ្នកពីតម្រូវការទៅកាន់ការថែទាំកម្រិតខ្ពស់
  ដូចជាផ្ទះសម្រាប់ក្រុមសម្រាប់កុមារ និងយុវវ័យដែលមានអាយុក្រោម 21 ឆ្នាំ
  ដែលមានបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរខ្លាំង។
- ប្រសិនបើអ្នកកំពុងរស់នៅក្នុងកន្លែងស្នាក់នៅក្រៅផ្ទះ
  បុគ្គលិកនៃសេវាកម្មព្យាបាលអាកប្បកិរិយាអាចធ្វើការជាមួយអ្នក
  ដូច្នេះអ្នកប្រហែលជាអាចផ្លាស់ទៅផ្ទះវិញ
  ឬទៅកាន់បរិយាកាសដែលមានមូលដ្ឋានក្នុងក្រុមគ្រួសារ

ដូចជាទីកន្លែងផ្ទះចិញ្ចឹមជាដើម។

សេវាព្យាបាលអាកប្បកិរិយានឹងជួយអ្នក និងក្រុមគ្រួសារ អ្នកថែទាំ
ឬអាណាព្យាបាលរបស់អ្នកឱ្យរៀនវិធីថ្មីៗក្នុងការដោះស្រាយបញ្ហាអាកប្បកិរិយា
និងបង្កើនប្រភេទនៃអាកប្បកិរិយាដែលនឹងអនុញ្ញាតឱ្យអ្នកទទួលបានជោគជ័យ។ អ្នក
បុគ្គលិកសេវាព្យាបាលអាកប្បកិរិយា និងក្រុមគ្រួសារ អ្នកថែទាំ
ឬអាណាព្យាបាលរបស់អ្នកនឹងធ្វើការជាមួយគ្នាជាក្រុមដើម្បីដោះស្រាយអាកប្បកិរិយាដែលមាន
បញ្ហាក្នុងរយៈពេលខ្លីរហូតដល់អ្នកលែងត្រូវការសេវាកម្ម។
អ្នកនឹងមានផែនការសេវាព្យាបាលអាកប្បកិរិយា ដែលនឹងប្រាប់ពីអ្វីដែលអ្នក ក្រុមគ្រួសារ
អ្នកថែទាំ ឬអាណាព្យាបាលរបស់អ្នក និងបុគ្គលិកសេវាព្យាបាលអាកប្បកិរិយានឹងធ្វើ
ខណៈពេលកំពុងទទួលបានសេវាកម្មទាំងនេះ។
ផែនការសេវាព្យាបាលអាកប្បកិរិយាក៏នឹងរួមបញ្ចូលពេលវេលា
និងកន្លែងដែលផ្តល់សេវាកម្មផងដែរ។
បុគ្គលិកសេវាព្យាបាលអាកប្បកិរិយាអាចធ្វើការជាមួយអ្នកនៅកន្លែងភាគច្រើនដែលអ្នកទំនង
ជាត្រូវការជំនួយ។ នេះរួមបញ្ចូលទាំងផ្ទះរបស់អ្នក កន្លែងផ្ទះចិញ្ចឹម សាលារៀន
កម្មវិធីព្យាបាលពេលថ្ងៃ និងតំបន់ផ្សេងទៀតនៅក្នុងសហគមន៍។

ការសម្របសម្រួលការថែទាំស៊ីជម្រៅ

នេះគឺជាសេវាកម្មគ្រប់គ្រងករណីគោលដៅ ដែលជួយសម្រួលដល់ការវាយតម្លៃ
ការធ្វើផែនការថែទាំ និងការសម្របសម្រួលសេវាកម្មដល់អ្នកទទួលផលដែលមានអាយុក្រោម 21
ឆ្នាំ។
សេវាកម្មនេះគឺសម្រាប់អ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់កម្រិតទំហំពេញលេញនៃ
សេវាកម្ម Medi-Cal
និងអ្នកដែលត្រូវបានបញ្ជូនទៅសេវាកម្មដោយផ្អែកលើតម្រូវការផ្នែកវេជ្ជសាស្ត្រ។
សេវាកម្មនេះត្រូវបានផ្តល់ជូនតាមរយៈគោលការណ៍នៃគំរូការអនុវត្តសួលរួមបញ្ចូលគ្នា។
វារួមបញ្ចូលទាំងការបង្កើតក្រុមការងារនៃកុមារ និងគ្រួសារ

ដើម្បីជួយធានាថាមានទំនាក់ទំនងដែលមានសុខភាពល្អក្នុងចំណោមកុមារ
ក្រុមគ្រួសាររបស់ពួកគេ និងប្រព័ន្ធសេវាកម្មសម្រាប់កុមារដែលពាក់ព័ន្ធ។

ក្រុមការងារនៃកុមារ និងគ្រួសារ រួមមានការគាំទ្រពីអ្នកជំនាញ (ឧទាហរណ៍៖
អ្នកសម្របសម្រួលការថែទាំ អ្នកផ្តល់សេវា
និងអ្នកគ្រប់គ្រងករណីពីភ្នាក់ងារសេវាកម្មសម្រាប់កុមារ) ការគាំទ្រពីធម្មជាតិ (ឧទាហរណ៍៖
សមាជិកគ្រួសារ អ្នកជិតខាង មិត្តភក្តិ និងអ្នកសាសនា)
និងមនុស្សផ្សេងទៀតដែលធ្វើការជាមួយគ្នាដើម្បីបង្កើត និងអនុវត្តផែនការអតិថិជន។
ក្រុមនេះគាំទ្រ និងធានាថាកុមារ និងគ្រួសារសម្រេចបាននូវគោលដៅរបស់ពួកគេ។

សេវាកម្មនេះក៏មានអ្នកសម្របសម្រួលម្នាក់ដែល៖

- ធានាថាសេវាកម្មចាំបាច់ផ្អែកវេជ្ជសាស្ត្រទទួលបាន សម្របសម្រួល
  និងផ្តល់ជូនតាមរបៀបដែលផ្អែកលើកម្លាំង បុគ្គល អតិថិជន សមស្របនឹងវប្បធម៌
  និងភាសា។
- ធានាថាសេវាកម្ម និងការគាំទ្រគឺផ្អែកលើតម្រូវការរបស់កុមារ។
- បង្កើតវិធីដើម្បីឱ្យមនុស្សគ្រប់គ្នាធ្វើការរួមគ្នាសម្រាប់កុមារ គ្រួសារ អ្នកផ្តល់សេវា។ល។
- គាំទ្រឪពុកម្តាយ/អ្នកថែទាំក្នុងការជួយបំពេញតម្រូវការរបស់កុមារ
- ជួយបង្កើតក្រុមកុមារ និងគ្រួសារ និងផ្តល់ការគាំទ្រជាបន្តបន្ទាប់។
- ធានាថាកុមារត្រូវបានថែទាំដោយប្រព័ន្ធសេវាកម្មសម្រាប់កុមារផ្សេងទៀតនៅពេលដែល
  ត្រូវការ។

សេវាកម្មដែលមានមូលដ្ឋាននៅផ្ទះស៊ីជម្រៅ

- សេវាកម្មទាំងនេះត្រូវបានរចនាឡើងជាពិសេសសម្រាប់សមាជិកម្នាក់ៗ។
  វារួមបញ្ចូលទាំងការផ្សាភ្ជាប់ផ្អែកលើចំណុចខ្លាំងដើម្បីកែលម្អស្ថានភាពសុខភាពផ្លូវចិត្ត
  ដែលអាចរំខានដល់មុខងាររបស់កុមារ/យុវជន។
  សេវាកម្មទាំងនេះមានគោលបំណងជួយកុមារ/យុវជន

កសាងជំនាញចាំបាច់ដើម្បីដំណើរការបានល្អប្រសើរនៅផ្ទះ និងក្នុងសហគមន៍
និងបង្កើនសមត្ថភាពគ្រួសាររបស់ពួកគេក្នុងការជួយពួកគេធ្វើដូច្នេះ។

- សេវាកម្មដែលមានមូលដ្ឋាននៅផ្ទះស៊ីជម្រៅត្រូវបានផ្តល់ជូនក្រោមគំរូការអនុវត្តសួលរួម
បញ្ចូលគ្នាដោយក្រុមការងារនៃកុមារ និងគ្រួសារ។
វាប្រើប្រាស់ផែនការសេវាកម្មរួមរបស់គ្រួសារ។
សេវាកម្មទាំងនេះត្រូវបានផ្តល់ជូនដល់សមាជិកដែលមានអាយុក្រោម 21
ឆ្នាំដែលមានសិទ្ធិទទួលបានសេវាកម្ម Medi-Cal ពេញលេញ។
ការបញ្ជូនបន្តដោយផ្អែកលើតម្រូវការផ្អែកវេជ្ជសាស្ត្រគឺត្រូវការជាចាំបាច់ដើម្បីទទួលបាន
សេវាកម្មទាំងនេះ។

ការថែទាំព្យាបាលដោយឪពុកម្តាយចិញ្ចឹម

- គំរូសេវាកម្មថែទាំព្យាបាលដោយឪពុកម្តាយចិញ្ចឹមផ្តល់សេវាសុខភាពផ្លូវចិត្តឯកទេសរយៈ
ពេលខ្លី ស៊ីជម្រៅ និងផ្អែកលើរបួសផ្លូវចិត្តសម្រាប់កុមាររហូតដល់អាយុ 21 ឆ្នាំ
ដែលមានតម្រូវការផ្លូវចិត្ត និងអាកប្បកិរិយាសួគស្ទាញ។
សេវាកម្មទាំងនេះត្រូវបានរចនាឡើងជាពិសេសសម្រាប់សមាជិកម្នាក់ៗ។
នៅក្នុងការថែទាំព្យាបាលដោយឪពុកម្តាយចិញ្ចឹម
កុមារត្រូវបានដាក់ឱ្យនៅជាមួយឪពុកម្តាយចិញ្ចឹមព្យាបាលដែលបានទទួលការបណ្តុះប
ណ្តាល ត្រួតពិនិត្យ និងគាំទ្រ។

ការព្យាបាលដោយការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយ និងកូន (PCIT)

- PCIT គឺជាកម្មវិធីមួយដែលជួយកុមារអាយុពី 2-7 ឆ្នាំដែលមានអាកប្បកិរិយាលំបាក
និងជួយឪពុកម្តាយ ឬអ្នកថែទាំរបស់ពួកគេរៀនវិធីថ្មីៗដើម្បីដោះស្រាយពួកគេ។
អាកប្បកិរិយាទាំងនេះអាចរួមបញ្ចូលការខឹងសម្បារ ឬការមិនគោរពតាមវិន័យ។
- តាមរយៈ PCIT ឪពុកម្តាយ ឬអ្នកថែទាំពាក់កាសស្តាប់ត្រចៀក
ពេលកំពុងលេងជាមួយកូនរបស់ពួកគេនៅក្នុងបន្ទប់លេងពិសេសមួយ។
អ្នកព្យាបាលមើលពីបន្ទប់ផ្សេងទៀត ឬតាមវីដេអូ ហើយផ្តល់ដំបូន្មានដល់ឪពុកម្តាយ
ឬអ្នកថែទាំតាមរយៈកាសស្តាប់ត្រ

ចៀក។ អ្នកព្យាបាលជួយឪពុកម្តាយ
ឬអ្នកថែទាំរៀនពីរបៀបលើកទឹកចិត្តដល់អាកប្បកិរិយាដែលមានសុខភាពល្អ
និងកែលម្អទំនាក់ទំនងរបស់ពួកគេជាមួយកូនរបស់ពួកគេ។

ការព្យាបាលមុខងារគ្រួសារ (FFT)

- FFT គឺជាកម្មវិធីប្រឹក្សាយោបល់រយៈពេលខ្លី និងផ្តោតសំខាន់សម្រាប់គ្រួសារ
  និងយុវជនដែលមានអាយុពី 11-18 ឆ្នាំ ដែលមានអាកប្បកិរិយាល់បាក
  ឬមានបញ្ហាក្នុងការដោះស្រាយអារម្មណ៍របស់ពួកគេ។ នេះអាចរួមបញ្ចូលការបំពានវិន័យ
  ការឈ្លោះប្រកែកគ្នា ឬការប្រើប្រាស់សារធាតុញៀន។
- FFT ធ្វើការជាមួយក្រុមគ្រួសារយុវជន
  និងជួនកាលសមាជិកផ្សេងទៀតនៃប្រព័ន្ធគាំទ្រយុវជនដូចជាគ្រូបង្រៀន ឬវេជ្ជបណ្ឌិត
  ដើម្បីជួយកាត់បន្ថយអាកប្បកិរិយាមិនល្អរបស់យុវជន។

ការព្យាបាលពហុប្រព័ន្ធ (MST)

- MST គឺជាកម្មវិធីដែលមានមូលដ្ឋានលើគ្រួសារសម្រាប់យុវជនដែលមានអាយុពី 12-17
  ឆ្នាំ ដែលបង្ហាញពីការល់បាកធ្ងន់ធ្ងរជាមួយនឹងអាកប្បកិរិយា។ MST
  ត្រូវបានគេប្រើជាញឹកញាប់សម្រាប់យុវជនដែលមានបញ្ហាជាមួយនឹងច្បាប់
  ឬអាចមានហានិភ័យនៃការជាប់ពាក់ព័ន្ធនឹងច្បាប់
  ឬមានហានិភ័យនៃការត្រូវបានបណ្តេញចេញពីផ្ទះរបស់ពួកគេដោយសារតែអាកប្បកិរិ
  យារបស់ពួកគេ។
- MST ពាក់ព័ន្ធនឹងការគាំទ្រពីក្រុមគ្រួសារ និងសហគមន៍ក្នុងការព្យាបាល
  ដើម្បីជួយយុវជនធ្វើការលើអាកប្បកិរិយាដូចជាការបំពានច្បាប់
  ឬការប្រើប្រាស់គ្រឿងញៀន។ MST
  ក៏ជួយឪពុកម្តាយរៀនជំនាញដើម្បីជួយពួកគេដោះស្រាយអាកប្បកិរិយាទាំងនេះនៅផ្ទះ
  ជាមួយមិត្តភក្តិរបស់ពួកគេ ឬនៅក្នុងសហគមន៍ផ្សេងទៀត។
- តាមរយៈ MST ឪពុកម្តាយ
  និងអ្នកថែទាំអាចរៀនពីរបៀបដោះស្រាយបញ្ហាប្រឈមជាមួយកូនៗ

ឬក្មេងជំទង់របស់ពួកគេ។ ពួកគេក៏នឹងរៀនដោះស្រាយបញ្ហានៅផ្ទះ ជាមួយមិត្តភក្តិ
ឬនៅក្នុងសង្កាត់របស់ពួកគេបានកាន់តែប្រសើរឡើង។ កម្មវិធីនេះគោរព
វប្បធម៌ផ្សេងៗគ្នា និងផ្តោតលើការជួយគ្រួសារនានានៅក្នុងផ្ទះ
និងសហគមន៍របស់ពួកគេផ្ទាល់។ វាក៏ធ្វើការជាមួយសាលារៀន ប៉ូលីស
និងតុលាការផងដែរ។

- ភាពញឹកញាប់នៃការជួបជុំគ្រួសារជាមួយកម្មវិធីនេះអាចផ្លាស់ប្តូរ។
  គ្រួសារខ្លះអាចត្រូវការការណាត់ជួបរយៈពេលខ្លី
  ខណៈពេលដែលគ្រួសារខ្លះទៀតអាចជួបគ្នារយៈពេលពីរម៉ោងជារៀងរាល់ថ្ងៃ
  ឬរៀងរាល់សប្តាហ៍។ ជំនួយនេះជាធម្មតាមានរយៈពេលពី 3 ទៅ 5 ខែ។

ការចូលឡើងវិញដែលពាក់ព័ន្ធនឹងយុត្តិធម៌

- ផ្តល់សេវាសុខភាពដល់សមាជិកដែលពាក់ព័ន្ធនឹងយុត្តិធម៌រហូតដល់ 90
  ថ្ងៃមុនពេលពួកគេត្រូវបានដោះលែងពីពន្ធនាគារ។ ប្រភេទសេវាកម្មដែលមានរួមមាន
  ការគ្រប់គ្រងករណីចូលឡើងវិញ សេវាពិគ្រោះយោបល់ផ្នែកសុខភាពអាកប្បកិរិយា
  ការគាំទ្រពីមិត្តភក្តិ ការប្រឹក្សាសុខភាពអាកប្បកិរិយា ការព្យាបាល ការអប់រំអ្នកជំងឺ
  សេវាថ្នាំ ការធ្វើផែនការក្រោយការដោះលែង និងឱ្យចេញវិញ សេវាមន្ទីរពិសោធន៍
  និងវិទ្យុសកម្ម ព័ត៌មានថ្នាំ
  សេវាគាំទ្រ និងជំនួយដើម្បីចុះឈ្មោះជាមួយអ្នកផ្តល់សេវាសមស្រប ឧទាហរណ៍
  កម្មវិធីព្យាបាលការញៀន ដើម្បីបន្តការព្យាបាលដោយជំនួយពីថ្នាំនៅពេលត្រូវបានដោះ
  លែង។ ដើម្បីទទួលបានសេវាកម្មទាំងនេះ បុគ្គលម្នាក់ៗត្រូវតែជាសមាជិក Medi-Cal ឬ
  CHIP និង៖
    - ប្រសិនបើមានអាយុក្រោម 21 ឆ្នាំ ដែលកំពុងជាប់ឃុំនៅមណ្ឌលកែប្រែយុវជន។
    - ប្រសិនបើជាមនុស្សពេញវ័យ ត្រូវស្ថិតនៅក្នុងការឃុំឃាំង
      និងបំពេញតម្រូវការថែទាំសុខភាពមួយក្នុងចំណោមតម្រូវការថែទាំសុខភាពរប
      ស់កម្មវិធី។
- សូមទាក់ទងខោនធីរបស់អ្នកដោយប្រើលេខទូរសព្ទនៅលើតម្រុបសៀវភៅណែនាំនេះស
  ម្រាប់ព័ត៌មានបន្ថែមអំពីសេវាកម្មនេះ។

សេវាកម្មគាំទ្រមិត្តភក្តិ Medi-Cal (ប្រៃប្រួលតាមខោនធី)

- សេវាកម្មគាំទ្រមិត្តភ័ក្តិ Medi-Cal លើកកម្ពស់ការជាសះស្បើយ ភាពរឹងមាំ ការចូលរួម
  ការទាក់ទងសង្គម ភាពពឹងលើខ្លួនឯង ការតស៊ូមតិដោយខ្លួនឯង
  ការអភិវឌ្ឍការគាំទ្រធម្មជាតិ
  និងការកំណត់អត្តសញ្ញាណចំណុចខ្លាំងតាមរយៈសកម្មភាពដែលមានរចនាសម្ព័ន្ធ។
  សេវាកម្មទាំងនេះអាចត្រូវបានផ្តល់ជូនអ្នក
  ឬអ្នកផ្តល់ការគាំទ្រដ៏សំខាន់ដែលអ្នកបានកំណត់
  ហើយអាចទទួលបានក្នុងពេលតែមួយជាមួយអ្នកទទួលបានសេវាកម្មសុខភាពផ្លូវចិត្ត
  ឬប្រព័ន្ធព្យាបាលវិបត្តប្រើប្រាស់ថ្នាំរៀបចំដោយ Medi-Cal ផ្សេងទៀត។
  អ្នកឯកទេសគាំទ្រមិត្តភក្តិក្នុងសេវាកម្មគាំទ្រមិត្តភក្តិ Medi-Cal
  គឺជាបុគ្គលដែលមានបទពិសោធន៍ជាមួយនឹងសុខភាពផ្លូវចិត្ត
  ឬស្ថានភាពប្រើប្រាស់សារធាតុញៀន ហើយកំពុងស្ថិតក្នុងការជាសះស្បើយ
  ដែលបានបំពេញតាមតម្រូវការនៃកម្មវិធីបញ្ជាក់ដែលរដ្ឋយល់ព្រមដោយខោនធី
  ដែលត្រូវបានបញ្ជាក់ដោយខោនធី
  និងអ្នកដែលផ្តល់សេវាកម្មទាំងនេះក្រោមការដឹកនាំរបស់អ្នកជំនាញសុខភាពផ្លូវចិត្ត
  ដែលមានអាជ្ញាប័ណ្ណ លើកលែង ឬចុះបញ្ជីជាមួយរដ្ឋ។
- សេវាកម្មគាំទ្រមិត្តភក្តិ Medi-Cal រួមមានការបង្វឹកជាលក្ខណៈបុគ្គល និងជាក្រុម ក្រុម
  កសាងជំនាញអប់រំ ការរុករកធនធាន
  សេវាកម្មចូលរួមដើម្បីលើកទឹកចិត្តអ្នកឱ្យចូលរួមក្នុងការព្យាបាលសុខភាពអាកប្បកិរិយា
  និងសកម្មភាពព្យាបាលដូចជាការលើកកម្ពស់ការតស៊ូមតិដោយខ្លួនឯង។
- សមាជិកដែលមានអាយុក្រោម 21
  ឆ្នាំអាចមានសិទ្ធិទទួលបានសេវាកម្មក្រោមការត្រួតពិនិត្យដំបូង និងតាមកាលកំណត់
   ថ្ងៃសម្រាប់ការសម្រេចចិត្តលើករណីរបស់អ្នកអាចបង្កគ្រោះថ្នាក់យ៉ាងធ្ងន់ធ្ងរដល់ជីវិត
   សុខភាព ឬសមត្ថភាពក្នុងការសម្រេចបាន រក្សា
   ឬទទួលបានមុខងារអតិបរមារបស់អ្នក។
2. ស្នើសុំ "សវនាការរហ័ស" ហើយផ្តល់លិខិតនោះជាមួយនឹងសំណើសុំសវនាការរបស់អ្នក។

ផ្នែកសវនាការរដ្ឋនៃនាយកដ្ឋានសេវាសង្គមនឹងពិនិត្យមើលសំណើរបស់អ្នកសម្រាប់ការសវនាការ
យុត្តិធម៌រដ្ឋដែលប្រញាប់ប្រញាល់ ហើយកំណត់ថាតើវាបំពេញតាមលក្ខណៈវិនិច្ឆ័យឬអត់។
ប្រសិនបើសំណើរបស់អ្នកត្រូវបានយល់ព្រម ការស្តាប់សវនាការនឹងត្រូវបានកំណត់ពេល
ហើយការសម្រេចចិត្តនឹងត្រូវបានធ្វើឡើងក្នុងរយៈពេលបីថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលផ្នែកសវ
នាការរដ្ឋទទួលបានសំណើរបស់អ្នក។

ឯកសារណែនាំផ្លូវការជាមុន

តើឯកសារណែនាំជាមុនជាអ្វី?

អ្នកមានសិទ្ធិទទួលបានឯកសារណែនាំជាមុន។ ឯកសារណែនាំជាមុនគឺជាឯកសារជាលាយ
លក្ខណ៍អក្សរអំពីការថែទាំសុខភាពរបស់អ្នកដែលត្រូវបានទទួលស្គាល់ក្រោមច្បាប់រដ្ឋកាលីហ្វ័រញ៉ា
។ ពេលខ្លះអ្នកអាចឮការណែនាំជាមុនដែលត្រូវបានពិពណ៌នាថាជាពាក្យបណ្តាំនៅរស់
ឬលិខិតប្រគល់សិទ្ធិអំណាចប្រើប្រាស់បានយូរ។
វារួមបញ្ចូលព័ត៌មានអំពីរបៀបដែលអ្នកចង់ឱ្យការថែទាំសុខភាពត្រូវបានផ្តល់ជូន
ឬនិយាយអំពីការសម្រេចចិត្តដែលអ្នកចង់ឱ្យធ្វើ ប្រសិនបើ
ឬនៅពេលដែលអ្នកមិនអាចនិយាយដោយខ្លួនឯងបាន។
នេះអាចរួមបញ្ចូលរឿងដូចជាសិទ្ធិក្នុងការទទួលយក ឬបដិសេធការព្យាបាលវេជ្ជសាស្ត្រ
ការរុះកាត់ ឬធ្វើការជ្រើសរើសការថែទាំសុខភាពផ្សេងទៀត។ នៅរដ្ឋកាលីហ្វ័រញ៉ា

ឯកសារណែនាំជាមុនមានពីរផ្នែក៖

- ការតែងតាំងភ្នាក់ងារ (មនុស្សម្នាក់)
  ដែលធ្វើការសម្រេចចិត្តអំពីការថែទាំសុខភាពរបស់អ្នក និង
- ការណែនាំអំពីការថែទាំសុខភាពផ្ទាល់ខ្លួនរបស់អ្នក។

ខោនធីរបស់អ្នកត្រូវមានកម្មវិធីណែនាំជាមុន។
ខោនធីរបស់អ្នកត្រូវបានតម្រូវឱ្យផ្តល់ព័ត៌មានជាលាយលក្ខណ៍អក្សរអំពីគោលនយោបាយណែនាំជាមុន និងពន្យល់អំពីច្បាប់រដ្ឋប្រសិនបើត្រូវបានស្នើសុំព័ត៌មាន។
ប្រសិនបើអ្នកចង់ស្នើសុំព័ត៌មាន
អ្នកគួរតែទូរសព្ទទៅលេខទូរសព្ទនៅលើគម្របសៀវភៅណែនាំនេះសម្រាប់ព័ត៌មានបន្ថែម។

អ្នកអាចទទួលបានទម្រង់បែបបទសម្រាប់ការណែនាំជាមុនពីខោនធីរបស់អ្នក
ឬតាមអ៊ីនធឺណិត។ នៅរដ្ឋកាលីហ្វ័រញ៉ា
អ្នកមានសិទ្ធិផ្តល់ការណែនាំអំពីការណែនាំជាមុនដល់អ្នកផ្តល់សេវាថែទាំសុខភាពទាំងអស់របស់អ្នក។ អ្នកក៏មានសិទ្ធិផ្លាស់ប្តូរ
ឬលុបចោលការណែនាំជាមុនរបស់អ្នកនៅពេលណាក៏បានដែរ។

ប្រសិនបើអ្នកមានសំណួរអំពីច្បាប់រដ្ឋកាលីហ្វ័រញ៉ាទាក់ទងនឹងតម្រូវការនៃការណែនាំជាមុន
អ្នកអាចផ្ញើលិខិតមួយទៅកាន់៖

នាយកដ្ឋានយុត្តិធម៌រដ្ឋកាលីហ្វ័រញ៉ា
សម្គាល់៖ អង្គភាពសាកសួរសាធារណៈ
P. O. Box 944255
Sacramento, CA 94244-2550

សិទ្ធិ និងទំនួលខុសត្រូវ

ការទទួលខុសត្រូវរបស់ខោនធី

តើខោនធីរបស់ខ្ញុំទទួលខុសត្រូវលើអ្វីខ្លះ?

ខោនធីរបស់អ្នកទទួលខុសត្រូវចំពោះចំណុចដូចខាងក្រោម៖

- ការស្វែងរកថាតើអ្នកបំពេញតាមលក្ខណៈវិនិច្ឆ័យដើម្បីទទួលបានសេវាសុខភាពផ្លូវចិត្ត ពីខោនធី ឬបណ្តាញអ្នកផ្តល់សេវារបស់ខ្លួនឬអត់។
- ការផ្តល់ការត្រួតពិនិត្យ ឬការវាយតម្លៃ
  ដើម្បីកំណត់ថាតើអ្នកត្រូវការសេវាសុខភាពផ្លូវចិត្តឬអត់។
- ការផ្តល់លេខទូរសព្ទដែលហៅតតគិតថ្លៃដែលត្រូវបានឆ្លើយតប 24 ម៉ោងក្នុងមួយថ្ងៃ ប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍ ដែលអាចប្រាប់អ្នកពីរបៀបទទួលបានសេវាកម្មពីខោនធី។ លេខទូរសព្ទត្រូវបានរាយនៅលើគម្របសៀវភៅណែនាំនេះ។
- ត្រូវប្រាកដថាមានអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តគ្រប់គ្រាន់នៅក្បែរនោះ
  ដើម្បីឱ្យអ្នកអាចទទួលបានសេវាកម្មដែលគ្របដណ្តប់ដោយខោនធីរបស់អ្នកនៅពេលចាំបាច់។
- ជូនដំណឹង និងអប់រំអ្នកអំពីសេវាកម្មដែលមានពីខោនធីរបស់អ្នក។
- ការផ្តល់សេវាកម្មជាភាសារបស់អ្នកដោយមិនគិតថ្លៃដល់អ្នក ហើយប្រសិនបើចាំបាច់ នឹងផ្តល់ជូនអ្នកបកប្រែដោយឥតគិតថ្លៃ។
- ផ្តល់ជូនអ្នកនូវព័ត៌មានជាលាយលក្ខណ៍អក្សរអំពីអ្វីដែលអ្នកមានជាភាសាផ្សេងទៀត ឬទម្រង់ជំនួសដូចជាអក្សរប្រេល ឬអក្សរពុម្ពទំហំធំ។ សូមមើលផ្នែក
  "ព័ត៌មានបន្ថែមអំពីខោនធីរបស់អ្នក"
  ដែលមានទីតាំងនៅចុងបញ្ចប់នៃសៀវភៅណែនាំនេះសម្រាប់ព័ត៌មានបន្ថែម។
- ជូនដំណឹងដល់អ្នកអំពីការផ្លាស់ប្តូរសំខាន់ៗណាមួយនៅក្នុងព័ត៌មានដែលបានរៀបរាប់នៅក្នុងសៀវភៅណែនាំនេះយ៉ាងហោចណាស់ 30
  ថ្ងៃមុនពេលការផ្លាស់ប្តូរចាប់ផ្តើមមានប្រសិទ្ធភាព។
  ការផ្លាស់ប្តូរត្រូវបានចាត់ទុកថាមានសារៈសំខាន់នៅពេលដែលមានការកើនឡើង ឬថយចុះនៃបរិមាណ ឬប្រភេទសេវាកម្មដែលផ្តល់ជូន ប្រសិនបើមានការកើនឡើង ឬថយចុះនៃចំនួនអ្នកផ្តល់សេវាបណ្តាញ
  ឬប្រសិនបើមានការផ្លាស់ប្តូរផ្សេងទៀតដែលនឹងប៉ះពាល់ដល់អត្ថប្រយោជន៍ដែលអ្នកទទួលបានពីខោនធី។
- ត្រូវប្រាកដថាភ្ជាប់ការថែទាំសុខភាពរបស់អ្នកជាមួយនឹងផែនការ

ឬប្រព័ន្ធផ្សេងទៀតដែលអាចចាំបាច់ដើម្បីជួយផ្លាស់ប្តូរការថែទាំរបស់អ្នកបានយ៉ាងរលូន។ នេះរួមបញ្ចូលទាំងការជានាថាការបញ្ជូនបន្តសម្រាប់អ្នកឯកទេស
ឬអ្នកផ្តល់សេវាផ្សេងទៀតត្រូវបានតាមដានយ៉ាងត្រឹមត្រូវ
ហើយអ្នកផ្តល់សេវាថ្មីដែលត្រៀមក្នុងការថែទាំអ្នក។

- ត្រូវប្រាកដថាអ្នកអាចបន្តជួបអ្នកផ្តល់សេវាថែទាំសុខភាពបច្ចុប្បន្នរបស់អ្នក
ទោះបីជាពួកគេមិននៅក្នុងបណ្តាញរបស់អ្នកក៏ដោយ ក្នុងរយៈពេលយូរជាក់លាក់មួយ។
នេះជាការសំខាន់ប្រសិនបើការប្តូរអ្នកផ្តល់សេវានឹងប៉ះពាល់ដល់សុខភាពរបស់អ្នក
ឬបង្កើនឱកាសនៃការត្រូវទៅមន្ទីរពេទ្យ។

តើការដឹកជញ្ជូនមានផ្តល់ជូនទេ?

ប្រសិនបើអ្នកពិបាកចូលរួមការណាត់ជួបសុខភាពអាកប្បកិរិយា ឬសុខភាពផ្លូវចិត្តរបស់អ្នក
កម្មវិធី Medi-Cal ជួយរៀបចំការដឹកជញ្ជូនសម្រាប់អ្នក។
ការដឹកជញ្ជូនត្រូវតែផ្តល់ជូនសម្រាប់សមាជិក Medi-Cal
ដែលមិនអាចផ្តល់ការដឹកជញ្ជូនដោយខ្លួនឯងបាន
និងអ្នកដែលមានតម្រូវការផ្នែកវេជ្ជសាស្ត្រដើម្បីទទួលបានសេវាកម្មដែលគ្របដណ្តប់ដោយ
Medi-Cal ។ មានការដឹកជញ្ជូនពីរប្រភេទសម្រាប់ការណាត់ជួប៖

- មិនមែនវេជ្ជសាស្ត្រ៖ ការដឹកជញ្ជូនដោយយានយន្តឯកជន
ឬសាធារណៈសម្រាប់អ្នកដែលមិនមានមធ្យោបាយផ្សេងទៀតដើម្បីទៅដល់ការណាត់ជួបរបស់ពួកគេ។
- មិនមែនសង្គ្រោះបន្ទាន់វេជ្ជសាស្ត្រ៖ ការដឹកជញ្ជូនដោយរថយន្តសង្គ្រោះបន្ទាន់
រថយន្តសម្រាប់រទេះរុញ
ឬរថយន្តសម្រាប់ដឹកឥវ៉ាន់សម្រាប់អ្នកដែលមិនអាចប្រើប្រាស់ការដឹកជញ្ជូនសាធារណៈ
ឬឯកជនបាន។

មានការដឹកជញ្ជូនសម្រាប់ការធ្វើដំណើរទៅកន្លែងលក់ថ្នាំពេទ្យ ឬដើម្បីទៅយកសម្ភារវេជ្ជសាស្ត្រ
ដើងសិប្បនិម្មិត ឧបករណ៍ជំនួយ និងឧបករណ៍ផ្សេងៗទៀតដែលត្រូវការ។

ប្រសិនបើអ្នកមាន Medi-Cal ប៉ុន្តែមិនបានចុះឈ្មោះក្នុងផែនការថែទាំដែលគ្រប់គ្រង
ហើយអ្នកត្រូវការការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រទៅកាន់សេវាទាក់ទងនឹងសុខភាព
អ្នកអាចទាក់ទងដោយផ្ទាល់ទៅអ្នកផ្តល់សេវាដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ
ឬអ្នកផ្តល់សេវារបស់អ្នកសម្រាប់ជំនួយ។ នៅពេលអ្នកទាក់ទងក្រុមហ៊ុនដឹកជញ្ជូន
ពួកគេនឹងសួរព័ត៌មានអំពីកាលបរិច្ឆេទ និងពេលវេលាណាត់ជួបរបស់អ្នក។

ប្រសិនបើអ្នកត្រូវការការដឹកជញ្ជូនវេជ្ជសាស្ត្រដែលមិនមែនជាអាសន្ន
អ្នកផ្តល់សេវារបស់អ្នកអាចចេញវេជ្ជបញ្ជាការដឹកជញ្ជូនវេជ្ជសាស្ត្រដែលមិនមែនជាអាសន្ន
ហើយភ្ជាប់អ្នកជាមួយអ្នក
ផ្តល់សេវាដឹកជញ្ជូន ដើម្បីសម្របសម្រួលការធ្វើដំណើររបស់អ្នកទៅ
និងមកពីការណាត់ជួបរបស់អ្នក។

សម្រាប់ព័ត៌មានបន្ថែម និងជំនួយទាក់ទងនឹងការដឹកជញ្ជូន
សូមទាក់ទងផែនការថែទាំដែលគ្រប់គ្រងរបស់អ្នក។

សិទ្ធិសមាជិក

តើខ្ញុំមានសិទ្ធិអ្វីខ្លះក្នុងនាមជាអ្នកទទួលបានសេវាសុខភាពអាកប្បកិរិយារបស់ Medi-Cal?
ក្នុងនាមជាសមាជិក Medi-Cal
អ្នកមានសិទ្ធិទទួលបានសេវាសុខភាពអាកប្បកិរិយាចាំបាច់ផ្នែកវេជ្ជសាស្ត្រពីខោនធីរបស់អ្នក។
ពេលទទួលបានសេវាសុខភាពអាកប្បកិរិយា អ្នកមានសិទ្ធិ៖

- ប្រព្រឹត្តដោយការគោរពផ្ទាល់ខ្លួន និងការគោរពចំពោះសេចក្តីថ្លៃថ្នូរ
  និងភាពឯកជនរបស់អ្នក។
- ទទួលបានការពន្យល់ច្បាស់លាស់ និងអាចយល់បានពីជម្រើសនៃការព្យាបាលដែលមាន។
- ចូលរួមក្នុងការសម្រេចចិត្តទាក់ទងនឹងការថែទាំសុខភាពអាកប្បកិរិយារបស់អ្នក។
  នេះរួមបញ្ចូលទាំងសិទ្ធិក្នុងការបដិសេធការព្យាបាលណាមួយដែលអ្នកមិនចង់ទទួល។
- ទទួលយកសៀវភៅណែនាំនេះ ដើម្បីស្វែងយល់អំពីសេវាកម្មរបស់ខោនធី កាតព្វកិច្ចរបស់
  ខោនធី និងសិទ្ធិរបស់អ្នក។
- ស្នើសុំច្បាប់ចម្លងនៃកំណត់ត្រាវេជ្ជសាស្ត្ររបស់អ្នក ហើយស្នើសុំការផ្លាស់ប្តូរបើចាំបាច់។

- មានសេរីភាពពីការរឹតត្បិត
  ឬការឃុំឃាំងណាមួយដែលត្រូវបានដាក់ជាមធ្យោបាយនៃការបង្ខិតបង្ខំ ការដាក់វិន័យ ការសម្រួល ឬការសងសឹក។
- ទទួលបានការថែទាំទាន់ពេលវេលា 24/7 សម្រាប់ស្ថានភាពអាសន្ន បន្ទាន់ ឬរបត្តិ នៅពេលចាំបាច់ផ្នែកវេជ្ជសាស្ត្រ។
- តាមការស្នើសុំ ទទួលបានឯកសារជាលាយលក្ខណ៍អក្សរក្នុងទម្រង់ជំនួសដូចជា អក្សរប្រេល អក្សរបោះពុម្ពទំហំធំ និងទម្រង់សំឡេងឱ្យបានទាន់ពេលវេលា។
- ទទួលបានសេវាសុខភាពអាកប្បកិរិយាពីខោនធីដែលអនុវត្តតាមកិច្ចសន្យារដ្ឋរបស់ខ្លួន សម្រាប់ភាពអាចរកបាន សមត្ថភាព ការសម្របសម្រួល ការគ្របដណ្តប់ និងការអនុញ្ញាតឲ្យមានការថែទាំ។ ខោនធីត្រូវបានតម្រូវឲ្យ៖
  - ជួល ឬមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយអ្នកផ្តល់សេវាគ្រប់គ្រាន់ ដើម្បីធានាថាសមាជិកដែលមានសិទ្ធិទទួលបាន Medi-Cal ទាំងអស់ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាសុខភាពផ្លូវចិត្ត អាចទទួលបានសេវាទាំងនោះទាន់ពេលវេលា។
  - គ្របដណ្តប់លើសេវាកម្មចាំបាច់ផ្នែកវេជ្ជសាស្ត្រនៅខាងក្រៅបណ្តាញសម្រាប់អ្នកទាន់ពេលវេលា ប្រសិនបើខោនធីមិនមាននិយោជិត ឬអ្នកផ្តល់សេវាតាមកិច្ចសន្យាដែលអាចផ្តល់សេវាកម្មបាន។
    សូមចំណាំ៖
    ខោនធីត្រូវតែធ្វើឱ្យប្រាកដថាអ្នកមិនចំណាយប្រាក់បន្ថែមសម្រាប់ការទៅជួបអ្នកផ្តល់សេវាក្រៅបណ្តាញ។ សូមមើលខាងក្រោមសម្រាប់ព័ត៌មានបន្ថែម៖
    - *សេវាសុខភាពអាកប្បកិរិយាចាំបាច់ផ្នែកវេជ្ជសាស្ត្រ*
      សម្រាប់បុគ្គលដែលមានអាយុ 21 ឆ្នាំឡើងទៅ
      គឺជាសេវាកម្មដែលសមហេតុផល និងចាំបាច់ដើម្បីការពារជីវិត
      ដើម្បីទប់ស្កាត់ជំងឺធ្ងន់ធ្ងរ ឬពិការភាពធ្ងន់ធ្ងរ
      ឬដើម្បីបំបាត់ការឈឺចាប់ធ្ងន់ធ្ងរ។
      សេវាសុខភាពអាកប្បកិរិយាចាំបាច់ផ្នែកវេជ្ជសាស្ត្រសម្រាប់បុគ្គលដែលមានអាយុក្រោម 21 ឆ្នាំ គឺជាសេវាកម្មដែលរក្សា គាំទ្រ កែលម្អ

ឬធ្វើឱ្យស្ថានភាពសុខភាពអាកប្បកិរិយាអាចទ្រាំទ្របានកាន់តែច្រើន។

- *អ្នកផ្តល់សេវាក្រៅបណ្តាញ*

  គឺជាអ្នកផ្តល់សេវាដែលមិនមាននៅក្នុងបញ្ជីអ្នកផ្តល់សេវារបស់ខោនធី។

- តាមការស្នើសុំរបស់អ្នក

  សូមផ្តល់យោបល់ទីពីរពីអ្នកជំនាញថែទាំសុខភាពដែលមានសមត្ថភាពនៅក្នុង ឬក្រៅបណ្តាញដោយមិនគិតថ្លៃបន្ថែម។

- ត្រូវប្រាកដថាអ្នកផ្តល់សេវាត្រូវបានបណ្តុះបណ្តាលដើម្បីផ្តល់សេវាសុខភាពផ្លូវចិត្តដែលអ្នកផ្តល់សេវាយល់ព្រមគ្របដណ្តប់។

- ត្រូវប្រាកដថាសេវាសុខភាពផ្លូវចិត្តដែលគ្របដណ្តប់ដោយខោនធីមានបរិមាណ រយៈពេល

  និងវិសាលភាពគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបស់សមាជិកដែលមានសិទ្ធិទទួលបាន Medi-Cal ។

  នេះរួមបញ្ចូលទាំងការធ្វើឱ្យប្រាកដថាវិធីសាស្ត្ររបស់ខោនធីសម្រាប់ការយល់ព្រមការទូទាត់សម្រាប់សេវាកម្មគឺផ្អែកលើភាពចាំបាច់ផ្អែកវេជ្ជសាស្ត្រ

  និងលក្ខណៈវិនិច្ឆ័យនៃការចូលប្រើប្រាស់ត្រូវបានប្រើប្រាស់ដោយយុត្តិធម៌។

- ត្រូវប្រាកដថាអ្នកផ្តល់សេវារបស់ខ្លួនធ្វើការវាយតម្លៃយ៉ាងហ្មត់ចត់

  និងសហការជាមួយអ្នកដើម្បីកំណត់គោលដៅព្យាបាល។

- សម្របសម្រួលសេវាកម្មដែលខ្លួនផ្តល់ជូនជាមួយនឹងសេវាកម្មដែលកំពុងផ្តល់ជូនអ្នកតាមរយៈផែនការថែទាំដែលបានគ្រប់គ្រង

  ឬជាមួយអ្នកផ្តល់សេវាថែទាំបឋមរបស់អ្នក ប្រសិនបើចាំបាច់។

- ចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋក្នុងការផ្តល់សេវាកម្មដែលមានសមត្ថភាពខាងវប្បធម៌ដល់មនុស្សទាំងអស់

  រួមទាំងអ្នកដែលមានជំនាញភាសាអង់គ្លេសមានកម្រិត និងសាវតារវប្បធម៌

  និងជនជាតិចម្រុះផងដែរ។

- បង្ហាញពីសិទ្ធិរបស់អ្នកដោយគ្មានការផ្លាស់ប្តូរដែលបង្កគ្រោះថ្នាក់ដល់ការព្យាបាល។
- ទទួលបានការព្យាបាល

  និងសេវាកម្មស្របតាមសិទ្ធិរបស់អ្នកដែលបានពិពណ៌នានៅក្នុងសៀវភៅណែនាំនេះ

និងស្របតាមច្បាប់សហព័ន្ធ និងរដ្ឋទាំងអស់ដែលអាចអនុវត្តបានដូចជា៖

- ចំណងជើងទី VI នៃច្បាប់សិទ្ធិពលរដ្ឋឆ្នាំ 1964 ដូចដែលបានអនុវត្តដោយបទប្បញ្ញត្តិនៅ 45 CFR ផ្នែកទី 80។
- ច្បាប់ស្តីពីការរើសអើងអាយុឆ្នាំ 1975 ដូចដែលបានអនុវត្តដោយបទប្បញ្ញត្តិនៅ 45 CFR ផ្នែកទី 91។
- ច្បាប់ស្តីពីការស្តារនីតិសម្បទាឆ្នាំ 1973 ។
- ចំណងជើងទី IX នៃវិសោធនកម្មអប់រំឆ្នាំ 1972 (ទាក់ទងនឹងកម្មវិធី និងសកម្មភាពអប់រំ)។
- ចំណងជើង II និង III នៃច្បាប់ស្តីពីជនពិការអាមេរិក។
- មាត្រា 1557 នៃច្បាប់ការពារអ្នកជំងឺ និងការថែទាំដែលមានតម្លៃសមរម្យ។

- អ្នកអាចមានសិទ្ធិបន្ថែមក្រោមច្បាប់រដ្ឋទាក់ទងនឹងការព្យាបាលសុខភាពអាកប្បកិរិយា។ ដើម្បីទាក់ទងអ្នកតស៊ូមតិសិទ្ធិអ្នកជំងឺរបស់ខោនធីរបស់អ្នក សូមទាក់ទងខោនធីរបស់អ្នកដោយប្រើលេខទូរសព្ទដែលមាននៅលើគម្របសៀវភៅណែនាំ។

ការកំណត់អត្តប្រយោជន៍មិនអំណោយផល

តើខ្ញុំមានសិទ្ធិអ្វីខ្លះ ប្រសិនបើខោនធីបដិសេធសេវាកម្មដែលខ្ញុំចង់បាន ឬគិតថាខ្ញុំត្រូវការ?

ប្រសិនបើខោនធីរបស់អ្នកបដិសេធ កំណត់ កាត់បន្ថយ ពន្យារពេល
ឬបញ្ចប់សេវាកម្មដែលអ្នកគិតថាអ្នកត្រូវការ
អ្នកមានសិទ្ធិទទួលបានការជូនដំណឹងជាលាយលក្ខណ៍អក្សរពីខោនធី។
ការជូនដំណឹងនេះត្រូវបានគេហៅថា
"ការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផល"។
អ្នកក៏មានសិទ្ធិមិនយល់ស្របនឹងការសម្រេចចិត្តដោយស្នើសុំបណ្តឹងឧទ្ធរណ៍ផងដែរ។
ផ្នែកខាងក្រោមជូនដំណឹងដល់អ្នកអំពីការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផល និងអ្វីដែលត្រូវធ្វើប្រសិនបើអ្នកមិនយល់ស្របនឹងការសម្រេចចិត្តរបស់ខោនធី។

តើការកំណត់អត្តប្រយោជន៍មិនអំណោយផលជាអ្វី?

ការកំណត់អត្តប្រយោជន៍មិនអំណោយផលត្រូវបានកំណត់ដោយសកម្មភាពណាមួយដូចខាងក្រោមដែលបានធ្វើឡើងដោយខោនធី៖

- ការបដិសេធ ឬការអនុញ្ញាតមានកំណត់ចំពោះសេវាកម្មដែលបានស្នើសុំ។ នេះរួមបញ្ចូលទាំងការកំណត់ដោយផ្អែកលើប្រភេទ ឬកម្រិតនៃសេវាកម្ម ភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រ ភាពសមស្រប ការកំណត់ ឬប្រសិទ្ធភាពនៃអត្តប្រយោជន៍ដែលគ្របដណ្តប់។
- ការកាត់បន្ថយ ការផ្អាក ឬការបញ្ចប់សេវាកម្មដែលត្រូវបានអនុញ្ញាតពីមុន
- ការបដិសេធទាំងស្រុង ឬមួយផ្នែក នៃការទូទាត់សម្រាប់សេវាកម្មណាមួយ
- ការខកខានក្នុងការផ្តល់សេវាកម្មទាន់ពេលវេលា
- ការខកខានមិនបានធ្វើសកម្មភាពក្នុងរយៈពេលកំណត់សម្រាប់ការដោះស្រាយបណ្តឹងសារទុក្ខ និងការប្តឹងឧទ្ធរណ៍តាមស្តង់ដារ។ ពេលវេលាកំណត់មានដូចខាងក្រោម៖
    - ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងជាមួយខោនធី ហើយខោនធីមិនឆ្លើយតបមកអ្នកវិញជាមួយនឹងការសម្រេចចិត្តជាលាយលក្ខណ៍អក្សរលើពាក្យបណ្តឹងរបស់អ្នកក្នុងរយៈពេល 30 ថ្ងៃ។
    - ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍ទៅខោនធី ហើយខោនធីមិនឆ្លើយតបមកអ្នកវិញជាមួយនឹងការសម្រេចចិត្តជាលាយលក្ខណ៍អក្សរលើបណ្តឹងឧទ្ធរណ៍របស់អ្នកក្នុងរយៈពេល 30 ថ្ងៃ។
    - ប្រសិនបើអ្នកបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍រហ័ស ហើយមិនបានទទួលការឆ្លើយតបក្នុងរយៈពេល 72 ម៉ោង។
- ការបដិសេធសំណើរបស់សមាជិកក្នុងការជំទាស់នឹងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ។

តើការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផលជាអ្វី?

សេចក្តីជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផល
គឺជាលិខិតជាលាយលក្ខណ៍អក្សរដែលខោនធីរបស់អ្នកនឹងផ្ញើទៅអ្នក
ប្រសិនបើវាសម្រេចចិត្តបដិសេធ កំណត់ កាត់បន្ថយ ពន្យារពេល ឬបញ្ចប់សេវាកម្មដែលអ្នក
និងអ្នកផ្តល់សេវារបស់អ្នកជឿថាអ្នកគួរតែទទួលបាន។
សេចក្តីជូនដំណឹងនេះនឹងពន្យល់ពីដំណើរការដែលខោនធីបានប្រើដើម្បីធ្វើការសម្រេចចិត្ត

និងរួមបញ្ចូលការពិពណ៌នាអំពីលក្ខណៈវិនិច្ឆ័យ
ឬគោលការណ៍ណែនាំដែលត្រូវបានប្រើដើម្បីកំណត់ថាតើសេវាកម្មនេះចាំបាច់ផ្នែកវេជ្ជសាស្ត្រឬអត់។

នេះរួមបញ្ចូលទាំងការបដិសេធ៖

- ការទូទាត់សម្រាប់សេវាកម្មមួយ។
- ការទាមទារសំណងសម្រាប់សេវាកម្មដែលមិនត្រូវបានគ្របដណ្តប់។
- ការទាមទារសំណងសម្រាប់សេវាកម្មដែលមិនចាំបាច់ផ្នែកវេជ្ជសាស្ត្រ។
- ការទាមទារសំណងសម្រាប់សេវាកម្មពីប្រព័ន្ធឌីកជញ្ជូនខុស។
- សំណើសុំជំទាស់នឹងការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ។

សូមចំណាំ៖

សេចក្តីជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផលក៏ត្រូវបានប្រើដើម្បីប្រាប់អ្នកផងដែរ ប្រសិនបើបណ្តឹងសារទុក្ខ បណ្តឹងឧទ្ធរណ៍
ឬបណ្តឹងឧទ្ធរណ៍រហ័សរបស់អ្នកមិនត្រូវបានដោះស្រាយទាន់ពេលវេលា
ឬប្រសិនបើអ្នកមិនទទួលបានសេវាកម្មក្នុងចន្លោះពេលស្តង់ដាររបស់ខោនធីសម្រាប់ការផ្តល់សេវាកម្ម។

ពេលវេលានៃការជូនដំណឹង

ខោនធីត្រូវផ្ញើសេចក្តីជូនដំណឹងតាមប្រៃសណីយ៍៖

- ជូនដល់សមាជិកយ៉ាងហោចណាស់ 10 ថ្ងៃមុនថ្ងៃនៃសកម្មភាពសម្រាប់ការបញ្ចប់ ការផ្អាក ឬការកាត់បន្ថយសេវាសុខភាពអាកប្បកិរិយាដែលមានការអនុញ្ញាតពីមុន។
- ជូនសមាជិកក្នុងរយៈពេលពីរថ្ងៃធ្វើការគិតចាប់ពីថ្ងៃសម្រេចចិត្តបដិសេធការទូទាត់ ឬការសម្រេចចិត្តដែលបណ្តាលឱ្យមានការបដិសេធ ការពន្យារពេល
ឬការកែប្រែសេវាសុខភាពអាកប្បកិរិយាទាំងអស់ ឬមួយផ្នែកដែលបានស្នើសុំ។

តើខ្ញុំនឹងទទួលបានការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផលជានិច្ចទេ នៅពេលដែលខ្ញុំមិនទទួលបានសេវាកម្មដែលខ្ញុំចង់បាន?

មែន អ្នកគួរតែទទួលបានការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផល។
ប្រសិនបើអ្នកមិនទទួលបានការជូនដំណឹងទេ អ្នកអាចដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមួយខោនធី
ឬប្រសិនបើអ្នកបានបញ្ចប់ដំណើរការប្តឹងឧទ្ធរណ៍ អ្នកអាចស្នើសុំការស្តាប់សវនាការយុត្តិធម៌រដ្ឋ។

នៅពេលអ្នកទាក់ទងខោនធីរបស់អ្នក
សូមបញ្ជាក់ថាអ្នកជួបប្រទះការកំណត់អត្តប្រយោជន៍មិនអំណោយផល
ប៉ុន្តែមិនបានទទួលការជូនដំណឹងទេ។ ព័ត៌មានអំពីរបៀបដាក់ពាក្យបណ្តឹងឧទ្ធរណ៍
ឬស្នើសុំសវនាការយុត្តិធម៌រដ្ឋត្រូវបានរួមបញ្ចូលនៅក្នុងសៀវភៅណែនាំនេះ
ហើយគួរតែមាននៅក្នុងការិយាល័យអ្នកផ្តល់សេវារបស់អ្នកផងដែរ។

តើការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផលនឹងប្រាប់ខ្ញុំអ្វីខ្លះ?

សេចក្តីជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផលនឹងប្រាប់អ្នក៖

- អ្វីដែលខោនធីរបស់អ្នកបានធ្វើដែលប៉ះពាល់ដល់អ្នក
  និងសមត្ថភាពរបស់អ្នកក្នុងការទទួលបានសេវាកម្ម។
- កាលបរិច្ឆេទដែលការសម្រេចចិត្តនឹងចូលជាធរមាន និងមូលហេតុនៃការសម្រេចចិត្ត។
- ប្រសិនបើមូលហេតុនៃការបដិសេធនេះគឺថាសេវាកម្មនេះមិនមានភាពចាំបាច់ផ្នែកវេជ្ជ
  សាស្ត្រទេ
  ការជូនដំណឹងនឹងរួមបញ្ចូលការពន្យល់ច្បាស់លាស់អំពីមូលហេតុដែលខោនធីបានធ្វើការ
  សម្រេចចិត្តនេះ។ ការពន្យល់នេះនឹងរួមបញ្ចូលហេតុផលគ្លីនិកជាក់លាក់ថា
  ហេតុអ្វីបានជាសេវាកម្មនេះមិនត្រូវបានចាត់ទុកថាចាំបាច់វេជ្ជសាស្ត្រសម្រាប់អ្នក។
- ច្បាប់រដ្ឋ ឬសហព័ន្ធដែលការសម្រេចចិត្តនោះផ្អែកលើ។
- សិទ្ធិរបស់អ្នកក្នុងការដាក់ពាក្យបណ្តឹងឧទ្ធរណ៍
  ប្រសិនបើអ្នកមិនយល់ស្របនឹងការសម្រេចចិត្តរបស់ខោនធី។
- របៀបទទួលច្បាប់ចម្លងនៃឯកសារ កំណត់ត្រា
  និងព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងការសម្រេចចិត្តរបស់ខោនធី។
- របៀបដាក់ពាក្យបណ្តឹងឧទ្ធរណ៍ជាមួយខោនធី។
- របៀបស្នើសុំសវនាការយុត្តិធម៌របស់រដ្ឋ
  ប្រសិនបើអ្នកមិនពេញចិត្តនឹងការសម្រេចចិត្តរបស់ខោនធីលើបណ្តឹងឧទ្ធរណ៍របស់អ្នក។
- របៀបស្នើសុំបណ្តឹងឧទ្ធរណ៍រហ័ស ឬការសវនាការយុត្តិធម៌រដ្ឋរហ័ស។
- របៀបទទួលបានជំនួយដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬការស្នើសុំសវនាការយុត្តិធម៌របស់រដ្ឋ។
- រយៈពេលដែលអ្នកត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬស្នើសុំសវនាការយុត្តិធម៌របស់រដ្ឋ។
- សិទ្ធិរបស់អ្នកក្នុងការបន្តទទួលបានសេវាកម្ម
  ខណៈពេលដែលអ្នករង់ចាំការសម្រេចរបស់តុលាការឧទ្ធរណ៍ ឬសវនាការយុត្តិធម៌របស់រដ្ឋ
  របៀបស្នើសុំការបន្តសេវាកម្មទាំងនេះ
  និងថាតើថ្លៃដើមនៃសេវាកម្មទាំងនេះនឹងត្រូវបានគ្របដណ្តប់ដោយ Medi-Cal
  ដែរឬទេ។
- នៅពេលដែលអ្នកត្រូវដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ឬសំណើសុំសវនាការយុត្តិធម៌របស់រដ្ឋ

ត្រឹមថ្ងៃផុតកំណត់ ប្រសិនបើអ្នកចង់ឱ្យសេវាកម្មបន្ត។

តើខ្ញុំគួរធ្វើដូចម្តេច ពេលទទួលការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផល?

នៅពេលអ្នកទទួលបានការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនអំណោយផល
អ្នកគួរតែអានព័ត៌មានទាំងអស់នៅក្នុងការជូនដំណឹងដោយប្រុងប្រយ័ត្ន។
ប្រសិនបើអ្នកមិនយល់ពីការជូនដំណឹងទេ ខោនធីរបស់អ្នកអាចជួយអ្នកបាន។
អ្នកក៏អាចសុំឱ្យមនុស្សម្នាក់ទៀតជួយអ្នកបានដែរ។

អ្នកអាចស្នើសុំការបន្តសេវាកម្មដែលត្រូវបានបញ្ឈប់ នៅពេលអ្នកដាក់ពាក្យបណ្តឹងឧទ្ធរណ៍
ឬស្នើសុំសវនាការយុត្តិធម៌របស់រដ្ឋ។ អ្នកត្រូវតែស្នើសុំការបន្តសេវាកម្មមិនឱ្យលើសពី 10
ថ្ងៃប្រតិទិនបន្ទាប់ពីថ្ងៃដែលការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិនល្អត្រូវបានបោះត្រា
ប្រៃសណីយ៍ ឬប្រគល់ជូនអ្នក ឬមុនកាលបរិច្ឆេទចូលជាធរមាននៃការផ្លាស់ប្តូរ។

តើខ្ញុំអាចបន្តទទួលបានសេវាកម្មទេ ខណៈដែលកំពុងរង់ចាំការសម្រេចចិត្តប្តឹងឧទ្ធរណ៍?

មែន អ្នកប្រហែលជាអាចបន្តទទួលបានសេវាកម្មរបស់អ្នក
ខណៈពេលដែលអ្នកកំពុងរង់ចាំការសម្រេចចិត្ត។ នេះមានន័យថា
អ្នកអាចបន្តជួបអ្នកផ្តល់សេវារបស់អ្នក និងទទួលបានការថែទាំដែលអ្នកត្រូវការ។

តើខ្ញុំត្រូវធ្វើអ្វីដើម្បីបន្តទទួលបានសេវាកម្មរបស់ខ្ញុំ?

អ្នកត្រូវតែបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

- អ្នកស្នើសុំបន្តទទួលបានសេវាកម្មក្នុងរយៈពេល 10
  ថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលខោនធីផ្ញើការជូនដំណឹងអំពីការកំណត់អត្តប្រយោជន៍មិន
  អំណោយផល ឬមុនថ្ងៃដែលខោនធីបាននិយាយថាសេវាកម្មនឹងឈប់
  អាស្រ័យលើកាលបរិច្ឆេទដែលយឺតជាង។
- អ្នកបានដាក់ពាក្យបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល 60
  ថ្ងៃតាមប្រតិទិនគិតចាប់ពីថ្ងៃដែលមានចែងក្នុងសេចក្តីជូនដំណឹងអំពីការកំណត់អត្ត
  ប្រយោជន៍មិនអំណោយផល។
- បណ្តឹងឧទ្ធរណ៍នេះនិយាយអំពីការបញ្ឈប់ ការកាត់បន្ថយ
  ឬការផ្អាកសេវាកម្មដែលអ្នកកំពុងទទួលបានរួចហើយ។
- អ្នកផ្តល់សេវារបស់អ្នកបានយល់ព្រមថាអ្នកត្រូវការសេវាកម្មនេះ។

- រយៈពេលដែលខោនធីបានយល់ព្រមរួចហើយដោយសារសេវាកម្មនេះមិនទាន់បញ្ចប់នៅឡើយទេ។

ចុះបើខោនធីសម្រេចថាខ្ញុំមិនត្រូវការសេវាកម្មបន្ទាប់ពីការប្តឹងឧទ្ធរណ៍?

អ្នកនឹងមិនត្រូវបានតម្រូវឱ្យបង់ប្រាក់សម្រាប់សេវាកម្មដែលអ្នកបានទទួលក្នុងអំឡុងពេលដែលបណ្តឹងឧទ្ធរណ៍កំពុងរង់ចាំនោះទេ។

ការទទួលខុសត្រូវរបស់សមាជិក

តើខ្ញុំមានកាតព្វកិច្ចអ្វីខ្លះក្នុងនាមជាសមាជិក Medi-Cal?

វាជារឿងសំខាន់ដែលអ្នកត្រូវយល់ពីរបៀបដែលសេវាកម្មខោនធីដំណើរការ
ដើម្បីអ្នកអាចទទួលបានការថែទាំដែលអ្នកត្រូវការ។ វាក៏សំខាន់ផងដែរក្នុងការ៖

- ចូលរួមការព្យាបាលរបស់អ្នកតាមកាលវិភាគ។ អ្នកនឹងទទួលបានលទ្ធផលល្អបំផុត
  ប្រសិនបើអ្នកធ្វើការជាមួយអ្នកផ្តល់សេវារបស់អ្នក
  ដើម្បីបង្កើតគោលដៅសម្រាប់ការព្យាបាលរបស់អ្នក
  និងអនុវត្តតាមគោលដៅទាំងនោះ។ ប្រសិនបើអ្នកពិតជាត្រូវការខកខានការណាត់ជួប
  សូមទូរសព្ទទៅអ្នកផ្តល់សេវារបស់អ្នកយ៉ាងហោចណាស់ 24 ម៉ោងជាមុន
  ហើយកំណត់ពេលវេលាឡើងវិញសម្រាប់ថ្ងៃ និងពេលវេលាផ្សេងទៀត។
- តែងតែយកកាតសម្គាល់អត្តប្រយោជន៍ Medi-Cal (BIC)
  និងអត្តសញ្ញាណប័ណ្ណដែលមានរូបថតរបស់អ្នកមកជាមួយជានិច្ច
  នៅពេលអ្នកចូលរួមការព្យាបាល។
- ជូនដំណឹងដល់អ្នកផ្តល់សេវារបស់អ្នក
  ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្តល់មាត់មុនពេលណាត់ជួបរបស់អ្នក។
- ប្រាប់អ្នកផ្តល់សេវារបស់អ្នកអំពីកង្វល់ផ្នែកវេជ្ជសាស្ត្រទាំងអស់របស់អ្នក។
  ព័ត៌មានកាន់តែពេញលេញដែលអ្នកចែករំលែកអំពីតម្រូវការរបស់អ្នក
  ការព្យាបាលរបស់អ្នកនឹងកាន់តែទទួលបានជោគជ័យ។
- ប្រាកដថាសួរអ្នកផ្តល់សេវារបស់អ្នកនូវសំណួរណាមួយដែលអ្នកមាន។
  វាមានសារៈសំខាន់ខ្លាំងណាស់ដែលអ្នកត្រូវយល់ច្បាស់អំពីព័ត៌មានដែលអ្នកទទួលបានក្នុ

ងអំឡុងពេលព្យាបាល។

- អនុវត្តតាមជំហានសកម្មភាពដែលបានគ្រោងទុកដែលអ្នក
  និងអ្នកផ្តល់សេវារបស់អ្នកបានព្រមព្រៀងគ្នា។
- ទាក់ទងខោនធី ប្រសិនបើអ្នកមានសំណួរអំពីសេវាកម្មរបស់អ្នក
  ឬប្រសិនបើអ្នកមានបញ្ហាណាមួយជាមួយអ្នកផ្តល់សេវារបស់អ្នកដែលអ្នកមិនអាចដោះ
  ស្រាយបាន។
- ប្រាប់អ្នកផ្តល់សេវារបស់អ្នក និងខោនធី
  ប្រសិនបើអ្នកមានការផ្លាស់ប្តូរណាមួយចំពោះព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក។
  នេះរួមបញ្ចូលទាំងអាសយដ្ឋាន លេខទូរសព្ទ
  និងព័ត៌មានវេជ្ជសាស្ត្រផ្សេងទៀតដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់អ្នកក្នុងការចូ
  លរួមព្យាបាល។
- ប្រព្រឹត្តចំពោះបុគ្គលិកដែលផ្តល់ការប្រព្រឹត្តចំពោះអ្នកដោយការគោរព និងគួរសម។
- ប្រសិនបើអ្នកសង្ស័យថាមានការក្លែងបន្លំ ឬប្រព្រឹត្តខុសឆ្គង សូមរាយការណ៍អំពីវា៖
  - នាយកដ្ឋានសេវាថែទាំសុខភាពស្នើសុំឱ្យអ្នកណាម្នាក់ដែលសង្ស័យពីការក្លែងបន្លំ
    ការខ្ជះខ្ជាយ ឬការរំលោភបំពានរបស់ Medi-Cal
    សូមទូរសព្ទទៅខ្សែទូរសព្ទទាន់ហេតុការណ៍ DHCS Medi-Cal Fraud តាមរយៈ **1-800-822-6222** ។ ប្រសិនបើអ្នកមានអារម្មណ៍ថានេះជាអាសន្ន សូមទូរសព្ទមក **911**
    សម្រាប់ជំនួយភ្លាមៗ។ ការហៅទូរសព្ទនេះគឺឥតគិតថ្លៃ
    ហើយអ្នកហៅទូរសព្ទអាចនៅតែក្បាសម្ងាត់។
  - អ្នកក៏អាចរាយការណ៍ពីការក្លែងបន្លំ
    ឬការរំលោភបំពានដែលសង្ស័យតាមរយៈអ៊ីមែលទៅកាន់ fraud@dhcs.ca.gov
    ឬប្រើប្រាស់ទម្រង់បែបបទអនឡាញនៅ
    http://www.dhcs.ca.gov/individuals/Pages/StopMedi-CalFraud.aspx ។

តើខ្ញុំត្រូវបង់ប្រាក់សម្រាប់ Medi-Cal ដែរឬទេ?

មនុស្សភាគច្រើននៅក្នុង Medi-Cal មិនចាំបាច់ចំណាយអ្វីទាំងអស់សម្រាប់សេវាវេជ្ជសាស្ត្រ
ឬសុខភាពផ្លូវចិត្តទេ។ ក្នុងករណីខ្លះ អ្នកប្រហែលជាត្រូវចំណាយសម្រាប់សេវាវេជ្ជសាស្ត្រ

និង/ឬសុខភាពផ្លូវចិត្ត ដោយផ្អែកលើចំនួនទឹកប្រាក់ដែលអ្នកទទួលបាន ឬរកបានជារៀងរាល់ខែ។

- ប្រសិនបើប្រាក់ចំណូលរបស់អ្នកតិចជាងដែនកំណត់របស់ Medi-Cal សម្រាប់ទំហំគ្រួសាររបស់អ្នក អ្នកនឹងមិនចាំបាច់ចំណាយសម្រាប់សេវាវេជ្ជសាស្ត្រ ឬសុខភាពផ្លូវចិត្តទេ។
- ប្រសិនបើប្រាក់ចំណូលរបស់អ្នកលើសពីដែនកំណត់របស់ Medi-Cal សម្រាប់ទំហំគ្រួសាររបស់អ្នក អ្នកនឹងត្រូវបង់ប្រាក់ខ្លះសម្រាប់សេវាសុខភាពផ្លូវចិត្ត ឬសុខភាពផ្លូវចិត្តរបស់អ្នក។ ចំនួនទឹកប្រាក់ដែលអ្នកត្រូវបង់ត្រូវបានគេហៅថា "ចំណែកនៃការចំណាយ" របស់អ្នក។ នៅពេលដែលអ្នកបានបង់ "ចំណែកនៃការចំណាយ" របស់អ្នករួចហើយ Medi-Cal នឹងបង់វិក្កយបត្រវេជ្ជសាស្ត្រដែលនៅសល់ដែលអ្នកគ្របដណ្តប់សម្រាប់ខែនោះ។ នៅក្នុងខែដែលអ្នកមិនមានការចំណាយវេជ្ជសាស្ត្រ អ្នកមិនចាំបាច់បង់អ្វីទាំងអស់។
- អ្នកប្រហែលជាត្រូវបង់ប្រាក់ «ចូលរួមបង់» សម្រាប់ការព្យាបាលណាមួយក្រោម Medi-Cal ។ នេះមានន័យថាអ្នកត្រូវបង់ប្រាក់ចេញពីហោប៉ៅរបស់អ្នករាល់ពេលដែលអ្នកទទួលបានសេវាវេជ្ជសាស្ត្រ ឬទៅបន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យសម្រាប់សេវាកម្មធម្មតារបស់អ្នក។
- អ្នកផ្តល់សេវារបស់អ្នកនឹងប្រាប់អ្នកថាតើអ្នកត្រូវការធ្វើការបង់ថ្លៃរួមឬអត់។

សេចក្តីជូនដំណឹងអំពីការមិនរើសអើង

ការរើសអើងគឺផ្ទុយនឹងច្បាប់។ ខោនធី Los Angeles អនុវត្តតាមច្បាប់សិទ្ធិពលរដ្ឋរបស់រដ្ឋ និងសហព័ន្ធ។ ខោនធី Los Angeles មិនរើសអើងដោយខុសច្បាប់ មិនរាប់បញ្ចូលមនុស្ស ឬប្រព្រឹត្តចំពោះពួកគេខុសគ្នាដោយសារតែភេទ ពូជសាសន៍ ពណ៌សម្បុរ សាសនា ដូនតា ដើមកំណើតជាតិ អត្តសញ្ញាណក្រុមជនជាតិ អាយុ ពិការភាពផ្លូវចិត្ត ពិការភាពរាងកាយ ស្ថានភាពសុខភាព ព័ត៌មានហ្សែន ស្ថានភាពអាពាហ៍ពិពាហ៍ ភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទទេ។

ខោនធី Los Angeles ផ្តល់ជូន៖

- ជំនួយ និងសេវាកម្មឥតគិតថ្លៃដល់ជនពិការ
  ដើម្បីជួយពួកគេឱ្យទំនាក់ទំនងកាន់តែប្រសើរឡើង ដូចជា៖
  - អ្នកបកប្រែភាសាសញ្ញាដែលមានសមត្ថភាព
  - ព័ត៌មានជាលាយលក្ខណ៍អក្សរក្នុងទម្រង់ផ្សេងទៀត (អក្សរធំ អក្សរប្រេល សំឡេង ឬទម្រង់អេឡិចត្រូនិចដែលអាចចូលប្រើបាន)
- សេវាកម្មភាសាឥតគិតថ្លៃសម្រាប់អ្នកដែលភាសាចម្បងរបស់ពួកគេមិនមែនជាភាសាអង់គ្លេស ដូចជា៖
  - អ្នកបកប្រែដែលមានសមត្ថភាព
  - ព័ត៌មានដែលសរសេរជាភាសាផ្សេងទៀត

ប្រសិនបើអ្នកត្រូវការសេវាកម្មទាំងនេះ សូមទាក់ទងខោនធី 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ ដោយទូរសព្ទទៅ 1-800-854-7771 ។ ឬប្រសិនបើអ្នកមិនអាចស្តាប់ ឬនិយាយបានល្អ សូមទូរសព្ទមក TTY: 711 ។ តាមការស្នើសុំ ឯកសារនេះអាចត្រូវបានផ្តល់ជូនអ្នកជាអក្សរប្រេល អក្សរពុម្ពធំ សំឡេង ឬទម្រង់អេឡិចត្រូនិកដែលអាចចូលប្រើបាន។

<u>របៀបដាក់ពាក្យបណ្តឹងសារទុក្ខ</u>

ប្រសិនបើអ្នកជឿថាខោនធី Los Angeles បានបរាជ័យក្នុងការផ្តល់សេវាកម្មទាំងនេះ ឬមានការរើសអើងដោយខុសច្បាប់តាមវិធីផ្សេងទៀតដោយផ្អែកលើភេទ ពូជសាសន៍ ពណ៌សម្បុរ សាសនា ដូនតា ដើមកំណើតជាតិ អត្តសញ្ញាណក្រុមជនជាតិ អាយុ ពិការភាពផ្លូវចិត្ត ពិការភាពរាងកាយ ស្ថានភាពសុខភាព ព័ត៌មានហ្សែន ស្ថានភាពអាពាហ៍ពិពាហ៍ ភេទ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទ អ្នកអាចដាក់ពាក្យបណ្តឹងជាមួយខោនធី Los Angeles ។ អ្នកអាចដាក់ពាក្យបណ្តឹងតាមទូរសព្ទ ជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់ ឬតាមប្រព័ន្ធអេឡិចត្រូនិច៖

នាយកដ្ឋានសុខភាពផ្លូវចិត្ត

- <u>តាមទូរសព្ទ៖</u>
  ទាក់ទងការិយាល័យសិទ្ធិអ្នកជំងឺនៃនាយកដ្ឋានសុខភាពផ្លូវចិត្តខោនធី Los Angeles រវាងម៉ោង 8:30 ព្រឹក និង 5:00 ល្ងាច ដោយទូរសព្ទទៅ (800) 700-9996 ឬ (213) 738-4888 ។ ឬប្រសិនបើអ្នកមិនអាចស្តាប់ ឬនិយាយបានល្អ សូមទូរសព្ទមក (TTY: 711)។

- <u>ជាលាយលក្ខណ៍អក្សរ៖</u> សូមបំពេញទម្រង់ពាក្យបណ្តឹង ឬសរសេរលិខិតមួយ ហើយផ្ញើទៅ៖

  ការិយាល័យសិទ្ធិអ្នកជំងឺនៃនាយកដ្ឋានសុខភាពផ្លូវចិត្តខោនធី Los Angeles
  510 South Vermont Avenue, 21st Floor, Los Angeles, CA 90020

- <u>ដោយផ្ទាល់៖</u> សូមទៅជួបគ្រូពេទ្យរបស់អ្នក
  ឬទៅជួបនាយកដ្ឋានសុខភាពផ្លូវចិត្តខោនធី Los Angeles នៅ 510 South Vermont Avenue, Los Angeles, CA 90020
  ហើយនិយាយថាអ្នកចង់ដាក់ពាក្យបណ្តឹងសារទុក្ខ។

- <u>តាមប្រព័ន្ធអេឡិចត្រូនិច៖</u>
  ចូលមើលគេហទំព័រការិយាល័យសិទ្ធិអ្នកជំងឺនៃនាយកដ្ឋានសុខភាពផ្លូវចិត្តខោនធី Los Angeles នៅ https://dmh.lacounty.gov/our-services/patients-rights/

នាយកដ្ឋានបង្ការ និងត្រួតពិនិត្យការប្រើប្រាស់សារធាតុញៀននៃសុខភាពសាធារណៈ:

- <u>តាមទូរសព្ទ៖</u> សូមទាក់ទងនាយកដ្ឋានបង្ការ
  និងត្រួតពិនិត្យការប្រើប្រាស់សារធាតុញៀននៃសុខភាពសាធារណៈ:ខោនធី Los Angeles រវាងម៉ោង 8:00 ព្រឹក និង 5:00 ល្ងាច ដោយទូរសព្ទទៅ (626) 299-4532 ឬ (888) 742-7900 ចុចលេខ 2 ។ ឬ ប្រសិនបើអ្នកមិនអាចស្តាប់ ឬនិយាយបានល្អ សូមទូរសព្ទមក (TTY: 711)។

- <u>ជាលាយលក្ខណ៍អក្សរ៖</u> បំពេញ ពាក្យបណ្តឹង ឬសរសេរលិខិតមួយ ហើយផ្ញើរាទៅកាន់៖
  សាខាផ្នែកបង្ការ និងត្រួតពិនិត្យការប្រើប្រាស់សារធាតុញៀន កិច្ចសន្យា និងការអនុលោមតាមច្បាប់ 1000 South Fremont Avenue, Building A9 East, 3rd Floor, Box 34, Alhambra, California 91803

- <u>ដោយផ្ទាល់៖</u> សូមទៅជួបគ្រូពេទ្យរបស់អ្នក ឬទៅជួបគ្រូពេទ្យជំនាញខាងបង្ការ និងគ្រប់គ្រងការប្រើប្រាស់សារធាតុញៀននៅ 1000 South Fremont Avenue, Building A9 East, Alhambra, California 91803
  ហើយនិយាយថាអ្នកចង់ដាក់ពាក្យបណ្តឹង។

- <u>តាមប្រព័ន្ធអេឡិចត្រូនិច៖</u> សូមចូលទៅកាន់ទំព័រព័ត៌មាន

និងធនធានសម្រាប់សមាជិកនៃនាយកដ្ឋានបង្ការ
និងត្រួតពិនិត្យការប្រើប្រាស់សារធាតុញៀននៃនាយក ដ្ឋានសុខភាពសាធារណៈ
តាមរយៈ http://ph.lacounty.gov/sapc/PatientPublic.htm។

ការិយាល័យសិទ្ធិពលរដ្ឋ – នាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ា

អ្នកក៏អាចដាក់ពាក្យបណ្តឹងសិទ្ធិពលរដ្ឋជាមួយនាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ា
ការិយាល័យសិទ្ធិពលរដ្ឋតាមទូរសព្ទ ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ៖

- តាមទូរសព្ទ៖ ទូរសព្ទទៅ **916-440-7370** ។ ប្រសិនបើអ្នកមិនអាចនិយាយ ឬស្តាប់បានល្អ សូមទូរសព្ទមក **711 (**ការបញ្ជូនតរដ្ឋកាលីហ្វ័រញ៉ា)។
- ជាលាយលក្ខណ៍អក្សរ៖ សូមបំពេញទម្រង់ពាក្យបណ្តឹង ឬផ្ញើលិខិតទៅកាន់៖

  នាយកដ្ឋានសេវាថែទាំសុខភាព
  ការិយាល័យសិទ្ធិពលរដ្ឋ
  P.O. Box 997413, MS 0009
  Sacramento, CA 95899-7413

  ទម្រង់បែបបទពាក្យបណ្តឹងអាចរកបាននៅ៖

  https://www.dhcs.ca.gov/discrimination-grievance-procedures

- តាមប្រព័ន្ធអេឡិចត្រូនិច៖ ផ្ញើអ៊ីមែលទៅកាន់ CivilRights@dhcs.ca.gov.

ការិយាល័យសិទ្ធិពលរដ្ឋ – នាយកដ្ឋានសុខាភិបាល និងសេវាមនុស្សធម៌របស់សហរដ្ឋអាមេរិក

ប្រសិនបើអ្នកជឿថាអ្នកត្រូវបានគេរើសអើងដោយផ្អែកលើពូជសាសន៍ ពណ៌សម្បុរ
ដើមកំណើតជាតិ អាយុ ពិការភាព ឬភេទ
អ្នកក៏អាចដាក់ពាក្យបណ្តឹងសិទ្ធិពលរដ្ឋជាមួយក្រសួងសុខាភិបាល
និងសេវាមនុស្សរបស់សហរដ្ឋអាមេរិក ការិយាល័យសិទ្ធិពលរដ្ឋតាមទូរសព្ទ ជាលាយលក្ខណ៍អក្សរ
ឬតាមប្រព័ន្ធអេឡិចត្រូនិកផងដែរ៖

- តាមទូរសព្ទ៖ ទូរសព្ទទៅ **1-800-368-1019** ។ ប្រសិនបើអ្នកមិនអាចនិយាយ
  ឬស្តាប់បានល្អ សូមទូរសព្ទទៅ **TTY/TDD 1-800-537-7697** ។

- ជាលាយលក្ខណ៍អក្សរ៖ បំពេញទម្រង់ពាក្យបណ្តឹង ឬផ្ញើសំបុត្រទៅកាន់៖

  នាយកដ្ឋានសុខាភិបាល និងសេវាមនុស្សធម៌សហរដ្ឋអាមេរិក
  200 Independence Avenue, SW
  Room 509F, HHH Building
  Washington, D.C. 20201

- ទម្រង់បែបបទពាក្យបណ្តឹងអាចរកបាននៅ http://www.hhs.gov/ocr/office/file/index.html។

- តាមប្រព័ន្ធអេឡិចត្រូនិក៖
  ចូលទៅកាន់រឹបផតថលពាក្យបណ្តឹងរបស់ការិយាល័យសិទ្ធិពលរដ្ឋនៅ https://ocrportal.hhs.gov/ocr/portal/lobby.jsf

ការជូនដំណឹងអំពីការអនុវត្តឯកជនភាព

សេចក្តីថ្លែងការណ៍ដែលពិពណ៌នាអំពីគោលនយោបាយ
និងនីតិវិធីរបស់ខោនធីសម្រាប់ការរក្សាការសម្ងាត់នៃកំណត់ត្រាវេជ្ជសាស្ត្រអាចរកបាន
ហើយនឹងត្រូវបានផ្តល់ជូនអ្នកតាមការស្នើសុំ។
ប្រសិនបើអ្នកមានអាយុ និងមានសមត្ថភាពយល់ព្រមចំពោះសេវាសុខភាពអាកប្បកិរិយា
អ្នកមិនត្រូវបានតម្រូវឱ្យទទួលបានការអនុញ្ញាតពីសមាជិកផ្សេងទៀតដើម្បីទទួលបានសេវាសុ
ខភាពអាកប្បកិរិយា ឬដាក់ពាក្យបណ្តឹងសម្រាប់សេវាសុខភាពអាកប្បកិរិយានោះទេ។

អ្នកអាចស្នើសុំឱ្យខោនធីរបស់អ្នកផ្ញើការទំនាក់ទំនងអំពីសេវាសុខភាពផ្លូវចិត្តទៅកាន់អាសយ
ដ្ឋានសំបុត្រ អាសយដ្ឋានអ៊ីមែល ឬលេខទូរសព្ទផ្សេងទៀតដែលអ្នកជ្រើសរើស។
នេះត្រូវបានគេហៅថា "សំណើសុំការទំនាក់ទំនងសម្ងាត់"។ ប្រសិនបើអ្នកយល់ព្រមថែទាំ
ខោនធីនឹងមិនផ្តល់ព័ត៌មានអំពីសេវាសុខភាពផ្លូវចិត្តរបស់អ្នកទៅឱ្យនរណាម្នាក់ផ្សេងទៀត
ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអ្នកទេ។
ប្រសិនបើអ្នកមិនផ្តល់អាសយដ្ឋានសំបុត្រ អាសយដ្ឋានអ៊ីមែល ឬលេខទូរសព្ទទេ
ខោនធីនឹងផ្ញើការទំនាក់ទំនងក្នុងនាមអ្នកទៅកាន់អាសយដ្ឋាន
ឬលេខទូរសព្ទដែលមានក្នុងឯកសារ។

ខោនធីនឹងគោរពតាមសំណើរបស់អ្នកដើម្បីទទួលបានការទំនាក់ទំនងសម្ងាត់ក្នុងទម្រង់
និងទម្រង់ដែលអ្នកបានស្នើសុំ។

ឬពួកគេនឹងធ្វើឱ្យប្រាកដថាការទំនាក់ទំនងរបស់អ្នកងាយស្រួលដាក់ក្នុងទម្រង់
និងទម្រង់ដែលអ្នកបានស្នើសុំ។
ខោនធីនឹងផ្ញើពួកគេទៅកាន់ទីតាំងផ្សេងទៀតតាមជម្រើសរបស់អ្នក។
សំណើរបស់អ្នកសម្រាប់ការទំនាក់ទំនងសម្ងាត់មានរយៈពេលរហូតដល់អ្នកលុបចោលវា
ឬដាក់សំណើថ្មីសម្រាប់ការទំនាក់ទំនងសម្ងាត់។

អ្នកអាចស្នើសុំការទំនាក់ទំនងសម្ងាត់ពីភាគី LACDMH ឬ SAPC អ្នកផ្តល់សេវា
ឬមណ្ឌលថែទាំព្យាបាល។ មិនត្រូវការការពន្យល់សម្រាប់សំណើនោះទេ។

សេចក្តីថ្លែងការណ៍មួយស្តីពីគោលនយោបាយ និងនីតិវិធីនៃប្រព័ន្ធព្យាបាល
វិបត្តប្រើប្រាស់ថ្នាំរៀបចំដោយ Medi-Cal
របស់ខោនធីសម្រាប់ការការពារព័ត៌មានវេជ្ជសាស្ត្ររបស់អ្នក (ហៅថា
"សេចក្តីជូនដំណឹងអំពីការអនុវត្តឯកជនភាព") អាចរកបាននៅលើគេហទំព័ររបស់ខោនធី៖

- នាយកដ្ឋានសុខភាពផ្លូវចិត្តខោន Los Angeles ៖ https://dmh.lacounty.gov/our-services/consumer-and-family-affairs/privacy/
- នាយកដ្ឋានសុខភាពសាធារណៈខោនធី Los Angeles ការបង្ការ
  និងត្រួតពិនិត្យការប្រើប្រាស់សារធាតុញៀន៖
  http://ph.lacounty.gov/sapc/PatientPublic.htm

ពាក្យដែលត្រូវដឹង

ខ្សែទូរសព្ទសង្គ្រោះជីវិត និងការធ្វើអត្តឃាត 988៖
លេខទូរសព្ទដែលផ្តល់ការគាំទ្រដោយឥតគិតថ្លៃ
និងសម្ងាត់សម្រាប់អ្នកដែលកំពុងជួបប្រទះវិបត្តិសុខភាពផ្លូវចិត្ត
រួមទាំងគំនិតចង់ធ្វើអត្តឃាត។ វាអាចប្រើបាន 24/7
ដើម្បីភ្ជាប់អ្នកហៅទូរសព្ទជាមួយអ្នកប្រឹក្សាដែលបានទទួលការ
បណ្តុះបណ្តាល ដែលអាចផ្តល់ជំនួយ និងការគាំទ្រ។

ចៅក្រមផ្នែករដ្ឋបាល៖ ចៅក្រមម្នាក់ដែលស្តាប់ និងសម្រេចក្តីលើសំណុំរឿងពាក់ព័ន្ធនឹងការកំណត់អត្តប្រយោជន៍មិនអំណោយផល។

សមាគមនៃការញៀនវេជ្ជសាស្ត្រអាមេរិក (ASAM)៖
សមាគមវេជ្ជសាស្ត្រវិជ្ជាជីវៈមួយដែលតំណាងឱ្យវេជ្ជបណ្ឌិត
និងអ្នកជំនាញថែទាំសុខភាពផ្សេងទៀតដែលមានជំនាញក្នុងការព្យាបាលការញៀន។ អង្គការនេះបានបង្កើតលក្ខណៈវិនិច្ឆ័យ ASAM
ដែលជាសំណុំលក្ខណៈវិនិច្ឆ័យជាតិសម្រាប់ការព្យាបាលការញៀន។

ដំណោះស្រាយបណ្តឹងឧទ្ធរណ៍៖
ដំណើរការនៃការដោះស្រាយការមិនចុះសម្រុងគ្នាដែលអ្នកមានជាមួយនឹងការសម្រេចចិត្តដែលធ្វើឡើងដោយខោនធីអំពីការគ្របដណ្តប់នៃសេវាកម្មដែលបានស្នើសុំ។
និយាយឱ្យសាមញ្ញជាងនេះទៅទៀត៖
វាគឺជារបៀបដែលអ្នកទទួលបានការមើលឡើងវិញនូវការសម្រេចចិត្តដែលអ្នកមិនយល់ស្រប។

ផ្ទៃខាងមុខសរសេរកម្មវិធី (API)៖ API គឺដូចជាអ្នកនាំសារដែលអនុញ្ញាតឱ្យកម្មវិធីផ្សេងៗគ្នា "និយាយ" គ្នាទៅវិញទៅមក និងចែករំលែកព័ត៌មាន។

ការវាយតម្លៃ៖
សកម្មភាពសេវាកម្មមួយដែលត្រូវបានរចនាឡើងដើម្បីវាយតម្លៃស្ថានភាពបច្ចុប្បន្ននៃសុខភាពផ្លូវចិត្ត អារម្មណ៍ ឬអាកប្បកិរិយា។

ការអនុញ្ញាត៖ ការផ្តល់ការអនុញ្ញាត ឬការយល់ព្រម។

តំណាងដែលមានការអនុញ្ញាត៖
នរណាម្នាក់ដែលត្រូវបានអនុញ្ញាតដោយស្របច្បាប់ឱ្យធ្វើសកម្មភាពក្នុងនាមមនុស្សម្នាក់ទៀត។

សុខភាពអាកប្បកិរិយា៖ សំដៅលើសុខុមាលភាពអារម្មណ៍ ផ្លូវចិត្ត និងសង្គមរបស់យើង។
និយាយឱ្យសាមញ្ញជាងនេះទៅទៀត៖ វានិយាយអំពីរបៀបដែលយើងគិត មានអារម្មណ៍
និងធ្វើអន្តរកម្មជាមួយអ្នកដទៃ។

អត្តប្រយោជន៍៖ សេវាថែទាំសុខភាព និងថ្នាំដែលគ្របដណ្តប់ក្រោមផែនការសុខភាពនេះ។

កាតសម្គាល់អត្ថប្រយោជន៍ (BIC)៖ កាតសម្គាល់ខ្លួនដើម្បីផ្ទៀងផ្ទាត់ការធានារ៉ាប់រងសុខភាព Medi-Cal របស់អ្នក។

សេវាកម្មសម្របសម្រួលការថែទាំ (ការសម្របសម្រួលការថែទាំ)៖
ជួយមនុស្សឱ្យរុករកប្រព័ន្ធថែទាំសុខភាព។

អ្នកថែទាំ៖ នរណាម្នាក់ដែលផ្តល់ការថែទាំ និងការគាំទ្រដល់ម្នាក់ទៀតដែលត្រូវការជំនួយ។

អ្នកគ្រប់គ្រងករណី៖ អ្នកថែទាំដែលបានចុះបញ្ជី
ឬអ្នកធ្វើកិច្ចការសង្គមដែលអាចជួយសមាជិកឱ្យយល់អំពីបញ្ហាសុខភាពសំខាន់ៗ
និងរៀបចំការថែទាំជាមួយអ្នកផ្តល់សេវារបស់សមាជិក។

ការគ្រប់គ្រងករណី៖ វាគឺជាសេវាកម្មមួយដើម្បីជួយសមាជិកក្នុងការទទួលបានសេវាវេជ្ជសាស្ត្រ
អប់រំ សង្គម ស្ថានីតិសម្បទា ឬសេវាសហគមន៍ផ្សេងៗទៀតដែលត្រូវការ។ ម្យ៉ាងវិញទៀត
វាជួយមនុស្សឱ្យទទួលបានការថែទាំ និងការគាំទ្រដែលពួកគេត្រូវការ។

CHIP (កម្មវិធីធានារ៉ាប់រងសុខភាពកុមារ)៖
កម្មវិធីរបស់រដ្ឋាភិបាលដែលជួយគ្រួសារឱ្យទទួលបានការធានារ៉ាប់រងសុខភាពសម្រាប់កូនៗរបស់ពួកគេ បើពួកគេមិនមានលទ្ធភាពទិញវា។

អ្នកសម្របសម្រួលសិទ្ធិស៊ីវិល៖ ធានាថាស្ថាប័នមួយ (ដូចជាសាលារៀន ក្រុមហ៊ុន ឬភ្នាក់ងាររដ្ឋាភិបាល) គោរពតាមច្បាប់ដែលការពារមនុស្សពីការរើសអើង។

ជំរុញដោយអតិថិជន៖ អ្វីមួយដែលផ្តោតលើតម្រូវការ និងចំណង់ចំណូលចិត្តរបស់អតិថិជន។

ស្ថាប័នដែលមានមូលដ្ឋាននៅសហគមន៍៖
ក្រុមមនុស្សដែលធ្វើការរួមគ្នាដើម្បីកែលម្អសហគមន៍របស់ពួកគេ។

សេវាកម្មមនុស្សពេញវ័យផ្អែកលើហគមន៍ (CBAS)៖
សេវាកម្មសម្រាប់អ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យ
និងផ្អែកលើមណ្ឌលថែទាំសម្រាប់ការថែទាំរបស់អ្នកថែទាំជំនាញ សេវាសង្គម ការព្យាបាល
ការថែទាំផ្ទាល់ខ្លួន ការបណ្តុះបណ្តាល និងការគាំទ្រពីក្រុមគ្រួសារ និងអ្នកថែទាំ សេវាអាហា

រូបត្ថម្ភ ការដឹកជញ្ជូន
និងសេវាកម្មផ្សេងទៀតសម្រាប់សមាជិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

ការធ្វើឱ្យមានស្ថេរភាពផ្អែកលើសហគមន៍៖
ជួយមនុស្សដែលជួបប្រទះវិបត្តិសុខភាពផ្លូវចិត្តទទួលបានការគាំទ្រនៅក្នុងសហគមន៍របស់ពួកគេជំនួសឱ្យការទៅមន្ទីរពេទ្យ។

ការបន្តសេវាកម្ម៖ សូមមើលការបន្តនៃការថែទាំ។

ការបន្តនៃការថែទាំ៖ សមត្ថភាពរបស់សមាជិកគម្រោងក្នុងការបន្តទទួលបានសេវាកម្ម Medi-Cal ពីអ្នកផ្តល់សេវាក្រៅបណ្តាញដែលមានស្រាប់របស់ពួកគេរហូតដល់ 12 ខែ
ប្រសិនបើអ្នកផ្តល់សេវា និងខោនធីយល់ព្រម។

ការបង់ប្រាក់រួម (បង់រួម)៖ ការទូទាត់ដែលសមាជិកធ្វើ ជាទូទៅនៅពេលបម្រើការងារ
បន្ថែមពីលើការទូទាត់របស់ក្រុមហ៊ុនធានារ៉ាប់រង។

សេវាកម្មដែលគ្របដណ្តប់៖ សេវាកម្ម Medi-Cal ដែលខោនធីទទួលខុសត្រូវក្នុងការទូទាត់។
សេវាកម្មដែលគ្របដណ្តប់គឺស្ថិតនៅក្រោមលក្ខខណ្ឌ ដែនកំណត់ និងការដកចេញនៃកិច្ចសន្យា Medi-Cal រិសោធនកម្មកិច្ចសន្យាណាមួយ
និងដូចដែលបានរាយក្នុងសៀវភៅណែនាំសមាជិកនេះ
[ត្រូវបានគេស្គាល់ផងដែរថាជាទម្រង់ភស្តុតាងរួមបញ្ចូលគ្នានៃការគ្របដណ្តប់ (EOC)
និងការបង្ហាញ។

សេវាកម្មដែលមានសមត្ថភាពខាងវប្បធម៌៖ ការផ្តល់សេវាកម្មដែលគោរព
និងឆ្លើយតបទៅនឹងវប្បធម៌ ភាសា និងជំនឿរបស់បុគ្គលម្នាក់ៗ។

បុគ្គលគាំទ្រដ៏សំខាន់ដែលត្រូវបានចាត់តាំង៖ បុគ្គលដែលសមាជិក
ឬអ្នកផ្តល់សេវាគិតថាមានសារៈសំខាន់ចំពោះភាពជោគជ័យនៃការព្យាបាល។
នេះអាចរួមបញ្ចូលឪពុកម្តាយ ឬអាណាព្យាបាលស្របច្បាប់របស់អនីតិជន
អ្នកដែលរស់នៅក្នុងគ្រួសារតែមួយ និងសាច់ញាតិផ្សេងទៀតរបស់សមាជិក។

DHCS៖ នាយកដ្ឋានសេវាថែទាំសុខភាពរដ្ឋកាលីហ្វ័រញ៉ា។
នេះគឺជាការិយាល័យរដ្ឋដែលត្រួតពិនិត្យកម្មវិធី Medi-Cal ។

ការរើសអើង៖ ការប្រព្រឹត្តមិនយុត្តិធម៌ ឬមិនស្មើគ្នាចំពោះនរណាម្នាក់ដោយផ្អែកលើពូជសាសន៍ ភេទ សាសនា ទំនោរផ្លូវភេទ ពិការភាព ឬលក្ខណៈផ្សេងៗទៀតរបស់ពួកគេ។

ការត្រួតពិនិត្យដំបូង និងតាមកាលកំណត់ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល (EPSDT)៖
ចូលទៅកាន់ “Medi-Cal សម្រាប់កុមារ និងក្មេងជំទង់” ។

សេវាព្យាបាលផ្អែកលើគ្រួសារ៖ ផ្តល់ការគាំទ្រ និងការព្យាបាលដល់កុមារ
និងក្រុមគ្រួសាររបស់ពួកគេ
ដើម្បីដោះស្រាយបញ្ហាប្រឈមសុខភាពផ្លូវចិត្តនៅក្នុងបរិយាកាសផ្ទះ។

សេវាកម្មផែនការគ្រួសារ៖ សេវាកម្មដើម្បីការពារ ឬពន្យារពេលការមានផ្ទៃពោះ។
សេវាកម្មត្រូវបានផ្តល់ជូនសមាជិកដែលមានអាយុបង្កើតកូន ដើម្បីឱ្យពួកគេអាចកំណត់ចំនួន និងចន្លោះពេលនៃកូន។

តម្លៃសម្រាប់សេវា (FFS) Medi-Cal៖
គំរូទូទាត់ដែលអ្នកផ្តល់សេវាសុខភាពផ្លូវចិត្តទទួលបានប្រាក់សម្រាប់សេវាកម្មនីមួយៗដែលពួកគេផ្តល់ជូនអ្នកជំងឺ ជាជាងថ្លៃសេវាប្រចាំខែ ឬប្រចាំឆ្នាំសម្រាប់អ្នកជំងឺម្នាក់ៗ។ Medi-Cal Rx ត្រូវបានគ្របដណ្តប់ក្រោមកម្មវិធីនេះ។

ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ៖ ទទួលខុសត្រូវក្នុងការបង់បំណុល ឬថ្លៃដើម។

ផ្ទះគ្រួសារចិញ្ចឹម៖ គ្រួសារមួយដែលផ្តល់ការថែទាំជំនួស 24
ម៉ោងសម្រាប់កុមារដែលត្រូវបានបំបែកចេញពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេ។

ការក្លែងបន្លំ៖ អំពើចេតនាដើម្បីបោកបញ្ឆោត ឬបំភ្លៃការពិត
ដែលធ្វើឡើងដោយបុគ្គលដែលដឹងថា ការបោកបញ្ឆោត ឬការបំភ្លៃការពិតនោះ
អាចនាំទៅរកផលប្រយោជន៍ដែលគ្មានការអនុញ្ញាតមួយចំនួនដល់ខ្លួនឯង ឬអ្នកដទៃ។

Medi-Cal ទំហំពេញលេញ៖ ការថែទាំសុខភាពដោយឥតគិតថ្លៃ
ឬតម្លៃទាបសម្រាប់ប្រជាជននៅក្នុងរដ្ឋកាលីហ្វ័រញ៉ា

ដែលផ្តល់ច្រើនជាងការថែទាំសុខភាពបន្ទាន់។ វាផ្តល់ការថែទាំផ្នែក
វេជ្ជសាស្ត្រ ផ្ទេញ សុខភាពផ្លូវចិត្ត ផែនការគ្រួសារ និងការថែទាំភ្នែក។
វាក៏គ្របដណ្តប់លើការព្យាបាលសម្រាប់ការប្រើប្រាស់គ្រឿងស្រវឹង និងគ្រឿងញៀន
ថ្នាំដែលគ្រូពេទ្យរបស់អ្នកចេញ
វេជ្ជបញ្ជា និងច្រើនទៀត។

បណ្តឹងសារទុក្ខ៖ ការបញ្ចេញមតិមិនពេញចិត្តដោយពាក្យសំដី
ឬជាលាយលក្ខណ៍អក្សររបស់សមាជិកអំពីសេវាកម្មដែលគ្របដណ្តប់ដោយ Medi-Cal
ផែនការថែទាំដែលគ្រប់គ្រង ខោនធី ឬអ្នកផ្តល់សេវា Medi-Cal ។
បណ្តឹងសារទុក្ខគឺដូចគ្នានឹងពាក្យបណ្តឹងឧទ្ធរណ៍ដែរ។

អាណាព្យាបាល៖ បុគ្គលដែលទទួលខុសត្រូវផ្នែកច្បាប់ចំពោះការថែទាំ និងសុខុមាលភាពរបស់
អ្នកដទៃ ជាធម្មតាជាកុមារ ឬអ្នកដែលមិនអាចមើលថែខ្លួនឯងបាន។

មន្ទីរពេទ្យ៖ ជាកន្លែងដែលសមាជិកទទួលបានការថែទាំសម្រាប់អ្នកជំងឺសម្រាកព្យាបាលក្នុង
និងក្រៅមន្ទីរពេទ្យពីវេជ្ជបណ្ឌិត និងអ្នកថែទាំ។

ការសម្រាកព្យាបាលនៅមន្ទីរពេទ្យ៖
ការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យក្នុងនាមជាអ្នកជំងឺសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ។

អ្នកផ្តល់សេវាថែទាំសុខភាពឥណ្ឌា (IHCP)៖
កម្មវិធីថែទាំសុខភាពដែលដំណើរការដោយសេវាសុខភាពឥណ្ឌា (IHS) កុលសម្ព័ន្ធឥណ្ឌា
កម្មវិធីសុខភាពកុលសម្ព័ន្ធ អង្គការកុលសម្ព័ន្ធ ឬអង្គការឥណ្ឌាទីក្រុង (UIO)
ដូចដែលពាក្យទាំងនោះត្រូវបានកំណត់នៅក្នុងផ្នែកទី 4
នៃច្បាប់កែលម្អការថែទាំសុខភាពឥណ្ឌា (25 U.S.C. ផ្នែកទី 1603)។

ការវាយតម្លៃដំបូង៖ ការវាយតម្លៃសមាជិកដើម្បីកំណត់តម្រូវការសម្រាប់សេវាសុខភាពផ្លូវចិត្ត
ឬការព្យាបាលជំងឺដោយសារការប្រើប្រាស់សារធាតុញៀន។

ការបន្សាបជាតិពុលអ្នកជំងឺស្នាក់នៅមន្ទីរពេទ្យ៖
សេវាថែទាំបន្ទាន់ផ្នែកវេជ្ជសាស្ត្រដោយស្ម័គ្រចិត្តសម្រាប់ការបន្សាបជាតិពុលសម្រាប់សមាជិកដែ
លមានផលវិបាកផ្នែកវេជ្ជសាស្ត្រធ្ងន់ធ្ងរដែលទាក់ទងនឹងការឈប់ប្រើប្រាស់ថ្នាំ។

គំរូការអនុវត្តសួលរួមបញ្ចូលគ្នា៖ ការណែនាំមួយដែលគូសបញ្ជាក់ពីតម្លៃ ស្តង់ដារ
និងការអនុវត្តសម្រាប់ការធ្វើការជាមួយកុមារ យុវជន និងគ្រួសារនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

អ្នកជំនាញសុខភាពផ្លូវចិត្តដែលមានអាជ្ញាប័ណ្ណ៖
អ្នកផ្តល់សេវាណាមួយដែលមានអាជ្ញាប័ណ្ណស្របតាមច្បាប់រដ្ឋកាលីហ្វ័រញ៉ាដែលអាចអនុវត្តបាន
ដូចជា៖ គ្រូពេទ្យដែលមានអាជ្ញាប័ណ្ណ អ្នកចិត្តសាស្ត្រដែលមានអាជ្ញាប័ណ្ណ
អ្នកសង្គមកិច្ចគ្លីនិកដែលមានអាជ្ញាប័ណ្ណ អ្នកប្រឹក្សាគ្លីនិក
វិជ្ជាជីវៈដែលមានអាជ្ញាប័ណ្ណ អ្នកព្យាបាលអាពាហ៍ពិពាហ៍ និងគ្រួសារដែលមានអាជ្ញាប័ណ្ណ
អ្នកថែទាំដែលបានចុះបញ្ជី អ្នកថែទាំវិជ្ជាជីវៈដែលមានអាជ្ញាប័ណ្ណ
អ្នកបច្ចេកទេសផ្លូវចិត្តដែលមានអាជ្ញាប័ណ្ណ។

មន្ទីរពេទ្យវិកលចរិកដែលមានអាជ្ញាប័ណ្ណ៖
មណ្ឌលព្យាបាលសុខភាពផ្លូវចិត្តដែលមានអាជ្ញាប័ណ្ណផ្តល់ការថែទាំអ្នកជំងឺក្នុងមន្ទីរពេទ្យ 24
ម៉ោងសម្រាប់អ្នកមានបញ្ហាផ្លូវចិត្ត អសមត្ថភាព ឬអ្នកដែលមានគ្រោះថ្នាក់ដល់ខ្លួនឯង
ឬអ្នកដទៃ។

មណ្ឌលថែទាំដែលមានអាជ្ញាប័ណ្ណ៖ មណ្ឌលសុខភាពដែលផ្តល់សេវាមិនមែនវេជ្ជសាស្ត្រសម្រាប់
ស្នាក់នៅដល់មនុស្សពេញវ័យដែលកំពុងជាសះស្បើយពីបញ្ហាទាក់ទងនឹងការប្រើប្រាស់គ្រឿង
ស្រវឹង ឬគ្រឿងញៀនផ្សេងទៀត (AOD) ខុស ឬរំលោភបំពាន។

ផែនការថែទាំដែលបានគ្រប់គ្រង៖ ផែនការសុខភាព Medi-Cal ដែលប្រើប្រាស់តែវេជ្ជបណ្ឌិត
អ្នកឯកទេស គ្លីនិក កន្លែងលក់ថ្នាំពេទ្យ និងមន្ទីរពេទ្យមួយចំនួនសម្រាប់អ្នកទទួល Medi-Cal
ដែលបានចុះឈ្មោះក្នុងផែនការនោះ។

Medi-Cal៖ កម្មវិធី Medicaid សហព័ន្ធរបស់រដ្ឋកាលីហ្វ័រញ៉ា។ Medi-Cal
ផ្តល់ជូនការធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ
និងតម្លៃទាបដល់មនុស្សដែលមានសិទ្ធិរស់នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា។

Medi-Cal សម្រាប់កុមារ និងក្មេងជំទង់៖ អត្ថប្រយោជន៍សម្រាប់សមាជិក Medi-Cal
ដែលមានអាយុក្រោម 21 ឆ្នាំ ដើម្បីជួយរក្សាសុខភាពរបស់ពួកគេ។
សមាជិកត្រូវតែទទួលបានការពិនិត្យសុខភាពត្រឹមត្រូវសម្រាប់អាយុរបស់ពួកគេ

និងការត្រួតពិនិត្យសមស្រប ដើម្បីស្វែងរកបញ្ហាសុខភាព
និងព្យាបាលជំងឺឱ្យបានទាន់ពេលវេលា។ ពួកគេត្រូវតែទទួលបានការព្យាបាល ដើម្បី
ថែរក្សា ឬជួយដល់ស្ថានភាពដែលអាចរកឃើញនៅក្នុងការត្រួតពិនិត្យ។
អត្ថប្រយោជន៍នេះត្រូវបានគេស្គាល់ផងដែរថាជាអត្ថប្រយោជន៍ពិនិត្យ ធ្វើរោគវិនិច្ឆ័យ
និងព្យាបាលដំបូង និងតាមកាលកំណត់ (EPSDT) ក្រោមច្បាប់សហព័ន្ធ។

អ្នកឯកទេសគាំទ្រមិត្តភក្តិ Medi-Cal៖
បុគ្គលម្នាក់ដែលធ្លាប់មានបទពិសោធន៍ជាមួយសុខភាពផ្លូវចិត្ត
ឬស្ថានភាពប្រើប្រាស់សារធាតុញៀន ហើយកំពុងស្ថិតក្នុងដំណាក់កាលជាសះស្បើយ
ដែលបានបំពេញតាមតម្រូវការនៃកម្មវិធីបញ្ជាក់ដែលរដ្ឋយល់ព្រមដោយខោនធី
ដែលត្រូវបានបញ្ជាក់ដោយខោនធី
និងដែលផ្តល់សេវាកម្មក្រោមការដឹកនាំរបស់អ្នកជំនាញសុខភាពផ្លូវចិត្ត ដែលមានអាជ្ញាប័ណ្ណ
លើកលែង ឬចុះបញ្ជីជាមួយរដ្ឋ។

Medi-Cal Rx៖ សេវាកម្មអត្ថប្រយោជន៍កន្លែងលក់ថ្នាំពេទ្យដែលជាផ្នែកមួយនៃ FFS Medi-Cal
និងត្រូវបានគេស្គាល់ថាជា "Medi-Cal Rx" ដែលផ្តល់អត្ថប្រយោជន៍ និងសេវាកម្មលក់ថ្នាំពេទ្យ
រួមទាំងថ្នាំពេទ្យតាមវេជ្ជបញ្ជា និងសម្ភារៈវេជ្ជសាស្ត្រមួយចំនួនដល់សមាជិក Medi-Cal ទាំងអស់។

ចាំបាច់ផ្នែកវេជ្ជសាស្ត្រ (ឬ ចាំបាច់វេជ្ជសាស្ត្រ)៖ សម្រាប់សមាជិកដែលមានអាយុ 21 ឆ្នាំឡើងទៅ
សេវាកម្មមួយគឺចាំបាច់ផ្នែកវេជ្ជសាស្ត្រ នៅពេលដែលវាសមហេតុផល
និងចាំបាច់ដើម្បីការពារអាយុជីវិត ដើម្បីទប់ស្កាត់ជំងឺធ្ងន់ធ្ងរ ឬពិការភាពធ្ងន់ធ្ងរ
ឬដើម្បីបំបាត់ការឈឺចាប់ធ្ងន់ធ្ងរ។ សម្រាប់សមាជិកដែលមានអាយុក្រោម 21 ឆ្នាំ
សេវាកម្មមួយគឺចាំបាច់ផ្នែកវេជ្ជសាស្ត្រ ប្រសិនបើវាត្រូវកែតម្រូវ ឬធ្វើឱ្យជំងឺផ្លូវចិត្ត
ឬស្ថានភាពដែលត្រូវបានរកឃើញដោយសេវាពិនិត្យ។

ការព្យាបាលដោយថ្នាំពេទ្យ (MAT)៖ ការប្រើប្រាស់ថ្នាំពេទ្យដែលត្រូវបានយល់ព្រមដោយ FDA
រួមផ្សំជាមួយនឹងការប្រឹក្សា ឬការព្យាបាលអាកប្បកិរិយា ដើម្បីផ្តល់វិធីសាស្ត្រ "អ្នកជំងឺទាំងមូល"
ចំពោះការព្យាបាលជំងឺប្រើប្រាស់សារធាតុញៀន។

សមាជិក៖ បុគ្គលម្នាក់ដែលបានចុះឈ្មោះក្នុងកម្មវិធី Medi-Cal ។

វិបត្តិសុខភាពផ្លូវចិត្ត៖ នៅពេលដែលនរណាម្នាក់កំពុងជួបប្រទះស្ថានភាពដែលអាកប្បកិរិយា ឬរោគសញ្ញារបស់ពួកគេធ្វើឱ្យខ្លួនគេ ឬអ្នកដទៃគ្រោះថ្នាក់ និងត្រូវការការយកចិត្តទុកដាក់ជាបន្ទាន់។

ផែនការសុខភាពផ្លូវចិត្ត៖
ខោនធីនីមួយៗមានផែនការសុខភាពផ្លូវចិត្តដែលទទួលខុសត្រូវក្នុងការផ្តល់ ឬរៀបចំសេវាកម្មសុខភាពផ្លូវចិត្តពិសេសដល់សមាជិក Medi-Cal នៅក្នុងខោនធីរបស់ពួកគេ។

បណ្តាញ៖ ក្រុមវេជ្ជបណ្ឌិត គ្លីនិក មន្ទីរពេទ្យ
និងអ្នកផ្តល់សេវាផ្សេងទៀតបានចុះកិច្ចសន្យាជាមួយខោនធីដើម្បីផ្តល់ការថែទាំ។

ការដឹកជញ្ជូនវេជ្ជសាស្ត្រមិនមែនបន្ទាន់៖ ការដឹកជញ្ជូនដោយរថយន្តសង្គ្រោះបន្ទាន់
រថយន្តសម្រាប់រទេះរុញ
ឬរថយន្តសម្រាប់ដឹកឥវ៉ាន់សម្រាប់អ្នកដែលមិនអាចប្រើប្រាស់ការដឹកជញ្ជូន
សាធារណៈ ឬឯកជនបាន។

ការដឹកជញ្ជូនមិនមែនវេជ្ជសាស្ត្រ៖ ការដឹកជញ្ជូននៅពេលធ្វើដំណើរទៅ
និងមកពីការណាត់ជួបសម្រាប់សេវាកម្មដែលគ្របដណ្តប់ដោយ Medi-Cal
ដែលត្រូវបានអនុញ្ញាតដោយអ្នកផ្តល់សេវារបស់សមាជិក និងនៅពេលទៅយកវេជ្ជបញ្ជា
និងសម្ភារៈវេជ្ជសាស្ត្រ។

ការិយាល័យអ្នកតំណាង៖ ជួយដោះស្រាយបញ្ហាពីទស្សនៈនៅកណ្តាល
ដើម្បីធានាថាសមាជិកទទួលបានសេវាកម្មចាំបាច់ផ្នែកវេជ្ជសាស្ត្រ
និងសេវាកម្មដែលគ្របដណ្តប់ទាំងអស់ ដែលផែនការទទួលខុសត្រូវតាមកិច្ចសន្យា។

ការដាក់ខ្លួននៅខាងក្រៅផ្ទះ៖ ការដកកុមារចេញពីផ្ទះរបស់ពួកគេជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ ទៅកាន់បរិយាកាសដែលមានសុវត្ថិភាពជាង ដូចជាជាមួយគ្រួសារចិញ្ចឹម ឬនៅក្នុងផ្ទះជាក្រុម។

អ្នកផ្តល់សេវាក្រៅបណ្តាញ៖
អ្នកផ្តល់សេវាដែលមិនមែនជាផ្នែកមួយនៃបណ្តាញដែលបានចុះកិច្ចសន្យារបស់ខោនធី។

ក្រៅហោប៉ាវ៖ ការចំណាយផ្ទាល់ខ្លួនសម្រាប់សមាជិកដើម្បីទទួលបានសេវាកម្មដែលគ្របដណ្តប់។
នេះរួមបញ្ចូលទាំងបុព្វលាភ ការបង់ប្រាក់រួម
ឬការចំណាយបន្ថែមណាមួយសម្រាប់សេវាកម្មដែលគ្របដណ្តប់។

សេវាសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺមិននៅមន្ទីរពេទ្យ៖
សេវាថែទាំអ្នកជំងឺក្រៅសម្រាប់សមាជិកដែលមានស្ថានភាពសុខភាពផ្លូវចិត្តស្រាលទៅមធ្យម
រួមមាន៖

- ការវាយតម្លៃ និងការព្យាបាលសុខភាពផ្លូវចិត្តជាលក្ខណៈបុគ្គល ឬជាក្រុម
  (ចិត្តសាស្ត្រព្យាបាល)
- ការធ្វើតេស្តផ្លូវចិត្ត នៅពេលដែលត្រូវបានចង្អុលបង្ហាញតាមគ្លីនិក
  ដើម្បីវាយតម្លៃស្ថានភាពសុខភាពផ្លូវចិត្ត
- សេវាអ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យសម្រាប់គោលបំណងតាមដានការព្យាបាលដោយថ្នាំ
- ការពិគ្រោះយោបល់ផ្នែកចិត្តសាស្ត្រ
- មន្ទីរពិសោធន៍ សម្ភារៈ និងអាហារបំប៉នសម្រាប់អ្នកជំងឺមិនស្នាក់នៅមន្ទីរពេទ្យ

អ្នកផ្តល់សេវាដែលចូលរួម (ឬវេជ្ជបណ្ឌិតដែលចូលរួម)៖ វេជ្ជបណ្ឌិត មន្ទីរពេទ្យ
ឬអ្នកជំនាញថែទាំសុខភាពដែលមានអាជ្ញាប័ណ្ណផ្សេងទៀត
ឬមណ្ឌលសុខភាពដែលមានអាជ្ញាប័ណ្ណ
រួមទាំងមណ្ឌលសុខភាពកម្រិតស្រាលដែលមានកិច្ចសន្យាជាមួយខោនធីដើម្បីផ្តល់សេវាកម្មដែល
គ្របដណ្តប់ដល់សមាជិកនៅពេលដែលសមាជិកទទួលបានការថែទាំ។

ការអភិវឌ្ឍផែនការ៖ សកម្មភាពសេវាកម្មដែលមានការអភិវឌ្ឍផែនការរបស់អតិថិជន
ការយល់ព្រមផែនការរបស់អតិថិជន និង/ឬការតាមដានវឌ្ឍនភាពរបស់សមាជិក។

ថ្នាំតាមវេជ្ជបញ្ជា៖ ថ្នាំដែលតម្រូវឱ្យមានការបញ្ជាទិញដោយស្របច្បាប់ពីអ្នកផ្តល់សេវាដែលមាន
អាជ្ញាប័ណ្ណ មិនដូចថ្នាំដែលមិនត្រូវការវេជ្ជបញ្ជា ("OTC") ដែលមិនតម្រូវឱ្យមានវេជ្ជបញ្ជាទេ។

ការថែទាំបឋម៖ ត្រូវបានគេស្គាល់ផងដែរថាជា "ការថែទាំជាប្រចាំ"។
ទាំងនេះគឺជាសេវាកម្មចាំបាច់ផ្នែកវេជ្ជសាស្ត្រ និងការថែទាំបង្ការ

ការទៅជួបគ្រូពេទ្យដើម្បីពិនិត្យសុខភាពកុមារ ឬការថែទាំដូចជាការថែទាំតាមដានជាប្រចាំ។
គោលដៅនៃសេវាកម្មទាំងនេះគឺដើម្បីការពារបញ្ហាសុខភាព។

អ្នកផ្តល់សេវាថែទាំបឋម (PCP)៖
អ្នកផ្តល់សេវាដែលមានអាជ្ញាប័ណ្ណដែលសមាជិកមានសម្រាប់ការថែទាំសុខភាពភាគច្រើនរបស់
ពួកគេ។ PCP ជួយសមាជិកទទួលបានការថែទាំដែលពួកគេត្រូវការ។ PCP អាចជា៖

- គ្រូពេទ្យទូទៅ
- គ្រូពេទ្យជំងឺសរីរាង្គ
- គ្រូពេទ្យឯកទេសជំងឺកុមារ
- គ្រូពេទ្យគ្រួសារ
- គ្រូពេទ្យឯកទេសសម្ភព/រោគស្ត្រី
- អ្នកផ្តល់សេវាថែទាំសុខភាពឥណ្ឌា (IHCP)
- មជ្ឈមណ្ឌលសុខភាពដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីសហព័ន្ធ (FQHC)
- គ្លីនិកសុខភាពជនបទ (RHC)
- អ្នកអនុវត្តការថែទាំ
- ជំនួយការគ្រូពេទ្យ
- គ្លីនិក

ការអនុញ្ញាតជាមុន (**ការយល់ព្រមជាមុន**)៖ ដំណើរការដែលសមាជិក
ឬអ្នកផ្តល់សេវារបស់ពួកគេត្រូវតែស្នើសុំការយល់ព្រមពីខោនធីសម្រាប់សេវាកម្មមួយចំនួន
ដើម្បីធានាថាខោនធីនឹងគ្រប
ដណ្តប់ពួកគេ។ ការបញ្ជូនបន្តមិនមែនជាការយល់ព្រមទេ។
ការអនុញ្ញាតជាមុនគឺដូចគ្នានឹងការយល់ព្រមជាមុនដែរ។

ការដោះស្រាយបញ្ហា៖ ដំណើរការដែលអនុញ្ញាតឱ្យសមាជិកដោះស្រាយបញ្ហា
ឬកង្វល់អំពីបញ្ហាណាមួយដែលទាក់ទងនឹងការទទួលខុសត្រូវរបស់ខោនធី
រួមទាំងការផ្តល់សេវាផងដែរ។

បញ្ជីអ្នកផ្តល់សេវា៖ បញ្ជីអ្នកផ្តល់សេវានៅក្នុងបណ្តាញរបស់ខោនធី។

ស្ថានភាពសង្គ្រោះបន្ទាន់ផ្នែកចិត្តសាស្ត្រ៖ ជំងឺផ្លូវចិត្ត ដែលរោគសញ្ញាធ្ងន់ធ្ងរ
ឬធ្ងន់ធ្ងរគ្រប់គ្រាន់ដើម្បីបង្កគ្រោះថ្នាក់ភ្លាមៗដល់សមាជិក ឬអ្នកដទៃ
ឬសមាជិកនោះមិនអាចផ្គត់ផ្គង់ ឬប្រើប្រាស់អាហារ ជម្រក
ឬសម្លៀកបំពាក់បានភ្លាមៗដោយសារតែជំងឺផ្លូវចិត្តនោះ។

ការធ្វើតេស្តផ្លូវចិត្ត៖ ការធ្វើតេស្តមួយដែលជួយយល់ពីគំនិត អារម្មណ៍
និងអាកប្បកិរិយារបស់នរណាម្នាក់។

ការបញ្ជូនបន្ត៖ នៅពេលដែល PCP
របស់សមាជិកម្នាក់និយាយថាសមាជិកអាចទទួលបានការថែទាំពីអ្នកផ្តល់សេវាផ្សេងទៀត។
សេវាថែទាំដែលគ្របដណ្តប់មួយចំនួនតម្រូវឱ្យមានការបញ្ជូនបន្ត និងការយល់ព្រមជាមុន
(ការអនុញ្ញាតជាមុន)។

សេវាកម្ម និងឧបករណ៍ព្យាបាលស្តារនីតិសម្បទា និងនីតិសម្បទា៖ សេវាកម្ម
និងឧបករណ៍ដើម្បីជួយសមាជិកដែលមានរបួស ពិការភាព ឬជំងឺរ៉ាំរ៉ៃ ដើម្បីទទួលបាន
ឬស្តារជំនាញផ្លូវចិត្ត និងរាងកាយឡើងវិញ។

សេវាកម្មកន្លែងស្នាក់នៅ៖ ផ្តល់លំនៅដ្ឋានបណ្តោះអាសន្ន
និងការគាំទ្រដល់មនុស្សដែលគ្មានផ្ទះសម្បែង ឬកំពុងជួបប្រទះវិបត្តិលំនៅដ្ឋាន។

ការត្រួតពិនិត្យ៖
ការត្រួតពិនិត្យរហ័សមួយត្រូវបានធ្វើឡើងដើម្បីកំណត់សេវាកម្មដែលសមស្របបំផុត។

ចំណែកនៃថ្លៃដើម៖
ចំនួនទឹកប្រាក់ដែលសមាជិកត្រូវបង់សម្រាប់ការចំណាយលើការព្យាបាលរបស់ពួកគេ មុនពេល
Medi-Cal នឹងបង់ថ្លៃសេវាកម្ម។

បញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ (បញ្ហាផ្លូវចិត្ត)៖ សំដៅលើបញ្ហាផ្លូវចិត្ត អាកប្បកិរិយា
ឬអារម្មណ៍ធ្ងន់ធ្ងរចំពោះកុមារ និងក្មេងជំទង់
ដែលរំខានដល់សមត្ថភាពរបស់ពួកគេក្នុងការបំពេញមុខងារនៅផ្ទះ សាលារៀន
ឬនៅក្នុងសហគមន៍។

អ្នកឯកទេស (ឬគ្រូពេទ្យឯកទេស)៖ វេជ្ជបណ្ឌិតដែលព្យាបាលបញ្ហាថែទាំសុខភាពមួយចំនួន។ ឧទាហរណ៍ គ្រូពេទ្យរះកាត់ឆ្អឹងព្យាបាលឆ្អឹងដែលបាក់ គ្រូពេទ្យឯកទេសអាឡែហ៊្សីព្យាបាលអាឡែហ៊្សី និងគ្រូពេទ្យឯកទេសបេះដូងព្យាបាលបញ្ហាបេះដូង។ ក្នុងករណីភាគច្រើន សមាជិកនឹងត្រូវការការបញ្ជូនពី PCP របស់ពួកគេដើម្បីទៅជួបអ្នកឯកទេស។

សេវាកម្មសុខភាពផ្លូវចិត្តពិសេស (SMHS)៖
សេវាកម្មសម្រាប់សមាជិកដែលមានតម្រូវការសេវាសុខភាពផ្លូវចិត្តដែលខ្ពស់ជាងកម្រិតនៃភាពចុះខ្សោយពីស្រាលទៅមធ្យម។

ផ្អែកលើចំណុចខ្លាំង៖ សម្លឹងមើលអ្វីដែលនរណាម្នាក់អាចធ្វើបាន ជាជាងគ្រាន់តែផ្តោតលើបញ្ហារបស់ពួកគេ។

សេវាកម្មសម្រាប់បញ្ហាប្រើប្រាស់សារធាតុញៀន៖
សេវាកម្មដែលជួយមនុស្សដែលកំពុងតស៊ូលំបាកជាមួយនឹងការញៀនថ្នាំ ឬគ្រឿងស្រវឹង។

កម្មវិធីសុខភាពពីចម្ងាយ៖
មធ្យោបាយមួយក្នុងការផ្តល់សេវាថែទាំសុខភាពតាមរយៈបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ដើម្បីសម្រួលដល់ការថែទាំសុខភាពរបស់អ្នកជំងឺ។

របួសផ្លូវចិត្ត៖ ភាពតានតឹងផ្លូវចិត្ត និងអារម្មណ៍យ៉ាងជ្រាលជ្រៅ ដែលកើតឡើងពីការជួបប្រទះ ឬឃើញព្រឹត្តិការណ៍ដ៏គួរឱ្យភ័យខ្លាចមួយ។

សេវាសុខភាពផ្លូវចិត្តឯកទេសដែលផ្អែកលើរបួសផ្លូវចិត្ត៖
សេវាកម្មទាំងនេះទទួលស្គាល់ថាមនុស្សជាច្រើនដែលកំពុងតស៊ូជាមួយបញ្ហាសុខភាពផ្លូវចិត្តបានជួបប្រទះនឹងរបួសផ្លូវចិត្ត ហើយពួកគេផ្តល់ការថែទាំដែលយកចិត្តទុកដាក់ និងគាំទ្រដល់អ្នកដែលរងរបួសផ្លូវចិត្ត។

ផែនការព្យាបាល៖ ផែនការមួយដើម្បីដោះស្រាយតម្រូវការរបស់សមាជិក និងតាមដានវឌ្ឍនភាព ដើម្បីស្តារកម្រិតមុខងារល្អបំផុតរបស់សមាជិកឡើងវិញ។

TTY/TDD៖ ឧបករណ៍ដែលជួយមនុស្សថ្លង់ ពិបាកស្តាប់ ឬមានបញ្ហាការនិយាយឲ្យធ្វើការហៅទូរសព្ទ។ TTY តំណាងឲ្យពាក្យ “Teletypewriter (ទូរលិខអង្គុលីលេខ)”។ TDD តំណាងឲ្យពាក្យ

“Telecommunications Device for the Deaf
(ឧបករណ៍ទូរគមនាគមន៍សម្រាប់ជនដែលមានបញ្ហាក្នុងការនិយាយ និងការស្តាប់)”។

សេវាកម្មវិជ្ជាជីវៈ៖ សេវាកម្មដែលជួយមនុស្សស្វែងរក និងរក្សាការងារ។

បញ្ជីរង់ចាំ៖ បញ្ជីមនុស្សដែលកំពុងរង់ចាំអ្វីមួយដែលមិនទាន់មាននាពេលបច្ចុប្បន្ន
ប៉ុន្តែអាចមាននៅពេលអនាគត។

ការប្រគល់ជូនដ៏កក់ក្តៅ៖
ការផ្ទេរការថែទាំដោយរលូនពីអ្នកផ្តល់សេវាម្នាក់ទៅអ្នកផ្តល់សេវាម្នាក់ទៀត។

ព័ត៌មានបន្ថែមអំពីខោនធីរបស់អ្នក

ព័ត៌មានបន្ថែមជាក់លាក់របស់ខោនធី

- ប្រព័ន្ធព្យាបាលវិបត្តប្រើប្រាស់ថ្នាំរៀបចំដោយ Medi-Cal របស់ខោនធី Los Angeles
  ផ្តល់ជូននូវសេវាកម្មគាំទ្រមិត្តភក្តិ Medi-Cal
  និងសេវាកម្មគ្រប់គ្រងគ្រាអាសន្ននៅទីតាំងដែលបានជ្រើសរើស។
- សូមមើលផ្នែក "ព័ត៌មានទំនាក់ទំនងរបស់ខោនធី"
  ដែលមានទីតាំងនៅដើមសៀវភៅណែនាំនេះ ដើម្បីស្នើសុំព័ត៌មានជាភាសាផ្សេងទៀត
  ឬទម្រង់ជំនួសដូចជាអក្សរប្រេល ឬអក្សរពុម្ពធំ។
- ប្រព័ន្ធផ្តល់សេវាសុខភាពផ្លូវចិត្តពិសេសរបស់ខោនធី Los Angeles
  ផ្តល់ជូននូវសេវាកម្មគាំទ្រមិត្តភក្តិ Medi-Cal ។